របាយការណ៍ពិនិត្យតាមដានជាសកល
លើការអប់រំសម្រាប់ទាំងអស់គ្នា

២០១៥





ការអប់រំសម្រាប់ទាំងអស់គ្នា



# ការអប់រំសម្រាប់ទាំងអស់គ្នា ២០០០ - ២០១៥ ៖ សមិទ្ធផល និងបញ្ហាប្រឈម

សង្ខេប















KH/2015/ED/RP/68
Phnom Penh, June 2015
Original: English

United Nations
Educational, Scientific and
Cultural Organization

# ការអប់រំសម្រាប់ទាំងអស់គ្នា ២០០០ - ២០១៥ ៖ សមិទ្ធផល និងបញ្ហាប្រឈម

# សង្ខេប

UNESCO Publishing

United Nations
Educational, Scientific and
Cultural Organization

របាយការណ៍នេះ គឺជាឯកសារបោះពុម្ពផ្សាយឯករាជ្យមួយ រៀបចំដោយអង្គការយូណេស្កូ ក្នុងនាមតំណាងឱ្យសហគមន៍អន្តរជាតិ។ របាយការណ៍នេះ គឺជាលទ្ធផលនៃការសហការគ្នារវាងសមាជិករបស់ក្រុមរៀបចំរបាយការណ៍ ជាមួយនឹងមនុស្សជាច្រើននាក់ផ្សេងទៀត ក៏ដូចជាជាមួយនឹងទីភ្នាក់ងារ ស្ថាប័ន និងរដ្ឋាភិបាលជាច្រើន។

ការប្រើឈ្មោះ និងមុខតំណែង និងការបង្ហាញពីសម្ភារ/ឯកសារនានា នៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនមែនមានន័យថាជាការសម្តែងពីការយល់ឃើញអ្វីមួយរបស់យូណេស្កូអំពីស្ថានភាពច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ ណាមួយ ឬអាជ្ញាធររបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់នោះ ឬពាក់ព័ន្ធជាមួយនឹងការកំណត់ព្រំប្រទល់ដែនរបស់ ប្រទេស ដែនដី ទីក្រុង ឬតំបន់នោះឡើយ។

ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ជាអ្នកទទួលខុសត្រូវលើការជ្រើសរើស និងការបង្ហាញពីព័ត៌មាននានា និងលើទស្សនៈយល់ឃើញនានា នៅក្នុងសៀវភៅនេះ ដែលមិនចាំបាច់ជាទស្សនៈយល់ឃើញរបស់យូណេស្កូឡើយ និងពុំតម្រូវឱ្យយូណេស្កូមានកាតព្វកិច្ចអ្វីនោះដែរ។ ប្រធានក្រុមការងារនេះ គឺជាអ្នកទទួលខុសត្រូវជារួមលើគំនិត និងទស្សនៈយល់ឃើញ នៅក្នុងរបាយការណ៍នេះ។


### ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានសកលលើការអប់រំសម្រាប់ទាំងអស់គ្នា

ប្រធាន ៖ Aaron Benavot

Manos Antoninis, Ashley Baldwin, Madeleine Barry, Nicole Bella, Nihan Köseleci Blanchy, Emeline Brylinski, Erin Chemery, Marcos Delprato, Joanna Härmä, Cornelia Hauke, Glen Hertelendy, Catherine Jere, Andrew Johnston, Priyadarshani Joshi, Helen Longlands, Leila Loupis, Giorgia Magni, Alasdair McWilliam, Anissa Mechtar, Claudine Mukizwa, David Post, Judith Randrianatoavina, Kate Redman, Maria Rojnov, Martina Simeti, Emily Subden, Felix Zimmermann និង Asma Zubairi.

### សមាជិកក្រុមការងារកន្លងមក

យើងខ្ញុំសូមថ្លែងអំណរគុណដល់ប្រធាន និងសមាជិកក្រុមការងាររៀបចំរបាយការណ៍ពិនិត្យតាមដានសកល កន្លងមក ដែលបានរួមចំណែកដ៏មានតម្លៃចំពោះការរៀបចំរបាយការណ៍នេះ ចាប់តាំងពីឆ្នាំ ២០០២ មក។ សូមថ្លែងអំណរគុណដល់អតីតប្រធានក្រុមការងារ ដែលមានដូចជា Nicholas Burnett, Christopher Colclough, Pauline Rose និង Kevin Watkins និងចំពោះ អតីតសមាជិករបស់ក្រុមការងារ ដូចជា Carlos Aggio, Kwame Akyeampong, Samer Al-Samarrai, Marc Philippe Boua Liebnitz, Mariela Buonomo, Lene Buchert, Fadila Caillaud, Stuart Cameron, Vittoria Cavicchioni, Mariana Cifuentes-Montoya, Alison Clayson, Hans Cosson-Eide, Roser Cusso, Valérie Djioze, Simon Ellis, Ana Font-Giner, Jude Fransman, Catherine Ginisty, Cynthia Guttman, Anna Haas, Elizabeth Heen, Julia Heiss, Keith Hinchliffe, Diederick de Jongh, Alison Kennedy, Léna Krichewsky, François Leclercq, Elise Legault, Agneta Lind, Anaïs Loizillon, Patrick Montjourides, Karen Moore, Albert Motivans, Hilaire Mputu, Michelle J. Neuman, Delphine Nsengimana, Banday Nzomini, Steve Packer, Ulrika Peppler Barry, Michelle Phillips, Liliane Phuong, Pascale Pinceau, Paula Razquin, Isabelle Reullon, Riho Sakurai, Marisol Sanjines, Yusuf Sayed, Sophie Schlondorff, Céline Steer, Ramya Subrahmanian,Ikuko Suzuki, Jan Van Ravens, Suhad Varin, Peter Wallet និង Edna Yahil។


របាយការណ៍ពិនិត្យតាមដានសកលលើការអប់រំសម្រាប់ទាំងអស់គ្នា គឺជាឯកសារបោះពុម្ពផ្សាយឯករាជ្យប្រចាំឆ្នាំ។ ការបោះពុម្ពផ្សាយឯកសារនេះធ្វើឡើង ក្រោមការសម្របសម្រួល និងដោយមានការគាំទ្រពីយូណេស្កូ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖
ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានសកលលើការអប់រំ សម្រាប់ទាំងអស់គ្នា
c/o UNESCO, 7, place de Fontenoy
75352 Paris 07 SP, France
Email: efareport@unesco.org
Tel.: +33 1 45 68 07 41
www.efareport.unesco.org
efareport.wordpress.com

កំហុស ឬការមិនបានបញ្ចូលព័ត៌មានអ្វីមួយ ដែលត្រូវបានរកឃើញ ក្រោយពេលបោះពុម្ព នឹងត្រូវកែតម្រូវនៅក្នុងឯកសារអេនឡាញ ដែលអាចរកបាន ក្នុងគេហទំព័រ www.efareport.unesco.org

របាយការណ៍ពិនិត្យតាមដានសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ដែលចេញផ្សាយកន្លងមក

| | |
|---|---|
| ២០១៣/១៤ | ការបង្រៀន និងរៀន ៖ សម្រេចឱ្យបាននូវគុណភាពសម្រាប់ទាំងអស់គ្នា |
| ២០១២ | យុវជន និងជំនាញ ៖ ប្រែក្លាយការអប់រំឱ្យទៅជាការងារ |
| ២០១១ | វិបត្តិលាក់មុខ ៖ ជម្លោះប្រដាប់អាវុធ និងការអប់រំ |
| ២០១០ | ការផ្តល់សេវាដល់ក្រុមជួបការលំបាក |
| ២០០៩ | ការជំនះបញ្ហាវិសមភាព ៖ ហេតុអ្វីបានជាអភិបាលកិច្ចមាន សារៈសំខាន់ |
| ២០០៨ | ការអប់រំសម្រាប់ទាំងអស់គ្នា ត្រឹមឆ្នាំ ២០១៥៖ តើយើងអាចសម្រេចបានដែរឬទេ ? |
| ២០០៧ | មូលដ្ឋានគ្រឹះរឹងមាំ ៖ ការគាំពារ និងអប់រំកុមារតូច |
| ២០០៦ | អក្ខរកម្មសម្រាប់ជីវិត |
| ២០០៥ | ការអប់រំសម្រាប់ទាំងអស់គ្នា ៖ លក្ខខណ្ឌតម្រូវខាងគុណភាព |
| ២០០៣/៤ | យេនឌ័រ និងការអប់រំសម្រាប់ទាំងអស់គ្នា ៖ ការលោតផ្លោះឆ្ពោះ ទៅរកសមភាព |
| ២០០២ | ការអប់រំសម្រាប់ទាំងអស់គ្នា ៖ តើពិភពលោកនេះកំពុងស្ថិតលើផ្លូវត្រូវឬ ? |

វាយអត្ថបទដោយ UNESCO
រចនាក្រាហ្វិចដោយ FHI 360
រៀបចំប្លង់ឯកសាររួមដោយ FHI 360

រូបថតគ្របមុខពីឆ្វេងទៅស្តាំ ៖ Karel Prinsloo, Mey Meng, UNICEF/
NYHQ2004-0991/Pirozzi, Nguyen Thanh Tuan, UNICEF/NYHQ2005-
1176/LeMoyne, Magali Corouge, Benavot, Eva-Lotta Jans-son, BRAC/
ShehzadNoorani, UNICEF/NYHQ2005-1194/LeMoyne, Karel Prinsloo,
Magali Corouge, Tutu Mani Chakma, Benavot, Amima Sayeed

# អារម្ភកថា

នៅក្នុងឆ្នាំ ២០០០ នាងវេទិកាអប់រំពិភពលោក ក្នុងទីក្រុងដាកា ប្រទេសសេណេហ្គាល់ រដ្ឋាភិបាលមកពី ប្រទេសចំនួន ១៦៤ បានឯកភាពលើក្របខ័ណ្ឌសកម្មភាពដាកា ក្រោមប្រធានបទ ការអប់រំសម្រាប់ ទាំងអស់គ្នា ៖ ការបំពេញនូវការប្ដេជ្ញាចិត្តរួមគ្នារបស់ យើង ដោយបានដាក់ចេញនូវ របៀបវារៈប្រកបដោយមហិច្ឆតាមួយ ដើម្បីសម្រេចគោលដៅចំនួន ៦ ត្រឹមឆ្នាំ ២០១៥។ ជាការឆ្លើយ តប យូណេស្កូបានផ្ដួចផ្ដើមឱ្យមានរបាយការណ៍ពិនិត្យតាមដានសកលលើការអប់រំសម្រាប់ទាំងអស់ គ្នានេះឡើង ក្នុងគោលបំណងពិនិត្យតាមដានលើវឌ្ឍនភាពដែលសម្រេចបានរំលេចឱ្យឃើញពី គម្លាតដែលនៅសេសសល់ និងផ្ដល់អនុសាសន៍សម្រាប់របៀបវារៈ នៃការអភិវឌ្ឍប្រកបដោយ ចីរភាពជាសកល ដែលនឹងត្រូវរៀបចំឡើង នៅក្នុងឆ្នាំ ២០១៥។

ចាប់តាំងពីឆ្នាំ ២០០០ មក មានការសម្រេចបាននូវវឌ្ឍនភាពយ៉ាងធំធេង ក្នុងពិភពលោក ទាំងមូល ប៉ុន្តែយើងនៅមិនទាន់ ទៅដល់គោលដៅរបស់យើងនៅឡើយ។ បើទោះបីជាមានកិច្ចខិតខំ ប្រឹងប្រែងគ្រប់បែបយ៉ាងពីសំណាក់រដ្ឋាភិបាល សង្គមស៊ីវិល និងសហគមន៍អន្តរជាតិយ៉ាងណា ក៏ដោយ ពិភពលោកទាំងមូលនៅតែមិនទាន់សម្រេចបាននូវការអប់រំសម្រាប់ទាំងអស់គ្នា។

អ្វីដែលជាចំណុចវិជ្ជមាននោះគឺ ចំនួនកុមារ និងក្មេងជំទង់ក្រៅសាលា បានថយចុះជិតពាក់ កណ្ដាល ចាប់តាំងពីឆ្នាំ ២០០០ មក។ មានកុមារប្រមាណជា ៣៤ លាននាក់ទៀត ដែលបាន ចូលរៀននៅសាលា ដោយសារតែមានការសម្រេចបាននូវវឌ្ឍនភាពកាន់តែឆាប់រហ័ស ចាប់តាំងពី វេទិកានៅទីក្រុងដាកាមក។ មានការសម្រេចនូវវឌ្ឍនភាពធំជាងគេ ខាងយុត្តភាពយេនឌ័រ ជាពិសេស នៅកម្រិតបឋមសិក្សា បើទោះបីជាគម្លាតយេនឌ័រ នៅតែបន្តមាន នៅក្នុង ប្រទេសជិតមួយភាគី នៃប្រទេសដែលមានទិន្នន័យក៏ដោយ។ រដ្ឋាភិបាលក៏បានបង្កើនកិច្ចខិតខំប្រឹង ប្រែង ដើម្បីវាស់វែងលទ្ធផលសិក្សា តាមរយៈការវាយតម្លៃកម្រិតជាតិផង និងកម្រិតអន្តរជាតិផង ដើម្បីធានាថា កុមារគ្រប់រូបពិតជាបានទទួលការអប់រំប្រកបដោយគុណភាព ដូចដែលបានសន្យា ចំពោះពួកគេ។

បើទោះជាមានការសម្រេចនូវវឌ្ឍនភាពទាំងនេះក៏ដោយ ការពិនិត្យតាមដាន ១៥ ឆ្នាំកន្លងមក បង្ហាញលទ្ធផលគួរឱ្យព្រួយបារម្ភ។

នៅទូទាំងសកលលោកទាំងមូល នៅមានកុមារក្រៅសាលា ៥៨ លាននាក់ទៀត និងមាន កុមារប្រមាណជា ១០០ លាននាក់ ដែលមិនបានរៀនចប់បឋមសិក្សា។ វិសមភាពក្នុងវិស័យអប់រំ មានការកើនឡើង ដោយអ្នកដែលក្រីក្រ និងជួបការលំបាកជាងគេ គឺជាអ្នករងបន្ទុកធ្ងន់ធ្ងរជាងគេ។ លទ្ធភាពដែលកុមារក្រីក្រជាងគេក្នុងពិភពលោក មិនបានទៅរៀននៅសាលារៀន មានច្រើនជាង កុមារដែលមានជីវភាពធូរធាជាងគេក្នុងពិភពលោក ៤ ដង ហើយលទ្ធភាពមិនបានរៀនចប់សាលា បឋមសិក្សាវិញគឺ ៥ ដង។ ជម្លោះ នៅតែជាឧបសគ្គយ៉ាងជ្រាលជ្រៅ ដោយកុមារក្រៅសាលា រស់នៅក្នុងតំបន់មានជម្លោះ មានភាគរយខ្ពស់ និងកាន់តែធំទៅៗ។ ជារួម ការរៀនសូត្រដែលមាន គុណភាពទាបនៅកម្រិតបឋមសិក្សា នៅតែធ្វើឱ្យកុមាររាប់លាននាក់ត្រូវបញ្ចប់ការសិក្សា ដោយពុំមាន ជំនាញជាមូលដ្ឋាន។

លើសពីនេះ ការអប់រំនៅតែទទួលបានថវិកាមិនគ្រប់។ រដ្ឋាភិបាលជាច្រើនបានបង្កើនចំណាយរបស់ខ្លួន ប៉ុន្តែមានរដ្ឋាភិបាលតែមួយចំនួនតូចប៉ុណ្ណោះដែលចាត់ទុកវិស័យអប់រំ ថាជាវិស័យអាទិភាព នៅក្នុងថវិកាជាតិរបស់ខ្លួន ហើយរដ្ឋាភិបាលភាគច្រើនវិភាជន៍ថវិកាក្នុងកម្រិតទាបជាង ២០% ដែលចាំបាច់ សម្រាប់ភ្ជាប់គម្លាតថវិកានេះ។ រូបភាពនេះ គឺស្រដៀងគ្នាជាមួយនឹងអ្នកផ្តល់ជំនួយដែរ ដែលក្រោយពេលបានបង្កើនថវិកាជំនួយរបស់ខ្លួនដំបូងៗរួចមក ចាប់ពីឆ្នាំ ២០១០ មក បែរជាកាត់បន្ថយជំនួយសម្រាប់ការអប់រំវិញ ហើយមិនបានផ្តល់អាទិភាពឱ្យបានគ្រប់គ្រាន់ដល់ប្រទេស ដែលមានតម្រូវការថវិកាច្រើនជាងគេឡើយ។

របាយការណ៍នេះប្រមូលផ្តុំបទពិសោធន៍ដូចរៀបរាប់ខាងលើនេះ ដើម្បីផ្តល់អនុសាសន៍មុតស្រួចអំពីទីកន្លែងរបស់ការអប់រំ នៅក្នុងរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពជាសកលនាពេលអនាគត។ មេរៀនទាំងនេះបង្ហាញយ៉ាងច្បាស់លាស់។ ចំណុចដៅអប់រំថ្មី ត្រូវតែមានលក្ខណៈជាក់លាក់ ពាក់ព័ន្ធ និងអាចវាស់វែងបាន។ ក្រុមដែលពុំមានឱកាសជួបការលំបាកពិបាកទៅដល់ និងនៅមិនទាន់មានសិទ្ធិទទួលបានការអប់រំ ត្រូវតែជាអាទិភាព។ ចាំបាច់ត្រូវតែមានការអនុវត្តសកម្មភាពឱ្យបានកាន់តែខ្លាំងក្លាពាក់ព័ន្ធនឹងការផ្តល់ថវិកានេះ ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ខណៈពេលដែលចំណាយមួយភាគធំត្រូវរ៉ាប់រងដោយរដ្ឋាភិបាល សហគមន៍អន្តរជាតិត្រូវតែប្រឹងប្រែងបន្ថែមទៀត ដើម្បីធានានិរន្តរភាព និងបង្កើនការផ្តល់ជំនួយដល់វិស័យអប់រំ ជាពិសេស នៅតាមប្រទេស ដែលមានចំណូលទាប និងចំណូលមធ្យមកម្រិតទាប ដែលមានតម្រូវការច្រើនជាងគេ។ របៀបវារៈនាពេលអនាគត ក៏ត្រូវការឱ្យមានការពិនិត្យតាមដានឱ្យបានខ្លាំងក្លាក្នុងកម្រិតមិនធ្លាប់មានកន្លងមក ដូចជា ការប្រមូលការវិភាគ និងការផ្សព្វផ្សាយទិន្នន័យជាដើម ដើម្បីទាមទារឱ្យរាល់អ្នកពាក់ព័ន្ធទាំងអស់មានគណនេយ្យភាព។

នៅក្នុងអំឡុងពេលឈានទៅរកឆ្នាំ ២០១៥ នេះ របាយការណ៍ពិនិត្យតាមដានសកលលើការអប់រំសម្រាប់ទាំងអស់គ្នា បំពេញតួនាទីនាំមុខ នៅក្នុងការផ្តល់ការគាំទ្រដល់ប្រទេសនានាតាមរយៈការផ្តល់ការវាយតម្លៃ និងការវិភាគដោយឈរលើមូលដ្ឋានរឹងមាំ ដើម្បីជួយសម្រួលដល់ការតាក់តែងគោលនយោបាយ និងអាចយកទៅប្រើប្រាស់ជាឧបករណ៍តស៊ូមតិប្រកបដោយអានុភាព សម្រាប់រដ្ឋាភិបាល និងសង្គមស៊ីវិល។ តួនាទីនេះនៅតែបន្តទៀត ខណៈពេលដែលយើងងាកមកអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពថ្មី។ ក្រោយឆ្នាំ ២០១៥ របាយការណ៍ទាំងនេះនឹងបន្តផ្តល់សំឡេងឯករាជ្យ ដែលអាចជឿទុកចិត្តបានអំពីស្ថានភាពនៃ ការអប់រំសកលតាមរយៈការផ្តល់នូវអនុសាសន៍ដ៏មានប្រយោជន៍ដល់គ្រប់ប្រទេស និងដៃគូទាំងអស់។

ចាប់តាំងពីឆ្នាំ ២០០០ មក មានការសម្រេចបាននូវសមិទ្ធផលជាច្រើន - យើងចាំបាច់ត្រូវធ្វើការងារយ៉ាងច្រើនថែមទៀត ដើម្បីធានាឱ្យមានការអប់រំប្រកបដោយគុណភាព និងការរៀនសូត្រពេញមួយជីវិត សម្រាប់ទាំងអស់គ្នា។ ពុំមានការវិនិយោគលើសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សអ្វីដែលមានអានុភាពជាង ឬផ្តល់ផលយូរអង្វែងជាងការវិនិយោគលើបរិយាប័ន្នសង្គម (ការគិតគូរពីទាំងអស់គ្នានៅក្នុងសង្គម) និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពឡើយ។ បទពិសោធន៍ចាប់តាំងពីឆ្នាំ ២០០០ មក បង្ហាញពីអ្វីដែលយើងអាចធ្វើបាន - យើងចាំបាច់ត្រូវយកបទពិសោធន៍ទាំងនេះមកប្រើ ដើម្បីធ្វើការងារឱ្យបានកាន់តែច្រើនថែមទៀត។



# សេចក្តីសង្ខេបនៃរបាយការណ៍ពិនិត្យតាមដានសកលលើការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ ២០១៥

នៅក្នុងវេទិកាអប់រំពិភពលោក នៅទីក្រុងដាកា ប្រទេសសេណេហ្កាល់ ដែលរៀបចំឡើងកាលពីឆ្នាំ ២០០០ រដ្ឋាភិបាលមកពី ១៦៤ ប្រទេស រួមនឹងតំណាងក្រុមនៅថ្នាក់តំបន់ អង្គការអន្តរជាតិ ទីភ្នាក់ងារអ្នកផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល បានអនុម័តលើក្របខ័ណ្ឌសកម្មភាពមួយ ដើម្បីសម្រេចឱ្យបាននូវការប្តេជ្ញាចិត្តផ្តល់ការអប់រំសម្រាប់ទាំងអស់គ្នា។ ក្របខ័ណ្ឌដាកានេះ មានគោលដៅចំនួន ៦ និងចំណុចដៅពាក់ព័ន្ធដែលត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ ២០១៥ និងយុទ្ធសាស្ត្រចំនួន ១២ ដែលអ្នកពាក់ព័ន្ធទាំងអស់ត្រូវចូលរួមចំណែកសម្រេច។

របាយការណ៍ពិនិត្យតាមដានសកលលើការអប់រំសម្រាប់ទាំងអស់គ្នានេះ ធ្វើការពិនិត្យតាមដានស្ទើរតែរាល់ឆ្នាំលើវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ចំនួនពីរដែលពាក់ព័ន្ធនឹងការអប់រំ។ របាយការណ៍ពិនិត្យតាមដានសកល ឆ្នាំ ២០១៥ នេះ ធ្វើការវាយតម្លៃពេញលេញលើវឌ្ឍនភាព ចាប់តាំងពីឆ្នាំ ២០០០ រហូតដល់កាលបរិច្ឆេទគោលដៅ ដើម្បីសម្រេចគោលដៅនៃក្របខ័ណ្ឌដាកា។ របាយការណ៍នេះធ្វើការបូកសរុប ដើម្បីឱ្យដឹងថាតើពិភពលោកទាំងមូល បានសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នាដែរឬទេ និងថាតើអ្នកពាក់ព័ន្ធនានាបានគោរពទៅតាមអ្វីដែលខ្លួនបានសន្យាដែរឬទេ។ របាយការណ៍នេះពន្យល់ពីកត្តាផ្សេងៗ ដែលអាចកំណត់ពីល្បឿននៃវឌ្ឍនភាពនេះ។ ចុងក្រោយ របាយការណ៍នេះកំណត់ពីមេរៀនសំខាន់ៗ សម្រាប់ផ្តល់ជាព័ត៌មានដល់ការរៀបចំរបៀបវារៈអប់រំសកល ក្រោយឆ្នាំ ២០១៥។

មានកុមារជាងពីរភាគបីបានចុះឈ្មោះចូលរៀនក្នុងសាលាបឋមសិក្សានៅក្នុងឆ្នាំ ២០១២ ច្រើនជាងចំនួនកុមារដែលបានចុះឈ្មោះនៅក្នុងឆ្នាំ ១៩៩៩

## ការបូកសរុបវឌ្ឍនភាពឆ្ពោះទៅសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា

### គោលដៅទី ១ - ការគាំពារ និងអប់រំកុមារតូច

ពង្រីក និងកែលំអការគាំពារ និងអប់រំកុមារតូចគ្រប់ជ្រុងជ្រោយ ជាពិសេស សម្រាប់កុមារងាយរងគ្រោះ និងជួបការលំបាកជាងគេ

- បើទោះបីជាមានការថយចុះនូវអត្រាមរណភាពកុមារជិត ៥០% ក៏ដោយ នៅក្នុងឆ្នាំ ២០១៣ មានកុមារអាយុក្រោម ៥ ឆ្នាំ ចំនួន ៦,៣ លាននាក់ ស្លាប់ ដោយសារមូលហេតុ ដែលអាចបង្ការបានភាគច្រើន។
- មានការសម្រេចបាននូវវឌ្ឍនភាពយ៉ាងច្រើន ខាងការបង្កើនអាហារូបត្ថម្ភកុមារ។ តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងសកលលោកទាំងមូល ក្នុងចំណោមកុមារ ៤ នាក់ មានកុមារ ១ នាក់ ដែលមានកម្ពស់ទាបបើធៀបជាមួយនឹងអាយុរបស់ខ្លួន ដែលនេះជាសញ្ញាបង្ហាញពីកង្វះរាំរ៉ៃនូវសារជាតិចិញ្ចឹមសំខាន់ៗ។
- នៅក្នុងឆ្នាំ ២០១២ ក្នុងសកលលោកទាំងមូល មានកុមារ ១៨៤ លាននាក់ ដែលចូលរៀននៅកម្រិតមត្តេយ្យសិក្សា ជាការកើនឡើងជិត ២ ភាគ ៣ ចាប់តាំងពីឆ្នាំ ១៩៩៩ មក។

### គោលដៅទី ២ - សកលកម្មនៃការអប់រំបឋមសិក្សា

ធានាថាត្រឹមឆ្នាំ២០១៥កុមារគ្រប់រូបជាពិសេសកុមារាកុមារស្ថិតក្នុងស្ថានភាពលំបាកនិងកុមារជនជាតិភាគតិចអាចទទួលបាន និងបញ្ចប់ការអប់រំបឋមសិក្សាមិនគិតថ្លៃ និងតម្រូវដោយច្បាប់ ប្រកបដោយគុណភាពល្អ។

- អត្រាពិតនៃការការសិក្សានៅបឋមសិក្សាមានកម្រិត ៨៤% នៅក្នុងឆ្នាំ ១៩៩៩ និងត្រូវបានប៉ាន់ប្រមាណថានឹងកើនឡើង ដល់ ៩៣% នៅក្នុងឆ្នាំ ២០១៥។
- អត្រាពិតនៃការសិក្សាមានការកើនឡើងគួរឱ្យកត់សម្គាល់ ពោលគឺកើនឡើងយ៉ាងហោចណាស់ ២០ ភាគរយ

ចំណុច ចាប់ពីឆ្នាំ ១៩៩៩ ដល់ ២០១២ នៅក្នុង ១៧ ប្រទេស ដែលក្នុងនោះមាន ១១ ប្រទេស ស្ថិតនៅអាហ្វ្រិចសាប់សាហារ៉ា។

- ខណៈពេលដែលមានការបង្ហាញយ៉ាងច្បាស់ពីការកើនឡើងមួយចំនួននូវអត្រានៃការសិក្សា ក្នុងឆ្នាំ ២០១២ មានកុមារជិត ៥៨ លាននាក់ នៅក្រៅសាលា ហើយភាពជឿនលឿន ក្នុងការកាត់បន្ថយចំនួននេះនៅជាប់គាំង។

ត្រឹមឆ្នាំ ២០១៥ ក្នុងចំណោមកុមារ ៦ នាក់ នៅប្រទេសដែលមានចំណូលទាបនិងមធ្យម មានកុមារ ១ នាក់ ដែលនឹងមិនបានរៀនចប់បឋមសិក្សា

**រូបភាពទី ១ ៖ ត្រឹមឆ្នាំ ២០១៥ កុមាររាប់លាននាក់ នៅតែនៅក្រៅសាលា**
**កុមារអាយុចូលរៀននៅបឋមសិក្សា ដែលនៅក្រៅសាលា ក្នុងពិភពលោកទាំងមូល និងតាម តំបន់មួយចំនួន ១៩៩០-២០១២ និង ២០១៥ (ចំណោល)**




ប្រភព ៖ មូលដ្ឋានទិន្នន័យរបស់ UIS

- បើទោះបីជាមានការសម្រេចបាននូវវឌ្ឍនភាពខាងការចូលរៀនក៏ដោយ ការបោះបង់ចោលការសិក្សា នៅតែជាបញ្ហាដដែល ៖ ក្នុង ៣២ ប្រទេស ភាគច្រើននៅអាហ្វ្រិចសាប់សាហារ៉ា មានកុមារដែលបានចូលរៀនហើយយ៉ាងហោចណាស់ ២០% នឹងមិនបានរៀនដល់ថ្នាក់ចុងក្រោយឡើយ។
- ត្រឹមឆ្នាំ ២០១៥ ដែលជាកាលបរិច្ឆេទកំណត់ ក្នុងចំណោមកុមារ ៦ នាក់ នៅប្រទេសដែលមានចំណូលទាបនិងមធ្យមមានកុមារ១នាក់ដែលនឹងមិនបានរៀនចប់បឋមសិក្សា។

## គោលដៅទី ៣ - ជំនាញសម្រាប់យុវជន និងមនុស្សពេញវ័យ

ធានាឱ្យមានការឆ្លើយតបចំពោះតម្រូវការរៀនសូត្ររបស់យុវជន និងមនុស្សពេញវ័យទាំងអស់ តាមរយៈការចូលរួមក្នុងកម្មវិធីរៀនសូត្រ និងកម្មវិធីបំណិនជីវិតប្រកបដោយសមធម៌

- ឆ្លុះបញ្ចាំងលើការកើនឡើងនូវអត្រាឆ្លងភូមិសិក្សា និងអត្រាគង់វង្ស អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិមានការកើនឡើងពី ៧១% នៅក្នុងឆ្នាំ ១៩៩៩ ដល់ ៨៥% នៅក្នុងឆ្នាំ ២០១២។ ការចូលរួមក្នុងការអប់រំមធ្យមសិក្សាបឋមភូមិ មានការកើនឡើងយ៉ាងឆាប់រហ័ស ចាប់តាំងពីឆ្នាំ ១៩៩៩ មក។ នៅក្នុងប្រទេសអាហ្វហ្គានីស្ថាន អេក្វាឌ័រ ម៉ាលី និងម៉ារ៉ុក អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិកើនឡើងយ៉ាងហោចណាស់ ២៥ ភាគរយចំណុច។

**រូបភាពទី ២ ៖ ពិភពលោកនៅឆ្ងាយពីការសម្រេចតាមចំណុចដៅអក្ខរកម្ម**

ក. អត្រាអក្ខរកម្មមនុស្សពេញវ័យ ក្នុងពិភពលោក និងតំបន់មួយចំនួន ឆ្នាំ ១៩៩០ ២០០០ ២០១០ និង ២០១៥ (ចំណោល)




ខ. អត្រាអក្ខរកម្មយុវជន ក្នុងពិភពលោក និងតំបន់មួយចំនួន ឆ្នាំ ១៩៩០ ២០០០ ២០១០ និង ២០១៥ (ចំណោល)




*សម្គាល់* ៖ ទិន្នន័យអក្ខរកម្មពុំត្រូវបានគេប្រមូលជារៀងរាល់ឆ្នាំឡើយ។ ដូច្នេះ ទិន្នន័យនៅថ្នាក់តំបន់ និងសកល សំដៅលើទិន្នន័យក្នុងទស្សវត្សរ៍ ដែលគ្របដណ្តប់ដោយជំរឿន។ តួលេខឆ្នាំ ១៩៩០ សំដៅលើទិន្នន័យពីទស្សវត្សរ៍ជំរឿន ១៩៨៥-១៩៩៥ ឆ្នាំ ២០០០ សំដៅលើទិន្នន័យពី ទស្សវត្សរ៍ជំរឿន ១៩៩៥-២០០៤ ឆ្នាំ ២០១០ សំដៅលើទិន្នន័យពីទស្សវត្សរ៍ជំរឿន ២០០៥-២០១២។
ប្រភព ៖ មូលដ្ឋានទិន្នន័យ UIS

- វិសមភាពនៅតែបន្តមាន នៅក្នុងការឆ្លងភូមិសិក្សាពីបឋមសិក្សា នៅមធ្យមសិក្សា។ ឧទាហរណ៍ នៅក្នុងប្រទេសហ្វីលីពីន មានកុមារ រៀនចប់បឋមសិក្សាមកពីគ្រួសារក្រីក្រជាង គេត្រឹមតែ ៦៩% ប៉ុណ្ណោះ ដែលបន្តទៅរៀននៅមធ្យមសិក្សាបឋមភូមិ បើធៀបជាមួយ នឹង ៩៤% នៃកុមារមកពីគ្រួសារមានជីវភាពធូរជាជាងគេ។
- ក្នុងចំណោមប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមចំនួន ៩៤ ដែលមានព័ត៌មាន ប្រទេសភាគច្រើនបានផ្តល់ការអប់រំមធ្យមសិក្សាបឋមភូមិដោយមិនគិតថ្លៃ ចាប់តាំងពីឆ្នាំ១៩៩៩មកដោយមានការកំណត់ក្នុងច្បាប់។ក្នុងចំណោមប្រទេសទាំងនេះ មាន ៦៦ ប្រទេស ផ្តល់ការធានាបែបនេះ តាមរយៈរដ្ឋធម្មនុញ្ញរបស់ខ្លួន និង ២៨ ប្រទេស បានអនុម័តវិធានការច្បាប់ផ្សេងទៀត។ ត្រឹមឆ្នាំ ២០១៥ មានប្រជាជាតិតិចតួចប៉ុណ្ណោះ ដែលគិតថ្លៃសម្រាប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ដែលក្នុងនោះមានដូចជា ប្រទេស បូតស្វាណា ហ្គីនី ប៉ាពូញូហ្គីនី អាហ្វ្រិចខាងត្បូង និងសាធារណរដ្ឋតង់ហ្សានី។

មានប្រទេសជិតពីរភាគបីនឹងសម្រេចបានយុគភាពយេនឌ័រនៅកម្រិតបឋមសិក្សាត្រឹមឆ្នាំ ២០១៥

## គោលដៅទី ៤ - អក្ខរកម្មមនុស្សពេញវ័យ

សម្រេចឱ្យបាននូវការកែលំអកម្រិតអក្ខរកម្មមនុស្សពេញវ័យ ៥០ ភាគរយ ត្រឹមឆ្នាំ ២០១៥ ជាពិសេសសម្រាប់ស្ត្រីនិងការទទួលបានការអប់រំថ្នាក់មូលដ្ឋាននិងការអប់រំបន្តប្រកបដោយសមធម៌សម្រាប់មនុស្សពេញវ័យទាំងអស់

- មានមនុស្សពេញវ័យមិនចេះអក្សរប្រមាណជា ៧៨១ លាននាក់។ អត្រាអនក្ខរកម្មមានការថយចុះតិចតួច ពី ១៨% នៅក្នុងឆ្នាំ ២០០០ មកប្រមាណជា ១៤% នៅក្នុងឆ្នាំ ២០១៥ ដែលមានន័យថា ចំណុចដៅទីក្រុងដាកា ដែលចង់កាត់បន្ថយអនក្ខរកម្មឱ្យនៅពាក់កណ្តាល មិនទាន់បានសម្រេចនៅឡើយ។

- ក្នុងចំណោម ៧៣ ប្រទេស ដែលមានអត្រាអក្ខរកម្មទាបជាង ៩៥% នៅក្នុងឆ្នាំ ២០០០ មានតែ ១៧ ប្រទេសប៉ុណ្ណោះ ដែលបានកាត់បន្ថយអត្រាអនក្ខរកម្មរបស់ខ្លួនពាក់កណ្តាល ត្រឹមឆ្នាំ ២០១៥
- មានការសម្រេចបាននូវវឌ្ឍនភាព ដើម្បីឈានទៅសម្រេចយុគភាពយេនឌ័រក្នុងអក្ខរកម្ម ប៉ុន្តែវឌ្ឍនភាពនេះនៅមិនទាន់គ្រប់គ្រាន់ឡើយ។ ប្រទេសទាំង ៤៣ ដែលរៀងរាល់បុរស ១០០ នាក់ មានស្ត្រីតិចជាង ៩០ នាក់ ចេះអក្សរ នៅក្នុងឆ្នាំ ២០០០ កំពុងស្ថិតលើផ្លូវទៅសម្រេចយុគភាព ប៉ុន្តែពុំមានប្រទេសណាមួយនឹងសម្រេចយុគភាពនេះ នៅឆ្នាំ ២០១៥ ឡើយ។

កុមារ ៣៤ លាននាក់ ច្រើនជាងមុន បាន ទៅរៀននៅសាលា ជាលើកទី ១ ដែល កុមារទាំងនេះនឹង មិនបានទៅរៀន បែបនេះឡើយ ប្រសិនបើពុំ មានគោលដៅ អប់រំសម្រាប់ ទាំងអស់គ្នានោះ

## គោលដៅទី ៥ - សមភាពយេនឌ័រ

លុបបំបាត់គម្លាតយេនឌ័រ នៅបឋមសិក្សា និងមធ្យមសិក្សា ត្រឹមឆ្នាំ ២០០៥ និងសម្រេចឱ្យបាននូវសមភាពយេនឌ័រ ក្នុងការអប់រំ ត្រឹមឆ្នាំ ២០១៥ ដោយផ្តោតការយកចិត្តទុកដាក់លើការធានាឱ្យស្ត្រីអាចមានលទ្ធភាពពេញលេញ និងស្មើភាពគ្នាក្នុងការទទួលបាន និងសម្រេចលទ្ធផលក្នុងការអប់រំថ្នាក់មូលដ្ឋាន ប្រកបដោយគុណភាពល្អ។

- នៅកម្រិតបឋមសិក្សា គេរំពឹងថា ៦៩% នៃប្រទេស ដែលមានទិន្នន័យ នឹងសម្រេចបាននូវយុគភាពយេនឌ័រត្រឹមឆ្នាំ ២០១៥។ វឌ្ឍនភាព មានភាពយឺតយ៉ាវ នៅក្នុងការអប់រំកម្រិតមធ្យមសិក្សា ដោយប្រទេស ៤៨% ត្រូវបានគេព្យាករថា នឹងសម្រេចយុគភាពយេនឌ័រ នៅក្នុងឆ្នាំ ២០១៥។
- មានការសម្រេចបាននូវវឌ្ឍនភាព នៅក្នុងការដោះស្រាយបញ្ហាគម្លាតយេនឌ័រធ្ងន់ធ្ងរ។ ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១២ ចំនួនប្រទេស ដែលមានក្មេងស្រីតិចជាង ៩០ នាក់ បានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា សម្រាប់រៀងរាល់ក្មេងប្រុស ១០០ នាក់ បានថយចុះ ពី ៣៣ នាក់ មក ១៦ នាក់។
- ក្នុងចំណោមកុមារក្រៅសាលា មានក្មេងស្រី ច្រើនជាងក្មេងប្រុស ដែលទំនងជាមិនដែលបានចុះឈ្មោះចូលរៀននៅសាលាទាល់តែសោះ (៤៨% ធៀបនឹង ៣៧%) ខណៈពេលដែលមានក្មេងប្រុសច្រើនជាងក្មេងស្រី ដែលបោះបង់ចោលការសិក្សា (២៦% ធៀបនឹង ២០%)។ ក្រោយពេលបានចុះឈ្មោះចូលរៀនហើយ ក្មេងស្រីច្រើនតែរៀនដល់ថ្នាក់លើៗ។
- នៅអាហ្វ្រិចសាប់សាហារ៉ា ក្មេងស្រីដែលមានជីវភាពក្រីក្រជាងគេ នៅតែមិនដែលបានចូលរៀននៅសាលាបឋមសិក្សា ក្នុងកម្រិតខ្ពស់បំផុត។ ក្នុងឆ្នាំ ២០១០ នៅប្រទេសហ្គីនី និងនីហ្សេក្មេងស្រីជាង៧០%នៃក្មេងស្រីដែលក្រីក្របំផុតមិនដែលបានទៅរៀននៅសាលាបឋមសិក្សាឡើយ បើធៀបជាមួយនឹងតួលេខតិចជាង ២០% នៃក្មេងប្រុសមកពីគ្រួសារមានជីវភាពធូរធាជាងគេ។

## គោលដៅទី ៦ - គុណភាពនៃការអប់រំ

កែលំអគ្រប់ទិដ្ឋភាពទាំងអស់នៃគុណភាពនៃការអប់រំ និងធានាឱ្យមានឧត្តមភាពសម្រាប់ទាំងអស់គ្នា ដើម្បីឱ្យមានការសម្រេចបាននូវលទ្ធផលសិក្សា ដែលមានការទទួលស្គាល់ និងអាចវាស់វែងបាន ដោយមនុស្សទាំងអស់គ្នា ជាពិសេស ខាងអក្ខរកម្ម ចំណេះដឹងអំពីលេខនពន្ធ និងបំណិនជីវិតសំខាន់ៗ

- ក្នុងចំណោមប្រទេសចំនួន ៨៦ ប្រទេសដែលមានទិន្នន័យ មានប្រទេស ៨៣% ដែលមានផលធៀបសិស្ស/គ្រូ មានការថយចុះនៅកម្រិតបឋមសិក្សា។ ប៉ុន្តែ នៅក្នុងមួយភាគបីនៃប្រទេសដែលមានទិន្នន័យ មានគ្រូបឋមសិក្សាតិចជាង ៧៥% ដែលទទួលបានការបណ្តុះបណ្តាលដល់កម្រិតស្តង់ដាជាតិ។
- នៅកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងចំណោម ១០៥ ប្រទេសដែលមានទិន្នន័យ មាន ៨៧ ប្រទេស មានផលធៀបសិស្ស/គ្រូ ក្រោម ៣០ ៖ ១។
- ត្រឹមឆ្នាំ ១៩៩០ ការវាយតម្លៃលើការសិក្សាចំនួន ១២ លើក ត្រូវបានធ្វើឡើង ទៅតាមស្តង់ដាជាតិ ប៉ុន្តែគិតត្រឹមឆ្នាំ ២០១៣ ចំនួននេះ មានការកើនឡើងដល់ ១០១ លើក។

**រូបភាពទី ៣ ៖ ការផ្តោតការយកចិត្តទុកដាក់លើការវាយតម្លៃលើការរៀនសូត្រមានការកើនឡើង នៅគ្រប់ប្រទេសទាំងអស់ចាប់តាំងពីឆ្នាំ ២០០០ មក**

ភាគរយនៃប្រទេស ដែលបានធ្វើការវាយតម្លៃថ្នាក់ជាតិលើការរៀនសូត្រយ៉ាងហោចណាស់ម្តង បែងចែកតាមតំបន់ ១៩៩០-១៩៩៩, ២០០០-២០០៦ និង ២០០៧-២០១៣




*ប្រភព* ៖ របាយការណ៍ពិនិត្យតាមដានសកលលើការអប់រំសម្រាប់ទាំងអស់គ្នា (២០១៤) ផ្អែកទៅតាមទិន្នន័យឧបសម្ព័ន្ធស្តីពីការវាយតម្លៃថ្នាក់ជាតិលើការរៀនសូត្រ

### ប្រអប់ទី ១ ៖ ក្រោយក្របខ័ណ្ឌដាកា តើវឌ្ឍនភាពមានល្បឿនលឿនជាងមុនឬ?

វឌ្ឍនភាពនៃអត្រារួមនៃការសិក្សានៅកម្រិតមត្តេយ្យសិក្សា មានការកើនឡើង។ ក្នុងចំណោម ៩០ ប្រទេស ដែលមានទិន្នន័យ ប្រសិនបើការចុះឈ្មោះចូលរៀនមានការកើនឡើង ក្នុងអត្រាដូចគ្នានឹងក្នុងទសវត្សរ៍ ១៩៩០ អត្រានៃការសិក្សាជាមធ្យមនៅមត្តេយ្យសិក្សានឹងមានត្រឹមតែ ៤០% ប៉ុណ្ណោះ នៅក្នុងឆ្នាំ ២០១៥។ ប៉ុន្តែ គេរំពឹងថា អត្រានេះនឹងកើនដល់ ៥៧%។

វឌ្ឍនភាពឆ្ពោះទៅរកសកលកម្មនៃការអប់រំកម្រិតបឋមសិក្សា មានកម្រិតទាបជាង។ ក្នុងចំណោមប្រទេសចំនួន ៥២ ដែលមានទិន្នន័យអំពីអត្រា ពិតនៃការសិក្សានៅបឋមសិក្សា ប្រសិនបើការចុះឈ្មោះចូលរៀនមានការកើនឡើង ក្នុងអត្រាដូចគ្នានឹងក្នុងទសវត្សរ៍ ១៩៩០ អត្រានៃការសិក្សា ជាមធ្យមនៅបឋមសិក្សានឹងមានត្រឹមតែ ៨២% ប៉ុណ្ណោះ នៅក្នុងឆ្នាំ ២០១៥។ ប៉ុន្តែ គេរំពឹងថា អត្រានេះនឹងកើនដល់ ៩១%។

ភស្តុតាងដែលបានពីប្រទេសចំនួន ៧០ ពាក់ព័ន្ធនឹងអត្រាគង់វង្ស រហូតដល់កម្រិតថ្នាក់ចុងក្រោយនៅបឋមសិក្សា បង្ហាញថា មានការកើនឡើងនូវការចុះឈ្មោះចូលរៀនមួយចំនួន ទន្ទឹមគ្នានឹងការថមថយនូវវឌ្ឍនភាពនៃអត្រានេះ។ អត្រាគង់វង្សមានការកើនឡើងនៅក្នុងប្រទេសចំនួន ២៣ ប៉ុន្តែមានការថយចុះ នៅក្នុងប្រទេសចំនួន ៣៧។ អត្រាគង់វង្សកម្រិតសកល ត្រូវបានគេព្យាករថានឹងមិនមានលើសពី ៧៦% នៅក្នុងឆ្នាំ ២០១៥ ឡើយ ខណៈពេលដែលបើគិតជាមួយនឹងអត្រានៃការសិក្សានៅទសវត្សរ៍ ១៩៩០ អត្រាគង់វង្សនឹងកើនឡើងដល់ ៨០%។

មានការប៉ាន់ប្រមាណថា មានកុមារដែលកើតមុនឆ្នាំ ២០១០ ចំនួន ៣៤ លាននាក់ថែមទៀត ដែលនឹងអាចទៅរៀននៅសាលារៀន ជាលើកដំបូង ត្រឹមឆ្នាំ ២០១៥ បើធៀបជាមួយនឹងអ្វីដែលនឹងកើតឡើង ប្រសិនបើនិន្នាការមុននៅតែបន្ត។ គេប៉ាន់ប្រមាណផងដែរថា មានកុមារកើតមុនឆ្នាំ ២០០៥ ចំនួន ២០ លាននាក់ទៀត នឹងរៀនចប់បឋមសិក្សា បើធៀបជាមួយនឹងការធ្វើចំណោលដោយយកនិន្នាការមុនក្របខ័ណ្ឌដាកាធ្វើជាគោល។

វឌ្ឍនភាពក្នុងការឈានទៅសម្រេចយុគភាពយេនឌ័រ ហាក់បីដូចជាមានការកើនឡើងលឿននៅកម្រិតបឋមសិក្សា បើទោះបីជាយុគភាពយេនឌ័រ នេះនៅតែអាចសម្រេចបាននៅកម្រិតសកលសូម្បីតែបើនិន្នាការមុនក្របខ័ណ្ឌដាកានៅតែបន្តមាន។

ការអះអាង នៅក្នុងក្របខ័ណ្ឌដាកា ដែលថា ការសម្រេចនូវការអប់រំសម្រាប់ទាំងអស់គ្នាត្រឹមឆ្នាំ ២០១៥ គឺជា "គោលដៅដែលមានភាពប្រាកដនិយម និងអាចសម្រេចទៅបាន" ប្រហែលជាការអះអាងដែលបំប៉ោងហួសពីការពិត សូម្បីតែមានការកាត់បន្ថយឱ្យនៅត្រឹមចំណុចដៅដែលមានកម្រិតទាប ដូចជា ចំណុចដៅសកលកម្មនៃការអប់រំបឋមសិក្សាក៏ដោយ។ តែទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលចំណុចដៅសកលនៅក្នុងក្របខ័ណ្ឌនេះខ្លួនឯង នៅមិនទាន់អាចសម្រេចបានកន្លងមក មានការសម្រេចនូវវឌ្ឍនភាពតិចតួច ដែលនៅតែមានភាពប្រសើរ បើធៀបជាមួយនឹងអ្វីដែលសម្រេចបានកន្លងមក។

មានយុទ្ធសាស្ត្រចំនួន១២ត្រូវបានស្នើឡើងនៅក្នុងក្របខ័ណ្ឌដាកា ដើម្បីសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា

# ការពន្យល់ពីវឌ្ឍនភាពឆ្ពោះទៅសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា ៖ ការវាយតម្លៃលើតួនាទីរបស់ចលនាអប់រំសម្រាប់ទាំងអស់គ្នា នៅកម្រិតសកល

ការសន្យាជាសកល ដែលត្រូវបានធ្វើឡើង នៅក្នុងក្របខ័ណ្ឌដាកា ត្រូវបានសម្រេចតែមួយផ្នែកប៉ុណ្ណោះ។ ប៉ុន្តែ យន្តការដែលបានគ្រោងទុកមួយចំនួន ដំណើរការទៅបានល្អ ដែលនាំឱ្យស្ថានភាពនៃការអប់រំមានការរីកចម្រើនទៅមុខទៀត ចាប់តាំងពីឆ្នាំ ២០០០ មក។ នេះគឺជាប្រភពនៃសុទិដ្ឋិនិយម សម្រាប់ក្របខ័ណ្ឌអប់រំសកល ក្រោយឆ្នាំ ២០១៥។

ក្របខ័ណ្ឌសកម្មភាពដាកា លើកស្នើនូវអន្តរាគមន៍សកលចំនួន ៣ ប្រភេទ ដើម្បីគាំទ្រដល់បណ្តាប្រទេសនានា ៖

- យន្តការសម្របសម្រួល ដែលក្នុងនោះយន្តការមួយចំនួនមានរួចទៅហើយ។ យន្តការផ្សេងទៀតត្រូវបានដាក់ចេញជាលើកដំបូង នៅក្នុងក្របខ័ណ្ឌដាកានេះ និងត្រូវបានផ្លាស់ប្តូរក្រោយមកទៀត។
- យុទ្ធនាការ ដែលរៀបចំឡើងសម្រាប់សមាសភាគពិសេសៗនៃការអប់រំសម្រាប់ទាំងអស់គ្នា ដូចជា អក្ខរកម្មមនុស្សពេញវ័យ ឬសម្រាប់ដោះស្រាយបញ្ហាប្រឈមពិសេស ដូចជា ស្ថានភាពជម្លោះ ជាដើម។
- គំនិតផ្តួចផ្តើម ត្រូវបានបង្កើតឡើងដោយផ្អែកលើក្របខ័ណ្ឌដាកា ដែលក្នុងនោះគំនិតផ្តួចផ្តើមមួយចំនួន ត្រូវបានបញ្ជាក់នៅក្នុងក្របខ័ណ្ឌដាកា ខណៈពេលគំនិតផ្តួចផ្តើមផ្សេងទៀតត្រូវបានបង្កើតឡើងក្រោយមកទៀត។

ការអប់រំ នៅក្នុងស្ថានភាពអាសន្ន បានទទួលការចាប់អារម្មណ៍ច្រើនជាងមុនឆ្ងាយចាប់តាំងពីឆ្នាំ ២០០០ មក ដោយសារតែកិច្ចខិតខំប្រឹងប្រែងតស៊ូមតិយ៉ាងមុតមាំ។

គេសង្ឃឹមថា ប្រសិនបើអនុវត្តបានជោគជ័យ អន្តរាគមន៍ទាំងនេះនឹងនាំឱ្យមានការសម្រេចនូវលទ្ធផលរយៈពេលមធ្យមចំនួន ៥ ដែលនឹងជួយពន្លឿនការសម្រេចគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា។ អន្តរាគមន៍ទាំងនេះនឹង ៖

- គូសបញ្ជាក់សាជាថ្មី និងធានានិរន្តរភាពការប្តេជ្ញាចិត្តនយោបាយចំពោះការអប់រំសម្រាប់ទាំងអស់គ្នា
- ជួយឱ្យមានការផ្សព្វផ្សាយ និងប្រើប្រាស់ចំណេះដឹង ភស្តុតាង និងជំនាញច្រើនប្រភេទ
- មានឥទ្ធិពល និងពង្រឹងគោលនយោបាយជាតិស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា និងការអនុវត្តគោលនយោបាយនេះ
- កៀងគរធនធានហិរញ្ញវត្ថុ ដើម្បីសម្រេចនូវការអប់រំសម្រាប់ទាំងអស់គ្នា យ៉ាងមានប្រសិទ្ធភាព
- រៀបចំឱ្យមានការពិនិត្យតាមដាន និងការរាយការណ៍ដោយឯករាជ្យអំពីវឌ្ឍនភាពឈានទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា

ក្របខ័ណ្ឌដាកាលើកស្នើនូវយុទ្ធសាស្ត្រចំនួន ១២ ដើម្បីសម្រេចលទ្ធផលទាំងនេះ។ តើដៃគូនានាដែលធ្វើការងារពាក់ព័ន្ធនឹងការអប់រំសម្រាប់ទាំងអស់គ្នាបានអនុវត្តយុទ្ធសាស្ត្រទាំងនេះរួមគ្នានៅកម្រិតសកល បានល្អកម្រិតណា?

## យុទ្ធសាស្ត្រទី ១ ៖ ការវិនិយោគឱ្យបានច្រើនលើការអប់រំថ្នាក់មូលដ្ឋាន

ប្រទេសដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប បានធ្វើការវិភាជន៍ធនធានរបស់ខ្លួនក្នុងភាគរយកាន់តែខ្ពស់ជាងមុននៃផលិតផលជាតិសរុបរបស់ខ្លួន សម្រាប់វិស័យអប់រំ ចាប់តាំងពីឆ្នាំ ១៩៩៩ មក ហើយជំនួយសម្រាប់វិស័យអប់រំ មានការកើនឡើងទ្វេដង ក្នុងស្ថានភាពជាក់ស្តែង។ ប៉ុន្តែ មានភស្តុតាងតិចតួច ដែលបង្ហាញថា អន្តរាគមន៍អប់រំសម្រាប់ទាំងអស់គ្នា នៅថ្នាក់សកល ដូចជា គំនិតផ្តួចផ្តើមពន្លឿនការអប់រំសម្រាប់ទាំងអស់គ្នា (EFA Fast Track Initiative) ដែលក្រោយមក ត្រូវបានប្តូរជាភាពជាដៃគូសកលសម្រាប់ការអប់រំបាន នាំឱ្យមានការបង្កើនចំណាយថ្នាក់ជាតិលើការអប់រំសាធារណៈ ឬជំនួយសម្រាប់វិស័យអប់រំ។

## យុទ្ធសាស្ត្រទី ២ ៖ គោលនយោបាយស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា នៅក្នុងក្របខ័ណ្ឌវិស័យរួម ដែលមានទំនាក់ទំនងជាមួយនឹងការកាត់បន្ថយភាពក្រីក្រ

ក្របខ័ណ្ឌដាកា បញ្ជាក់ថា គោលដៅអប់រំសម្រាប់ទាំងអស់គ្នានៅថ្នាក់ជាតិ ត្រូវតែជាឧបករណ៍ចម្បង សម្រាប់ប្រែក្លាយការប្តេជ្ញាចិត្តឱ្យទៅជាសកម្មភាពជាក់ស្តែង។ ការប្រៀបធៀបផែនការជាតិពីរជំនាន់ របស់ប្រទេសចំណូលទាប និងមធ្យមចំនួន ៣០ បានបង្ហាញថា គុណភាពនៃផែនការទាំងនោះមានការកើនឡើង។ ប៉ុន្តែ ផែនការដែលមើលទៅល្អលើក្រដាស អាចមានទំនាក់ទំនងតិចតួច ជាមួយនឹងតថភាពនៃដំណើរការ នយោបាយ និងប្រព័ន្ធអប់រំរបស់ប្រទេសទាំងនោះ។

មានការកែលំអយ៉ាងជាក់ច្បាស់មួយ ចាប់តាំងពីឆ្នាំ ២០០០ មក នៅក្នុងរបៀបដែលគោលដៅអប់រំសម្រាប់ទាំងអស់គ្នាត្រូវបានពិនិត្យតាមដាន។

## យុទ្ធសាស្ត្រទី ៣ ៖ ការចូលរួមរបស់សង្គមស៊ីវិល នៅក្នុងយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍការអប់រំ

ការកើនឡើងនូវការចូលរួមរបស់សង្គមស៊ីវិល គឺជាលក្ខណៈសំខាន់មួយនៃវិស័យអប់រំចាប់តាំងពីឆ្នាំ ២០០០ មក។ ប៉ុន្តែ ពេលខ្លះ ការគាំទ្រនេះទទួលបានជោគជ័យតិចតួចប៉ុណ្ណោះ នៅក្នុងការបង្កើតនូវសម្ព័ន្ធភាពរឹងមាំនៅថ្នាក់ជាតិ ដែលធ្វើការងារក្នុងវិស័យអប់រំ ដែលមានសមត្ថភាពនាំឱ្យមានការផ្លាស់ប្តូរជាដុំកំភួននេះ។

## យុទ្ធសាស្ត្រទី ៤ ៖ គណនេយ្យភាព នៅក្នុងអភិបាលកិច្ច និងការគ្រប់គ្រង

ការចូលរួមនៅថ្នាក់មូលដ្ឋាន និងវិមជ្ឈការ ត្រូវបានចាត់ទុកថាជាមធ្យោបាយសំខាន់ៗ ដើម្បីលើកកម្ពស់អភិបាលកិច្ចក្នុងការងារអប់រំ។ ជារួម ការជម្រុញឱ្យមានការចូលរួមនៅថ្នាក់មូលដ្ឋាន និងការធ្វើឱ្យសាលារៀនឆ្លើយតបចំពោះតម្រូវការរបស់សិស្ស មាតាបិតា និងសហគមន៍ នៅតែជាការលំបាក ជាពិសេស សម្រាប់គ្រួសារក្រីក្រ ដែលមានពេលវេលាតិចតួច សម្រាប់ចូលរួម។ នៅតាមប្រទេសក្រីក្រ ដែលសមត្ថភាពនៅទន់ខ្សោយ វិមជ្ឈការ និងស្វ័យភាពសាលារៀន ត្រូវបានគេរកឃើញថា បង្កជាការលំបាក ឬពុំមានឥទ្ធិពលលើលទ្ធផលសិក្សារបស់សិស្ស និងប្រព័ន្ធអប់រំឡើយ។

## យុទ្ធសាស្ត្រទី ៥ ៖ ការបំពេញតម្រូវការរបស់ប្រព័ន្ធអប់រំ ដែលរងផលប៉ះពាល់ដោយសារជម្លោះ និងអស្ថិរភាព

ជារួម បញ្ហាប្រឈមនៅក្នុងការផ្តល់សេវាអប់រំ នៅក្នុងស្ថានភាពអាសន្ន បានទទួលការយកចិត្តទុកដាក់ច្រើនជាងមុនឆ្ងាយ ចាប់តាំងពីឆ្នាំ ២០០០ មក។ ការរំលោភបំពានសិទ្ធិមនុស្សនៅក្នុងស្ថានភាពជម្លោះ កំពុងទទួលបានការចាប់អារម្មណ៍កាន់តែច្រើនឡើង។ ការតស៊ូមតិ បានជួយបន្តដាក់បញ្ហាអប់រំក្នុងស្ថានភាពជម្លោះ និងស្ថានភាពអាសន្ន ក្នុងរបៀបវារៈ។ នេះគឺដោយសារដៃគូនានាបានរួមចំណែកបំពេញ តាមការ ប្តេជ្ញាចិត្តពាក់ព័ន្ធ ដែលធ្វើឡើងនៅក្នុងក្របខ័ណ្ឌដាកា។

ការអប់រំ នៅក្នុងស្ថានភាពអាសន្ន បានទទួលការចាប់អារម្មណ៍ច្រើនជាងមុនឆ្ងាយ ចាប់តាំងពីឆ្នាំ ២០០០ មក ដោយសារតែកិច្ចខិតខំប្រឹងប្រែង តស៊ូមតិយ៉ាងមុតមាំ។

## យុទ្ធសាស្ត្រទី ៦ ៖ យុទ្ធសាស្ត្ររួម ដើម្បីសម្រេចសមភាពយេនឌ័រ

យន្តការសកល ដែលគេអាចមើលឃើញច្បាស់លាស់ជាងគេ ពាក់ព័ន្ធជាមួយនឹងសមភាពយេនឌ័រ គឺគំនិតផ្តួចផ្តើមអប់រំក្មេងស្រីរបស់សហប្រជាជាតិ (United Nations Girls' Education Initiative - UNGEI)។ ការវាយតម្លៃបានទទួលស្គាល់ការរួមចំណែករបស់គំនិតផ្តួចផ្តើមនេះ នៅក្នុងកិច្ចពិគ្រោះយោបល់គោលនយោបាយ និងការតស៊ូមតិនៅកម្រិតសកល បើទោះបីជាមិនសូវមាននៅកម្រិតតំបន់ក៏ដោយ។ នៅកម្រិត ប្រទេស UNGEI បានបំពេញនាទីជាតួអង្គរឹងមាំដ៏មានតម្លៃ តាមរយៈភាពជាដៃគូរឹងមាំនៅថ្នាក់ជាតិ។ ជារួម ដៃគូដែលធ្វើការងារខាងការអប់រំសម្រាប់ទាំងអស់គ្នា បានផ្តោតការយកចិត្តទុកដាក់គ្រប់គ្រាន់លើសមភាពយេនឌ័រ ដើម្បីរួមចំណែកចំពោះវឌ្ឍនភាពក្នុងការឈានទៅសម្រេចគោលដៅនេះ។

ចលនាអប់រំសម្រាប់ទាំងអស់គ្នា ទទួលរងផលប៉ះពាល់ នៅពេលដែលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ក្លាយជារបៀបវារៈអភិវឌ្ឍន៍ដែលគ្របលុបលើរបៀបវារៈផ្សេងទៀត

## យុទ្ធសាស្ត្រទី ៧ ៖ សកម្មភាព ដើម្បីប្រយុទ្ធប្រឆាំងនឹងមេរោគ និងជំងឺអេដស៍

នៅក្នុងឆ្នាំ ២០០០ ការឆ្លងរាលដាលជំងឺអេដស៍ បង្កការគំរាមកំហែងដល់មូលដ្ឋានគ្រឹះនៃប្រព័ន្ធអប់រំ នៅអាហ្វ្រិចភាគខាងត្បូង និងខាងកើត។ នៅក្នុងឆ្នាំ ២០១៥ ខណៈពេលដែលគេមិនទាន់ទទួលបានជោគជ័យក្នុងសមរភូមិនេះនៅឡើយ ស្ថានភាពអាក្រក់បំផុតត្រូវបានទប់ស្កាត់មិនឱ្យកើតមានឡើង។ គំនិតផ្តួចផ្តើមអប់រំ បានឆ្លើយតបចំពោះបញ្ហាប្រឈមមេរោគអេដស៍ យ៉ាងបន្ទាន់ និងបានរៀបចំឱ្យមានការអប់រំគ្រប់ជ្រុងជ្រោយអំពីផ្លូវភេទ។ ប្រទេសជាច្រើនបានចាត់វិធានការជាជំហានៗ ដើម្បីអនុវត្តអភិក្រមដែលមានលក្ខណៈទូលំទូលាយនេះ ដែលគួរចាត់ទុកថា កើតឡើងដោយសារកិច្ចខិតខំប្រឹងប្រែងសកលក្រោយក្របខ័ណ្ឌដាកា។

## យុទ្ធសាស្ត្រទី ៨ ៖ បរិយាកាសអប់រំប្រកបដោយសុវត្ថិភាព សុខភាព បញ្ចូលគ្នា និងមានធនធានប្រកបដោយសមធម៌

ក្របខ័ណ្ឌដាកា គូសបញ្ជាក់ពីរបៀបដែលគុណភាពនៃបរិយាកាសរៀនសូត្ររួមចំណែកសម្រេចគោលដៅ ពាក់ព័ន្ធជាមួយនឹងសមភាពយេនឌ័រ និងការអប់រំដែលមានគុណភាពល្អ។ ប៉ុន្តែការបែងចែកបញ្ហាជាក្រុម នៅក្នុងយុទ្ធសាស្ត្រនេះ ចាប់ពីគរុកោសល្យ រហូតដល់កិច្ចគាំពារសង្គម រហូតដល់ហេដ្ឋារចនាសម្ព័ន្ធ មានន័យថា យុទ្ធសាស្ត្រនេះមិនបានផ្តោតការយកចិត្តដាក់ឱ្យចំចំណុចឱ្យបានគ្រប់គ្រាន់។ ការងារ ដែលធ្វើឡើង នៅថ្នាក់សកល បានចូលរួមចំណែកតិចតួច ដើម្បីជួយដល់ប្រទេសនានា ក្នុងការបង្កើតនូវបរិយាកាសរៀនសូត្រដែលមានភាពល្អប្រសើរ។

## យុទ្ធសាស្ត្រទី ៩ ៖ ស្ថានភាព ទឹកចិត្ត និងវិជ្ជាជីវៈគ្រូបង្រៀន

ក្រុមការងារអន្តរជាតិខាងគ្រូបង្រៀន សម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៨ ដើម្បីសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងអន្តរជាតិ ដើម្បីបំពេញចំនួនគ្រូដែលនៅខ្វះ។ ការវាយតម្លៃបង្ហាញថា ក្រុមការងារនេះមានភាពពាក់ព័ន្ធ ប៉ុន្តែ គោលដៅរបស់ក្រុមការងារនេះគួរតែមានភាពពាក់ព័ន្ធឱ្យបានកាន់តែជិតស្និទ្ធជាមួយនឹងតម្រូវការរបស់ប្រទេស។ គណៈកម្មាធិការជំនាញចម្រុះ រវាងអង្គការពលកម្មអន្តរជាតិ និងអង្គការយូណេស្កូ ទទួលបន្ទុកការអនុវត្តអនុសាសន៍ ពាក់ព័ន្ធនឹងបុគ្គលិកបង្រៀន មិនត្រូវបានរកឃើញថាជាយន្តការរឹងមាំ ដែលនាំឱ្យមានការផ្លាស់ប្តូរនោះទេ។ ចាប់តាំងពីឆ្នាំ ២០០០ មក ការពិនិត្យតាមដានស្ថានភាពគ្រូ នៅមិនទាន់មានវឌ្ឍនភាពអ្វីឡើយ។

## យុទ្ធសាស្ត្រទី ១០ ៖ ការទាញប្រយោជន៍ពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

ក្របខ័ណ្ឌដាកា គូសបញ្ជាក់ពីសក្តានុពលនៃបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងការផ្តល់នូវការអប់រំសម្រាប់ទាំងអស់គ្នា។ មហិច្ឆតានេះត្រូវជួបនឹងការលំបាក ដោយសារតែវឌ្ឍនភាពយឺតយ៉ាវ ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ នៅតាមប្រទេសក្រីក្រ ការសាយភាយបច្ចេកវិទ្យានៅមានភាពយឺតយ៉ាវ និងការពុំមានការសម្របសម្រួលសកលធំដុំលើបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដែលពាក់ព័ន្ធនឹងការអប់រំ។

## យុទ្ធសាស្ត្រទី ១១ ៖ ការពិនិត្យតាមដានវឌ្ឍនភាពជាប្រព័ន្ធ

ក្របខ័ណ្ឌដាកា អំពាវនាវឱ្យមានស្ថិតិអប់រំដែលរឹងមាំ និងអាចជឿទុកចិត្តបាន។ ការវាយតម្លៃមួយ ទទួលស្គាល់ថា ការងាររបស់វិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូ (UIS) ថាមានតួនាទីយ៉ាងសំខាន់ សម្រាប់ការងារនេះ។ ចាប់តាំងពីឆ្នាំ ២០០០ មក ការកើនឡើងដ៏ច្រើននូវទិន្នន័យអង្កេតគ្រួសារ បានបង្កលក្ខណៈឱ្យគេអាចពិនិត្យតាមដានលើវិសមភាពបាន។ ទិន្នន័យអំពីចំណាយសម្រាប់ការអប់រំសាធារណៈ បន្តមិនមានពេញលេញ ប៉ុន្តែមានការរីកចម្រើនយ៉ាងសំខាន់ពាក់ព័ន្ធនឹងរបៀបដែលអ្នកផ្តល់ជំនួយធ្វើការរាយការណ៍ពីចំណាយនានា។ ការវាយតម្លៃចុងក្រោយបានរកឃើញថា របាយការណ៍ពិនិត្យតាមដានសកលនេះ "ត្រូវបានគេយល់យ៉ាងទូលំទូលាយថាជារបាយការណ៍ដែលមានគុណភាពខ្ពស់ ដែលមានមូលដ្ឋានលើការស្រាវជ្រាវ និងការវិភាគរឹងមាំ"។ ជារួម មានការកែលំអយ៉ាងជាក់ច្បាស់មួយ ចាប់តាំងពីឆ្នាំ ២០០០ មក នៅក្នុងរបៀបដែលគោលដៅអប់រំសម្រាប់ទាំងអស់គ្នាត្រូវបានពិនិត្យតាមដាន។

## យុទ្ធសាស្ត្រទី ១២ ៖ ប្រើប្រាស់យន្តការដែលមានស្រាប់

យុទ្ធសាស្ត្រចុងក្រោយនេះ គូសបញ្ជាក់ថា សកម្មភាពនានាគួរ "មានមូលដ្ឋានលើអង្គការបណ្តាញ និងគំនិតផ្តួចផ្តើមដែលមានស្រាប់"។ សំណួរសំខាន់មួយគឺថាតើយន្តការដែលមានស្រាប់អាចទាមទារគណនេយ្យភាពពីសហគមន៍អន្តរជាតិដែរឬទេ។ ច្បាស់ណាស់ យន្តការសម្របសម្រួលការអប់រំសម្រាប់ទាំងអស់គ្នានៅកម្រិតសកល មិនអាចបំពេញតួនាទីនេះបានឡើយ បើទោះបីជាការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល ដែលបង្កើតឡើង នៅក្នុងឆ្នាំ ២០០៦ អាចប្រើប្រាស់ ដើម្បីពិនិត្យឡើងវិញលើវឌ្ឍនភាពនៃការអប់រំសម្រាប់ទាំងអស់គ្នាក៏ដោយ។ គណនេយ្យភាព គឺជាអ្វីដែលនៅខ្វះចន្លោះនៅក្នុងវដ្តនៃការអប់រំសម្រាប់ទាំងអស់គ្នា ហើយនៅបន្តជា បញ្ហា ដែលត្រូវដោះស្រាយក្រោយឆ្នាំ ២០១៥។

### *ការសម្របសម្រួលការអប់រំសម្រាប់ទាំងអស់គ្នានៅកម្រិតសកល*

ការវិភាគលើថាតើដៃគូដែលធ្វើការងារអប់រំសម្រាប់ទាំងអស់គ្នា អនុវត្តយុទ្ធសាស្ត្រដាកាទាំងនេះបានល្អកម្រិតណា នៅកម្រិតសកល តម្រូវឱ្យមានការវាយតម្លៃរួមលើការសម្របសម្រួលរបស់ស្ថាប័ន។ ប៉ុន្តែ ប័ណ្ណរបាយការណ៍ពុំមានលក្ខណៈវិជ្ជមានឡើយ។ ជារួម យន្តការសម្របសម្រួល

ការអប់រំសម្រាប់ទាំងអស់គ្នាជាផ្លូវការ ដែលដឹកនាំដោយយូណេស្កូ មិនបានធានាឱ្យមានការប្តេជ្ញាចិត្តខាងនយោបាយបន្តជាប់រហូតឡើយ និងបានទទួលជោគជ័យតិចតួច នៅក្នុងការជម្រុញឱ្យមានការចូលរួមពីទីភ្នាក់ងារ និងអ្នកពាក់ព័ន្ធផ្សេងទៀត។ ការវាយតម្លៃ ដែលនឹងមាននាពេលខាងមុខលើយន្តការសម្របសម្រួលការអប់រំសម្រាប់ទាំងអស់គ្នាជាសកល ដែលធ្វើឡើងដោយសេវាត្រួតពិនិត្យផ្ទៃក្នុងរបស់យូណេស្កូ នឹងផ្តល់នូវពន្លឺជាច្រើនអំពីបញ្ហាទាំងនេះ។

ចលនាអប់រំសម្រាប់ទាំងអស់គ្នាទទួលរងផលប៉ះពាល់ នៅពេលដែលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ក្លាយជារបៀបវារៈអភិវឌ្ឍន៍ដែលគ្របលុបលើរបៀបវារៈផ្សេងទៀត

## *ការដាក់បញ្ចូលភស្តុតាងនានាបញ្ចូលគ្នា*

តើយុទ្ធសាស្ត្រទាំង ១២ នៅក្នុងក្របខ័ណ្ឌដាកានេះមានលក្ខណៈគ្រប់គ្រាន់ ដើម្បីរួមចំណែកសម្រេចលទ្ធផលរយៈពេលមធ្យមសំខាន់ៗ ទាំង ៥ ចេញពីរចនាសម្ព័ន្ធនៃការអប់រំសម្រាប់ទាំងអស់គ្នាប្រកបដោយប្រសិទ្ធភាពដែរឬទេ? នៅក្នុងការវាយតម្លៃថាតើការប្តេជ្ញាចិត្តនយោបាយចំពោះការអប់រំសម្រាប់ទាំងអស់គ្នា ត្រូវបានបញ្ជាក់សារជាថ្មី និងមាននិរន្តរភាព នៅក្នុងរយៈពេលទាំងមូលដែរឬទេ មានការបង្ហាញយ៉ាងច្បាស់ថា ចលនាអប់រំសម្រាប់ទាំងអស់គ្នាទទួលរងផលប៉ះពាល់ នៅពេលដែលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ក្លាយជារបៀបវារៈអភិវឌ្ឍន៍ដែលគ្របលុបលើរបៀបវារៈផ្សេងទៀត។ លទ្ធផល គឺការផ្តោតការយកចិត្តទុកដាក់ខ្លាំងពេកលើសកលកម្មនៃការអប់រំកម្រិតបឋមសិក្សា។ យូណេស្កូមានការប្រុងប្រយ័ត្ន នៅក្នុងការចូលរួមផ្នែកនយោបាយកម្រិតខ្ពស់របស់យើង ដូច្នេះវេទិកា ដែលជាជម្រើសរបស់តួអង្គខាងគោលនយោបាយអប់រំបានងាកចេញពីក្រុមកម្រិតខ្ពស់នេះ។ ការសន្មត់ថា សន្និសីទថ្នាក់សកល និងថ្នាក់តំបន់មានកម្លាំងគ្រប់គ្រាន់ ដើម្បីទាមទារឱ្យប្រទេស និង សហគមន៍អន្តរជាតិមានគណនេយ្យភាពនោះ នៅមិនទាន់ត្រូវបានបង្ហាញឱ្យឃើញថាជាការពិតនោះទេ។

ចាប់តាំងពីឆ្នាំ ២០០០ មក មានការប្រមូល ផ្សព្វផ្សាយ និងប្រើប្រាស់ចំណេះដឹង ភស្តុតាង និងជំនាញជាច្រើនប្រភេទ។ ភស្តុតាងថ្មីៗជាច្រើន និងគំនិតផ្តួចផ្តើមខាងគោលនយោបាយ និងការស្រាវជ្រាវជាច្រើន មិនសុទ្ធតែពាក់ព័ន្ធជាមួយនឹងសកម្មភាពអប់រំសម្រាប់ទាំងអស់គ្នានោះទេ ប៉ុន្តែជារឿយៗ មានប្រភពពីខាងក្រៅវិស័យអប់រំ។ ខណៈពេលដែលភស្តុតាងថ្មីៗមួយចំនួនពិតបានជាបានមកដល់កិច្ចប្រជុំសម្របសម្រួលការអប់រំសម្រាប់ទាំងអស់គ្នាពិតមែនភស្តុតាងទាំងនេះមិនហាក់បីដូចជាត្រូវបានគេយកមកប្រើប្រាស់ សម្រាប់តាក់តែងគោលនយោបាយឡើយ។

ចាប់តាំងពីឆ្នាំ ២០០០ មក ពុំមានកង្វះផែនការអប់រំជាតិនោះទេ។ ប៉ុន្តែ ថាតើចំណេះដឹង ឬឧបករណ៍ថ្មីៗត្រូវបានគេយកទៅប្រើប្រាស់ ដើម្បីអភិវឌ្ឍសមត្ថភាពឱ្យបានសមស្រប សម្រាប់ការតាក់តែងគោលនយោបាយជាតិដោយយកភស្តុតាងធ្វើជាគោល ឬថាតើចំណេះដឹង ឬឧបករណ៍ទាំងនោះបានពង្រឹងគោលនយោបាយជាតិស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា និងការអនុវត្តគោលនយោបាយនេះឬអត់នោះ មិនសូវជាមានភាពច្បាស់លាស់ឡើយ។

លទ្ធផលរំពឹងទុកសំខាន់មួយនៃដំណើរការដាកានេះ គឺផែនការដែលអាចជឿទុកចិត្តបាននឹងជួយកៀងគរធនធានហិរញ្ញវត្ថុ សម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នាយ៉ាងមានប្រសិទ្ធភាព។ ការកើន

ឡើងនូវការចំណាយលើការអប់រំ នៅតាមប្រទេសដែលមានចំណូលទាប គឺជាសញ្ញាជាវិជ្ជមាន ប៉ុន្តែដើមចមសំខាន់ជាងគេ គឺការកើនឡើងនូវការកៀងគរធនធានក្នុងស្រុក ជាជាងជាការផ្តល់អាទិភាពដល់វិស័យអប់រំ។ ជំនួយអន្តរជាតិមានការកើនឡើងច្រើន ក្នុងបរិមាណជាក់ស្តែង ប៉ុន្តែទំហំនៃជំនួយទាំងនេះនៅតិចតួចជាងតម្រូវការ។

ការសម្រេចចិត្តដាក់ឱ្យអនុវត្តនូវយន្តការឯករាជ្យ សម្រាប់ពិនិត្យតាមដាន និងរាយការណ៍ពីវឌ្ឍនភាព ក្នុងការឈានទៅសម្រេច គោលដៅអប់រំសម្រាប់ទាំងអស់គ្នា អាចមានសារៈសំខាន់ សម្រាប់បន្តរក្សាអ្វីដែលសម្រេចបានកន្លងមក និងការប្តេជ្ញាចិត្តចំពោះការអប់រំសម្រាប់ទាំងអស់គ្នា។ ប៉ុន្តែការរាយការណ៍ឱ្យបានល្អអាចធ្វើទៅបាន តែនៅពេលដែលមានការកែលំអគុណភាព និងការវិភាគទិន្នន័យ ដោយជារឿយៗ មានការគាំទ្រពីដៃគូ ដែលធ្វើការងារពាក់ព័ន្ធនឹងការអប់រំសម្រាប់ទាំងអស់គ្នាតែប៉ុណ្ណោះ។


Credit: Eva-Lotta Jansson

# សេចក្តីសន្និដ្ឋាន

កិច្ចខិតខំប្រឹងប្រែង ដែលមានចាប់តាំងពីឆ្នាំ ២០០០ មក ដើម្បីលើកកម្ពស់ការអប់រំនៅទូទាំងពិភពលោក បានកើតឡើងក្នុងពេលស្ទើរតែដូចគ្នា ជាមួយនឹងការធានាឱ្យកុមារគ្រប់រូបបានចូលរៀនក្នុងសាលារៀន។ សកលកម្មនៃការអប់រំបឋមសិក្សា ដែលជាចំណុចដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា (និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍) ពាក់ព័ន្ធជាពិសេស ជាមួយនឹងប្រទេសក្រីក្រជាងគេ ប៉ុន្តែចំណុចដៅផ្សេងទៀត មិនសូវជាពាក់ព័ន្ធឡើយ។ ក្នុងពេលជាមួយគ្នានៅពេលដែលមានការផ្តោតការយកចិត្តទុកដាក់លើសកលកម្មនៃការចូលរៀននៅបឋមសិក្សា មានន័យថា ទិដ្ឋភាពសំខាន់ៗផ្សេងទៀត ដូចជា គុណភាពនៃការអប់រំ ការគាំពារ និងអប់រំកុមារតូច និងអក្ខរកម្មមនុស្សពេញវ័យ មិនសូវទទួលបានការយកចិត្តទុកដាក់ឡើយ។

ជារួម សូម្បីតែចំណុចដៅសកលកម្មនៃការអប់រំបឋមសិក្សាក៏មិនអាចសម្រេចបានផុត ចុះទម្រាំគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ដែលមានមហិច្ឆតាធំជាងនេះទៅទៀតនោះ ហើយអ្នកដែលជួបការលំបាកជាងគេ នៅតែជាអ្នកទទួលបានប្រយោជន៍ចុងក្រោយគេ។ ប៉ុន្តែ មានការសម្រេចបាននូវសមិទ្ធផល ដែលមិនគួរមើលរំលង។ គិតត្រឹមឆ្នាំ ២០១៥ នេះ សកលលោកទាំងមូលបានសម្រេចនូវភាពជឿនលឿនលើសពី អ្វីដែលអាចមាន ប្រសិនបើនិន្នាការកាលពីទសវត្សរ៍ ១៩៩០ នៅតែបន្ត។ ហើយការពិនិត្យតាមដានលើវឌ្ឍនភាពនៃការអប់រំ ចាប់តាំងពីមាន ក្របខ័ណ្ឌដាកាមក មានភាពល្អប្រសើរ និងពង្រីកវិសាលភាពកាន់តែធំជាងមុន។

ចុងក្រោយ ចលនាអប់រំសម្រាប់ទាំងអស់គ្នា អាចចាត់ទុកថាជាជោគជ័យមួយ បើទោះបីជាដៃគូដែលធ្វើការងារពាក់ព័ន្ធជាមួយនឹងការអប់រំសម្រាប់ទាំងអស់គ្នា អាចមិនបានបំពេញទៅតាម ការប្តេជ្ញាចិត្តរួមគ្នារបស់ខ្លួនយ៉ាងណាក៏ដោយ។ ប៉ុន្តែ មេរៀនដែលកើតឡើងនៅក្នុង រយៈពេល ១៥ ឆ្នាំចុងក្រោយនេះ បង្ហាញថា ខណៈពេលដែលដំណោះស្រាយបច្ចេកទេសមានសារៈសំខាន់ឥទ្ធិពល និងកម្លាំងនយោបាយរឹតតែមានសារៈសំខាន់ជាងនេះទៅទៀត និងចាំបាច់ត្រូវមាន ដើម្បីឱ្យមានកំណែទម្រង់ និងសកម្មភាពក្នុងកម្រិតមួយ ដែលចាំបាច់ ដើម្បីសម្រេចនូវការអប់រំសម្រាប់ទាំងអស់គ្នានៅថ្នាក់ជាតិ។ ការពិភាក្សាអំពីរបៀបវារៈក្រោយឆ្នាំ ២០១៥ អាចផ្តល់នូវកាលានុវត្តភាពមួយ ដើម្បីឱ្យមានវិសាលភាព ក្នុងកម្រិតដែលចាំបាច់នេះ។

របៀបវារៈក្រោយឆ្នាំ ២០១៥ ផ្តល់នូវកាលានុវត្តភាពមួយ ដើម្បីអនុវត្តកំណែទម្រង់ និងធ្វើសកម្មភាពក្នុងទ្រង់ទ្រាយធំ នៅថ្នាក់ជាតិ

# បណ្ណរាយការណ៍ ២០០០-២០១៥

## គោលដៅទី ១ ការគាំពារ និងអប់រំកុមារតូច

ពង្រីក និងកែលំអការគាំពារ និងអប់រំកុមារតូចគ្រប់ជ្រុងជ្រោយ ជាពិសេស សម្រាប់កុមារងាយរងគ្រោះ និងជួបការលំបាកជាងគេ

### ពិន្ទុសកល *

*ក្នុងចំណោមប្រទេសចំនួន ១៤៨ ដែលមានទិន្នន័យ

| នៅឆ្ងាយខ្លាំងពីគោលដៅ | នៅឆ្ងាយពីគោលដៅ | កៀកនឹងគោលដៅ | បានសម្រេចគោលដៅ |
|---|---|---|---|
| 20% | 25% | 8% | 47% |

### ជោគជ័យ

**មរណភាពកុមារ**

↓39%

2000

2015

**ការចូលរៀន**

នៅមត្តេយ្យសិក្សា កុមារ ១៨៤ លាននាក់បានចូលរៀន (២០១២)

**ការអប់រំ**

មត្តេយ្យសិក្សាដែលតម្រូវដោយច្បាប់ នៅក្នុងប្រទេសចំនួន ៤០ ត្រឹមឆ្នាំ ២០១៤

**% របស់កុមារដែលទៅ សាលាមត្តេយ្យ ***




*ទិន្នន័យឆ្នាំ ២០១២

### កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើង

**ការយល់ដឹងច្រើនជាងមុនអំពីតម្រូវការរបស់កុមារតូច**

+ សៀវភៅ

ការភ្ជោចចំណេះដឹង

វត្តមានរបស់មាតាបិតា

ការលេងកម្សាន្ត

គំរូអប់រំដែលគិតគូរពីវប្បធម៌

របស់របរសម្រាប់រៀនសូត្រ

បរិយាកាសប្រកបដោយសុវត្ថិភាព

**វិធីសាស្ត្រផ្សេងៗ ដើម្បី បង្កើនការទទួលបានការអប់រំ នៅកម្រិតនេះ:**

លុបចោលថ្លៃសាលា (ហ្គាណា)

ការផ្ទេរសាច់ប្រាក់ (ចិន)

សាលាមត្តេយ្យចល័ត (ម៉ុងហ្គោលី)

ការបង្ខំតាមច្បាប់ឱ្យទៅរៀន (ម៉ិចស៊ិចកូ និងមីយ៉ាន់ម៉ា)

**ការបង្កើនតម្រូវការ**

យុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ

(ហ្គាណា និងថៃ)

### បញ្ហាប្រឈមដែលនៅបន្តមាន

**មរណភាពកុមារ**

ក្នុងឆ្នាំ ២០១៣ មានកុមារ 6.3 លាននាក់ ស្លាប់មុន អាយុបាន ៣ ឆ្នាំ

**ការចូលរៀននៅមត្តេយ្យសិក្សា**

នៅក្នុងប្រទេសមួយភាគប្រាំ មានកុមារតិចជាង 30% ដែលនឹងចុះឈ្មោះចូលរៀន នៅត្រឹមឆ្នាំ ២០១៥

**គុណភាពទាប**

ចាំបាច់ត្រូវមានគ្រូ និងអ្នកផ្តល់ការថែទាំដែលបានឆ្លងកាត់ការបណ្តុះបណ្តាលបន្ថែមទៀត

### វិឌ្ឍនភាពមិនស្មើគ្នា

**មរណភាពកុមារ**

កុមារម្នាក់នៅអាហ្វ្រិចសាប់សាហារ៉ា អាចស្លាប់មុនដល់អាយុបាន ៥ ឆ្នាំ ១៥ ដង ច្រើនជាង កុមារដែលនៅក្នុងតំបន់អភិវឌ្ឍន៍

**ទីតាំង**

ក្នុងឆ្នាំ ២០០០ កុមារនៅតំបន់ជនបទ ដែលមិនដែលទៅសាលា មានច្រើនជាងកុមារនៅតំបន់ ប្រជុំជន ២ ដង [តូហ្គោ ឆាដ និងឡាវ]

**ទ្រព្យធន**

គម្លាតរវាងអ្នកមាន និងអ្នកក្រ ដែលបានទៅរៀន គឺធំជាងមុន ២ ដង នៅក្នុងឆ្នាំ ២០០០ [នីហ្សេ តូហ្គោ C.A.R បូស្នៀ/ ហេហ្សេហ្គោវីណា និងម៉ុងហ្គោលី]

**សាលាមតេយ្យឯកជន**

កុមារដែលចុះឈ្មោះចូលរៀននៅ សាលាមត្តេយ្យឯកជនមានការកើនឡើង

ចាប់តាំងពីឆ្នាំ ១៩៩៩ មក

### អនុសាសន៍ សម្រាប់ក្រោយឆ្នាំ ២០១៥

១. ចាំបាច់ត្រូវតែមានការអប់រំបន្ថែមទៀត ដើម្បីបញ្ចូលកុមារគ្រប់រូប ជាពិសេស កុមារដែលជួបប្រទះការលំបាកជាងគេ

ចាំបាច់ត្រូវមានការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត

២. ចាំបាច់ត្រូវតែមានទិន្នន័យល្អជាងមុនអំពីការគាំពារ និងការអប់រំកុមារតូចគ្រប់ប្រភេទទាំងអស់

៣. ចាំបាច់ត្រូវមានការអប់រំកម្រិតមត្តេយ្យសិក្សាដែលមានលក្ខណៈចាប់បង្ខំ យ៉ាងហោចណាស់មួយឆ្នាំ សម្រាប់កុមារទាំងអស់

# គោលដៅទី ១ ការគាំពារ និងអប់រំកុមារតូច

*ពង្រីក និងកែលំអការគាំពារ និងអប់រំកុមារតូចគ្រប់ជ្រុងជ្រោយ ជាពិសេសសម្រាប់កុមារងាយរងគ្រោះ និងជួបការលំបាកជាងគេ*

ការគាំទ្រដល់ការអភិវឌ្ឍកុមារនៅដំណាក់កាលដំបូងបំផុតនៃជីវិត មានឥទ្ធិពលយ៉ាងធំធេងមកលើការធ្វើឱ្យលទ្ធផលខាងការអប់រំ និងសង្គមកាន់តែមានភាពល្អប្រសើរជាងមុន។ ផលប្រយោជន៍ខាងសេដ្ឋកិច្ចអាចទទួលបានខ្ពស់បំផុតពីការវិនិយោគលើការអប់រំកុមារតូច។ សហគមន៍ ដែលមិនសូវមានឱកាសដូចគេ ជាពិសេស នៅតាមប្រទេសក្រីក្រ កាន់តែអាចទទួលបានប្រយោជន៍យ៉ាងច្រើន ដែលនេះជាហេតុផលមួយទៀត សម្រាប់ការវិនិយោគឱ្យច្រើនលើការអប់រំនៅកម្រិតនេះ។

ចាប់តាំងពីឆ្នាំ ២០០០ មក មានការសម្រេចបាននូវវឌ្ឍនភាព ខាងចំនួនកុមារ ដែលបានចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីគាំពារ និងអភិវឌ្ឍន៍កុមារតូច នៅទូទាំងពិភពលោកទាំងមូល។ ប៉ុន្តែ កុមារមកពីក្រុមជួបការលំបាក នៅតែមិនមានឱកាសចូលរៀនបែបនេះ ដោយសារតែកង្វះថវិកា បញ្ហាវិសមធម៌ជាប្រព័ន្ធ និងកង្វះការយកចិត្តទុកដាក់លើបញ្ហាគុណភាព។

## មានការសម្រេចបានវឌ្ឍនភាពមួយចំនួន ខាងភាពរស់រាន និងអាហារូបត្ថម្ភ ប៉ុន្តែការថែទាំនៅតែមានគុណភាពអន់

បញ្ហាកង្វះអាហារូបត្ថម្ភ អាចនាំឱ្យមានភាពយឺតយ៉ាវដល់ការអភិវឌ្ឍចលករធំ និងតូច និងការកើនឡើងនូវហានិភ័យពាក់ព័ន្ធនឹងមរណភាព។ ប៉ុន្តែ អាហារូបត្ថម្ភដែលល្អ គឺមិនគ្រប់គ្រាន់ឡើយ ៖ ចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការក្នុងចំណោមសេវាសុខភាព អប់រំ និងកិច្ចគាំពារសង្គម ដើម្បីប្រយុទ្ធប្រឆាំងនឹងកត្តាហានិភ័យ ពាក់ព័ន្ធនឹងភាពក្រីក្រ ដែលជួយពង្រឹងដល់គ្នាទៅវិញទៅមកទាំងនេះ។

### *មរណភាពកុមារមានការថយចុះ*

ចន្លោះពីឆ្នាំ ១៩៩០ ដល់ ២០១៣ អត្រាមរណភាពកុមារបានថយចុះពី ៩០ ដល់ ៤៦ ករណី ក្នុង ១០០០ កំណើតរស់។ ប៉ុន្តែ ការថយចុះនូវមរណភាពកុមារជិត ៥០% នេះ មិនទាន់គ្រប់គ្រាន់ ដើម្បីសម្រេចតាមចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលត្រូវបានកំណត់នៅក្នុងឆ្នាំ ២០០០ ថា ត្រូវកាត់បន្ថយឱ្យបាន ២ ភាគ ៣ ពីកម្រិតក្នុងឆ្នាំ ១៩៩០ នោះទេ។ កុមារ ដែលកាលពីឆ្នាំ ២០១៣ មាន ៦,៣ លាននាក់ បន្តបាត់បង់ជីវិត មុនពេលដែលពួកគេមានអាយុ ៥ ឆ្នាំ ដែលករណីស្លាប់ជាច្រើនកើតឡើងដោយសារមូលហេតុ ដែលអាចបង្ការជាមុនបាន។ កុមារកាន់តែប្រឈមនឹងហានិភ័យខ្ពស់ទៅទៀត ប្រសិនបើពួកគេកើតជាមួយនឹងម្ដាយដែលមានជីវភាពក្រីក្រ រស់នៅតំបន់ជនបទ និង/ឬមិនបានទទួលការអប់រំខ្ពស់។ ដើម្បីដោះស្រាយបញ្ហាមរណភាពកុមារនេះ ឆន្ទៈនយោបាយ និងថវិកា មានសារៈសំខាន់យ៉ាងខ្លាំង។

ការកសាងមូលដ្ឋានគ្រឹះឱ្យបានសមស្រប នាំមកវិញនូវអត្ថប្រយោជន៍ធំធេងនាពេលអនាគត

### *អាហារូបត្ថម្ភកុមារមានភាពល្អប្រសើរជាងមុន ប៉ុន្តែមិនគ្រប់គ្រាន់ឡើយ*

ប្រទេសភាគច្រើនបានសម្រេចនូវវឌ្ឍនភាព នៅក្នុងការកាត់បន្ថយភាគរយកុមារក្រិន ចាប់ពីទសវត្សរ៍ ១៩៩០ មក។ ប្រទេសជាច្រើន នៅអាហ្វ្រិចសាប់សាហារ៉ា បានសម្រេចនូវវឌ្ឍនភាពយ៉ាងល្អប្រសើរ ចាប់តាំងពីឆ្នាំ ២០០០ មក

ប៉ុន្តែតំបន់នេះនៅតែមានកុមារដែលមានបញ្ហាអាហារូបត្ថម្ភក្នុងភាគច្រើនខ្ពស់បំផុត ខ្ពស់ឆ្ងាយពីតំបន់ផ្សេងទៀត ដែលគេព្យាករថាអាចកើនឡើងរហូតដល់ ៤៥% នៃចំនួនកុមារមានបញ្ហាអាហារូបត្ថម្ភ ក្នុងពិភពលោក ត្រឹមឆ្នាំ ២០២០។

### *ការឈប់សម្រាករបស់មាតាបិតា និងការអនុវត្តការចិញ្ចឹមបីបាច់កូនបានល្អ អាចជួយគាំទ្រដល់ការអភិវឌ្ឍកុមារបាន*

កុមារគួរទទួលបានការគាំទ្រ ដើម្បីឱ្យពួកគេលូតលាស់រីកចម្រើន ពោលគឺមិនត្រឹមតែរស់រានមានជីវិតប៉ុណ្ណោះទេ។ ការឈប់សម្រាក លំហែមាតុភាពដោយមានប្រាក់ឈ្នួលនៅក្នុងអំឡុងខែដំបូងៗនៃជីវិតរបស់ទារក មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់សុខភាព និងសុខុមាលភាព របស់ម្តាយនិងកូន នៅតាមបណ្តាប្រទេសចំណូលមធ្យម និងខ្ពស់ជាច្រើន។ បើទោះបីជាប្រទេសស្ទើរតែទាំងអស់ផ្តល់ការឈប់សម្រាកបែបនេះតាមច្បាប់ក៏ដោយមានស្ត្រីដែលមានការងារធ្វើក្នុងពិភពលោកតែ ២៨% ប៉ុណ្ណោះ ដែលទទួលបានអត្ថប្រយោជន៍សម្រាប់មាតុភាពរបស់ខ្លួនជាសាច់ប្រាក់។ ការចូលរួមរបស់ឳពុកក៏មានសារៈសំខាន់ផងដែរ ចំពោះការអភិវឌ្ឍកុមារ។ ត្រឹមឆ្នាំ ២០១៣ ការសម្រាកលំហែបិតុភាពត្រូវបានផ្តល់នៅក្នុងប្រទេសចំនួន ៧៨ ក្នុងចំណោមប្រទេសទាំង ១៦៧ ដែលមានទិន្នន័យប៉ុណ្ណោះ ដោយប្រទេសចំនួន ៧០ ផ្តល់ការឈប់សម្រាកដោយ មានប្រាក់ឈ្នួល។ ប៉ុន្តែ បុរសអាចមានភាពស្ទាក់ស្ទើរ ក្នុងការឈប់សម្រាកសម្រាកបែបនេះ ដោយសារតែជារឿយៗប្រាក់ឈ្នួលរបស់ពួកគេមានកម្រិតទាប។

នៅត្រឹមឆ្នាំ ២០១៤ ប្រទេសចំនួន ៤០បានកំណត់ការអប់រំថ្នាក់មត្តេយ្យសិក្សា ថាជាការអប់រំដែលតម្រូវតាមច្បាប់។

មាតាបិតាអាចជម្រុញការអភិវឌ្ឍខាងចំណេះដឹង និងចិត្តសង្គមរបស់កូនរបស់ខ្លួនបន្ថែមទៀត តាមរយៈកម្មវិធីក្នុងឬក្រៅផ្ទះ ជាក្រុម ឬជាលក្ខណៈបុគ្គល។ កម្មវិធីចុះតាមផ្ទះផ្តល់នូវការគាំទ្រផ្ទាល់និងអាចមានប្រយោជន៍យ៉ាងធំធេង។

### ប្រទេសជាច្រើនកំពុងឈានទៅប្រើប្រាស់អភិក្រមពហុវិស័យ ដើម្បីផ្តល់សេវាកុមារតូច

ក្នុងការអំពាវនាវឱ្យប្រទេសនានាពង្រីក និងកែលំអការគាំពារ និងអភិវឌ្ឍន៍កុមារតូចឱ្យបានគ្រប់ជ្រុងជ្រោយជាពិសេស សម្រាប់កុមារក្រីក្រ និងកុមារជួបការលំបាកក្របខ័ណ្ឌសកម្មភាពដាការនេះផ្តល់អនុសាសន៍ឱ្យមានការរៀបចំគោលនយោបាយជាតិ ដែលមានចារឹកពហុវិស័យ ដោយមានការគាំទ្រពីធនធានឱ្យបានគ្រប់គ្រាន់។ គិតត្រឹមឆ្នាំ ២០១៤មានប្រទេសចំនួន៧៨បានអនុម័តលើគោលនយោបាយពហុវិស័យ បែបនេះ និង ២៣ កំពុងតែរៀបចំគោលនយោបាយបែបនេះ។ សមាសភាគដែលរួមចំណែកនាំឱ្យគោលនយោបាយពហុវិស័យទទួលបាន ជោគជ័យ រួមមានការសម្របសម្រួល ការវាស់វែងវឌ្ឍនភាពតាមក្រសួង និងស្ថាប័ននានា ដោយមានការឯកភាពគ្នាជារួម និងនិរន្តភាពបុគ្គលិក។

### ប្រព័ន្ធអប់រំមត្តេយ្យសិក្សា និងកម្រិតនៃការចុះឈ្មោះចូលរៀនត្រូវបានពង្រីកយ៉ាងឆាប់រហ័ស នៅតាមប្រទេសមួយចំនួន

ការពង្រីកលទ្ធភាពទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សាមិនថាតាមរយៈកម្មវិធីក្នុងប្រព័ន្ធ ឬកម្មវិធីក្រៅផ្លូវការ នោះទេមានសារៈសំខាន់យ៉ាងខ្លាំង ចំពោះការបង្កើនឱកាសក្នុងជីវិតរបស់កុមារ តាមរយៈការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធអប់រំ

និងធនធាន និងការកាត់បន្ថយវិសមភាព នៅក្នុងសង្គមទាំងមូល។

## *ការចុះឈ្មោះចូលរៀនមានការកើនឡើងជិត ២ ភាគ ៣ ក្នុងរយៈពេលជាងមួយទសវត្សរ៍បន្តិច ប៉ុន្តែសមភាពនៅតែមានកម្រិតខ្ពស់*

ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១២ ការចុះឈ្មោះចូលរៀននៅមធ្យមសិក្សាបានកើនឡើង ៦៤% (ដល់ ១៨៤ លាននាក់) ដោយមានគម្លាតយេនឌ័រតិចតួច។ ប្រទេសមួយចំនួនបានពង្រីកប្រព័ន្ធមធ្យមសិក្សាសាធារណៈរបស់ខ្លួនយ៉ាងធំធេង ដូចជា ប្រទេសកាហ្សាក់ស្ថាន និងវៀតណាម ជាដើម។ ប៉ុន្តែ វឌ្ឍនភាពដែលសម្រេចបាននេះមិនដូចគ្នាឡើយ ដោយគម្លាតនៅតែមានរវាងតំបន់ប្រជុំជន និងតំបន់ជនបទ និងរវាងសហគមន៍មួយ និងសហគមន៍មួយទៀត និងរវាងតំបន់មួយ និងតំបន់មួយទៀត នៅក្នុងប្រទេស។ វិសមភាពទ្រព្យសម្បត្តិ ពាក់ព័ន្ធនឹងការចូលរៀនមានជាទូទៅនៅតាមប្រទេសមួយចំនួន ដូចជា ប្រទេសឡាវ ទុយនេស៊ី និងម៉ុងហ្គោលី ជាដើម។ វិធីសាស្ត្រ ដើម្បីជម្រុញឱ្យមានការពង្រីកការចូលរៀនបន្ថែមទៀត រួមមាន ៖

- ច្បាប់ ដែលតម្រូវឱ្យមានការចូលរួម។ គិតត្រឹមឆ្នាំ ២០១៤ មានប្រទេសចំនួន ៤០ បានកំណត់ការអប់រំថ្នាក់មធ្យមសិក្សា ថាជាការអប់រំដែលតម្រូវដោយច្បាប់។
- គោលនយោបាយ ដែលដាក់បញ្ចូលការអប់រំមធ្យមសិក្សាទៅក្នុងវដ្តនៃការអប់រំថ្នាក់មូលដ្ឋាន។ ប្រទេសជាច្រើនបានរៀបចំចេញជា គោលនយោបាយបែបនេះ ប៉ុន្តែមិនបានផ្តល់ធនធានហិរញ្ញវត្ថុ សម្រាប់ការអនុវត្តគោលនយោបាយទាំងនេះឡើយ។
- ការលុបបំបាត់ការបង់ថ្លៃសម្រាប់ការអប់រំមធ្យមសិក្សា។ ប្រទេស ដែលបានធ្វើបែបនេះ មានការកើនឡើងការចូលរួមខ្លាំង បើទោះបីជារដ្ឋាភិបាលមួយចំនួនបានខិតខំស្វែងរកធនធានចាំបាច់ក៏ដោយ។
- ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ សម្រាប់ការចុះឈ្មោះចូលរៀន។ នៅតំបន់ជនបទរបស់ប្រទេសចិន កុមារ នៅក្នុងគ្រួសារ ដែលទទួល បានការលើកលែងការបង់ថ្លៃសិក្សា និងការផ្ទេរសាច់ប្រាក់ ជាមួយនឹងលក្ខខណ្ឌថា កុមារទាំងនោះត្រូវតែចូលរៀន ច្រើនតែបានចូលរៀននៅសាលាមធ្យមសិក្សា ២០% ច្រើនជាងមុន។
- ការធ្វើឱ្យការរៀនសូត្រនៅមធ្យមសិក្សាកាន់តែមានភាពទាក់ទាញចំពោះមាតាបិតា និងកុមារ។ នៅក្នុង

**រូបភាពទី ៤ ៖ អត្រានៃការសិក្សានៅមធ្យមសិក្សាត្រូវបានព្យាករថាមានការកើនឡើង ៣ ភាគ ៤ នៅក្នុងរយៈពេលនៃក្របខ័ណ្ឌដាការនេះ**
អត្រារួមនៃការសិក្សានៅមធ្យមសិក្សា ក្នុងពិភពលោក និងតាមតំបន់ ១៩៩០-២០១២ និង ២០១៥ (ចំណោល)




*ប្រភព* ៖ មូលដ្ឋានទិន្នន័យ UIS: Bruneforth (2015)

ប្រទេសថៃ ការផ្តល់ការលើកទឹកចិត្ត រួមជាមួយនឹងយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ បានបង្កើនការចូលរៀនក្នុងកម្មវិធីគាំពារ និងអប់រំកុមារតូចដល់ ជិត ៩៣% សម្រាប់កុមារអាយុ ៤ និង ៥ ឆ្នាំ។

## *ការចូលរួមរបស់វិស័យឯកជននៅតែមានកម្រិតខ្ពស់*

ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១២ ភាគរយនៃការចុះឈ្មោះចូលរៀនក្នុងសាលាមត្តេយ្យឯកជន បានកើនឡើងពី ២៨% ដល់ ៣១% ក្នុង ១០០ ប្រទេស ដែលមានទិន្នន័យ។ ការកើនឡើងនូវការចូលរៀនក្នុងសាលាឯកជន នាំឱ្យមានបញ្ហាចំនួន ២។ នៅតាមកន្លែងដែលការទទួលបានសេវាគាំពារ និងអប់រំកុមារតូច ពឹងអាស្រ័យលើការបង់ថ្លៃកុមារក្រីក្រជាងគេជាច្រើននាក់ត្រូវខកខានមិនបានទទួលសេវា។ ហើយអ្នកផ្តល់សេវា ឯកជនមិនទំនងជាផ្តល់សេវា នៅតំបន់ដាច់ស្រយាល ដែលមានប្រជាជនរស់នៅរាយប៉ាយឆ្ងាយពីគ្នាណាស់។ លើសពីនេះ នៅតាមប្រទេសដែល មានចំណូលទាប និងចំណូលមធ្យមកម្រិតទាប សាលាឯកជនដែលគិតថ្លៃទាបជាច្រើន ដំណើរការក្នុងស្ថានភាពអន់ថយដោយពុំមានការចុះបញ្ជី ត្រឹមត្រូវជាមួយនឹងរដ្ឋាភិបាល។ សូម្បីតែនៅតាមប្រទេសដែលមានចំណូលខ្ពស់ ដូចជាចក្រភពអង់គ្លេស ជាដើម កុមារក្រីក្រជាច្រើននាក់រៀនមិនបានពូកែ ដោយសារតែសាលាមត្តេយ្យឯកជនផ្តល់សេវា



Credit: Olivier Culmann/Tendance Floue

ដែលមានគុណភាពទាប គិតថ្លៃទាប និងច្រើនតែដំណើរការនៅតាមតំបន់ជួបការលំបាក។

### *ការខិតខំ ដើម្បីសម្រេចគុណភាព នៅមិនទាន់ទទួលបានការឆ្លើយតបប្រកបដោយអត្ថន័យនៅឡើយ*

កុមារ ដែលមិនបានទទួលការអប់រំមត្តេយ្យសិក្សាដែលមានគុណភាពល្អ មិនសូវជាទទួលបានជោគជ័យនៅកម្រិតបឋមសិក្សា និងកម្រិតខ្ពស់ៗទៅទៀតឡើយ។ ខណៈពេលដែលសូម្បីតែការផ្តល់ការអប់រំកម្រិតនេះដែលមានគុណភាពមិនល្អ ផ្តល់នូវអត្ថប្រយោជន៍មួយចំនួន ដែរនោះ គុណភាពកាន់តែប្រសើរនាំឱ្យទទួលបានប្រយោជន៍កាន់តែច្រើន។

ការរៀបចំគ្រូមត្តេយ្យសិក្សា គឺជាគន្លឹះ សម្រាប់បង្កើនគុណភាព តែទោះជាយ៉ាងណាក៏ដោយ ជារឿយៗ បុគ្គលិកដែលមិនបានទទួលការបណ្តុះបណ្តាល នៅតែត្រូវបានគេជួលឱ្យបម្រើការងារ ហើយមុខមាត់ និងបៀវត្សរ៍ទាបនាំឱ្យមានការឈប់ច្រើន ដែលធ្វើឱ្យខូចខាតដល់លទ្ធផលនៃការសិក្សា។ វិស័យឯកជនច្រើនតែផ្តល់បៀវត្សរ៍ដល់គ្រូទាបតាមដែលអាចធ្វើបាន ដើម្បីកាត់បន្ថយចំណាយ។ ប្រទេសនានា ដូចជា ប្រទេសកេនយ៉ា សឹង្ហបុរី និងកូឡុំប៊ៀរជាដើម កាន់តែកំណត់យ៉ាងច្បាស់លាស់ពីលក្ខខណ្ឌសម្រាប់ការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ប៉ុន្តែប្រទេសជាច្រើនមិនទាន់បានកំណត់ស្តង់ដាអប្បបរមាជាផ្លូវការនៅឡើយទេ។


ប័ណ្ណរាយការណ៍ ២០០០-២០១៥
គោលដៅទី ២ សកលកម្មនៃការអប់រំបឋមសិក្សា
ធានាថា ត្រឹមឆ្នាំ ២០១៥ កុមារគ្រប់រូប ជាពិសេស កុមារា កុមារស្ថិតក្នុងស្ថានភាពលំបាក និងកុមារជនជាតិភាគតិច អាចទទួលបាន និងបញ្ចប់ការអប់រំបឋមសិក្សាមិនគិតថ្លៃ និងតម្រូវដោយច្បាប់ប្រកបដោយគុណភាពល្អ។
ពិន្ទុសកល *
*ក្នុងចំណោមប្រទេសចំនួន ១៤០ ដែលមានទិន្នន័យ
នៅឆ្ងាយខ្លាំងពីគោលដៅ
9%
នៅឆ្ងាយពីគោលដៅ
29%
ជៀកនឹងគោលដៅ
10%
បានសម្រេចគោលដៅ
52%
ជោគជ័យ
កុមារដែលបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា
1999
84%
បច្ចុប្បន្ន
91%
= 48 លាននាក់ទៀត
ការរៀនចប់បឋមសិក្សា
ម៉ាលី
ហ្គីនី
សេរ៉ាលីអូន
បេនិន
អេចូពី
ម៉ូសាមប៊ិច
អត្រាបញ្ចប់ការសិក្សាបឋមសិក្សាកើនឡើងជាង ២០ ភាគរយចំណុច
កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើង
លុបចោលការបង់ថ្លៃសាលា
កិច្ចគាំពារសង្គម
(ឧ. ការផ្ទេរសាច់ប្រាក់ដល់កុមារដែលជួបការលំបាក)
សាលារៀន ទឹក អគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធ សុខភាព
បញ្ហាប្រឈមដែលនៅបន្តមាន
ក្រៅសាលា
កុមារ ៥៨ លាននាក់ នៅក្រៅសាលា នៅឡើយ ក្នុងចំណោមនេះ មិនដែលបានទៅសាលាឡើយ
មិនបានរៀនចប់សាលា
៣៤ លាននាក់ ឆាប់បោះបង់ចោលការសិក្សា ជារៀងរាល់ឆ្នាំ
% របស់អ្នកដែលរៀនដល់ថ្នាក់ចុងក្រោយក្នុងសាលារៀន មិនមានការកើនឡើងឡើយ
100
80
60
40
20
0
%
1999
2011
64% អាស៊ីខាងត្បូង និងខាងលិច
58% អាហ្វ្រិកសាប់សាហារ៉ា
ឧបសគ្គ
កុមារក្រៅសាលា ៣៦% រស់នៅក្នុងតំបន់ ដែលរងផលប៉ះពាល់ដោយសារជម្លោះ
ការអប់រំ មានគុណភាពទាប
$$$
ការអប់រំនៅមិនទាន់ផ្តល់ដោយមិនគិតថ្លៃសម្រាប់ទាំងអស់គ្នានៅឡើយ
វិឌ្ឍនភាពមិនស្មើគ្នា
កុមារក្រៅសាលានៅថ្នាក់តំបន់ប្រទេសផ្សេងទៀត
តំបន់ផ្សេងៗក្នុងលោក
អាហ្វ្រិកសាប់សាហារ៉ា
អាស៊ីខាងត្បូង និងខាងលិច
តំបន់ជនបទ/ប្រជុំជន
ប្រទេសចំណូលមធ្យមកម្រិតទាប
2000 3x មិនដែលទៅសាលាច្រើនជាង
2008 4x មិនដែលទៅសាលាច្រើនជាង
ក្រុមជួបការលំបាក ដែលត្រូវបានបន្សល់ទុកឱ្យនៅក្រោយគេ
ជម្លោះ
ធ្វើការងារ ពិការ
ជនជាតិភាគតិច/ភាសាភាគតិច
ផ្ទុកមេរោគអេដស៍
ក្មេងស្រីនៅជនបទ
ក្រុមដែលក្រីក្រជាងគេនៅតែទទួលបានលទ្ធផល អន់ជាងគេ
5x បានរៀនចប់តិចជាងកុមារ ដែលមកពីគ្រួសារជីវភាព ធូរធាជាងគេក្នុងឆ្នាំ ២០១០
អនុសាសន៍ សម្រាប់ក្រោយឆ្នាំ ២០១៥
១. ត្រូវតែមានការឆ្លើយតបចំពោះស្ថានភាពលំបាក ប្រសិនបើយើងចង់សម្រេចនូវសកលកម្មនៃការអប់រំបឋមសិក្សា
២. ចាំបាច់ត្រូវមានទិន្នន័យឱ្យបានកាន់តែល្អប្រសើរ ដើម្បីតាមដានវិឌ្ឍនភាពរបស់អ្នកដែលជួបការលំបាកជាងគេ
មានកន្លែងដែលអាចកែលំអ

# គោលដៅទី ២ សកលកម្មនៃការអប់រំបឋមសិក្សា

*ធានាថា ត្រឹមឆ្នាំ ២០១៥ កុមារគ្រប់រូប ជាពិសេស កុមារា កុមារស្ថិតក្នុងស្ថានភាពលំបាក និងកុមារជនជាតិភាគតិច អាចទទួលបាន និងបញ្ចប់ការអប់រំបឋមសិក្សាមិនគិតថ្លៃ និងតម្រូវដោយច្បាប់ ប្រកបដោយគុណភាពល្អ។*

សកលកម្មនៃការអប់រំកម្រិតបឋមសិក្សា គឺជាគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ដែលលេចធ្លោជាងគេ ដូចដែលឆ្លុះបញ្ចាំង តាមរយៈការដាក់បញ្ចូលគោលដៅនេះ ទៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ គោលដៅនេះទទួលបានថវិកាគាំទ្របានសមស្រប មានការគាំទ្រពីនយោបាយ និងត្រូវបានពិនិត្យតាមដានយ៉ាងទូលំទូលាយ។ តែទោះជាយ៉ាងណាក៏ដោយ គោលដៅនេះនៅតែមិនទាន់សម្រេចបានទៀត នៅឆ្នាំ ២០១៥។

ប្រទេស ដែលមិនបានផ្តល់សេវាឱ្យបានដល់ក្រុមជួបការលំបាក មិនអាចសម្រេចនូវសកលកម្មនៃការអប់រំកម្រិតបឋមសិក្សាបានឡើយ។ ចាំបាច់ត្រូវតែមានការកែលំអបន្ថែមទៀត ដើម្បីផ្តល់សេវាឱ្យបានដល់ក្រុមដែលមានជីវភាពក្រីក្រជាងគេ ជនជាតិភាគតិច និងក្រុមភាសាភាគតិច ក្មេងស្រីដែលរស់នៅជនបទ កុមារដែលកំពុងធ្វើការងារសហគមន៍ពនេចរ កុមារដែលរងផលប៉ះពាល់ដោយសារមេរោគ និងជំងឺអេដស៍ អ្នករស់នៅតាមសំណង់មិនរៀបរយ កុមារពិការ និងកុមារដែលរស់នៅក្នុងស្ថានភាពអាសន្នស្មុគស្មាញ។

## ការពិនិត្យតាមដានវឌ្ឍនភាព

នៅក្នុងឆ្នាំ ២០១២ មានកុមារអាយុចូលរៀននៅសាលាបឋមសិក្សាជិត ៥៨ លាននាក់ មិនបានចុះឈ្មោះចូលរៀននៅសាលារៀនឡើយ។ មូលហេតុរួមមានសម្ពាធប្រជាសាស្ត្រ ស្ថានភាពមានជម្លោះ ការទទួលរងការលំបាករបស់ក្រុមសង្គម-សេដ្ឋកិច្ចខុសៗគ្នា និងការមិនមានការប្តេជ្ញាចិត្ត

គោលដៅទី ២ គឺជាគោលដៅដែលលេចធ្លោជាងគេ ប៉ុន្តែនៅតែមិនអាចសម្រេចបាននៅត្រឹមឆ្នាំ ២០១៥

**រូបភាពទី ៥ ៖ ល្បឿននៃកំណើនអត្រាពិតនៃការសិក្សានៅបឋមសិក្សា មានការកើនឡើងនៅដើមទសវត្សរ៍ ២០០០ ប៉ុន្តែថមថយមកវិញ ក្រោយឆ្នាំ ២០០៧**

អត្រាពិតនៃការសិក្សានៅបឋមសិក្សាដែលបានកែសម្រួលរួច ក្នុងពិភពលោក និងតាមតំបន់ ១៩៩០-២០១២ និង ២០១៥ (ចំណោល)




*ប្រភព* ៖ មូលដ្ឋានទិន្នន័យ UIS: Bruneforth (2015)

ឱ្យបានគ្រប់គ្រាន់ នៅតាមប្រទេសមួយចំនួន ដែលមានប្រជាជនក្រៅសាលាច្រើននាក់។

បើទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយប្រទេសមួយចំនួន ដូចជា ប៊ូរុនឌី អេត្យូពី ម៉ារ៉ុក ម៉ូហ្សាំប៊ីក នេប៉ាល់ និងសាធារណរដ្ឋតង់ហ្សានី បានសម្រេចនូវវឌ្ឍនភាពជាច្រើន បើទោះបីជាមិនបានដូចៗគ្នាក៏ដោយ ក្នុងការកាត់បន្ថយគម្លាតយេនឌ័រ និងប្រាក់ចំណូល នៅក្នុងការចូលរៀននៅសាលាបឋមសិក្សា និងក្នុងការបង្កើនអត្រាពិតនៃការសិក្សា និងអត្រាបញ្ចប់ការសិក្សា។

ការបញ្ចប់ការសិក្សានៅបឋមសិក្សាមានការកើនឡើងនៅក្នុងប្រទេសភាគច្រើន

### *អត្រាពិតនៃការសិក្សាមានការកើនឡើងយ៉ាងច្រើន*

ក្នុងចំណោម ១១៦ ប្រទេសដែលមានទិន្នន័យ ១៧ ប្រទេស បានបង្កើនអត្រាពិតនៃការសិក្សា ជាង ២០ ភាគរយចំណុច ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១២។ ប្រទេសប៊ូតាន ឡាវ និងនេប៉ាល់ បង្ហាញឧទាហរណ៍ពីការកើនឡើងយ៉ាងខ្ពស់នូវអត្រាពិតនៃការសិក្សានៅអាស៊ី។ នៅអាមេរិចឡាទីនវិញ ប្រទេសអែលសាវ៉ាឌ័រ គ័រតេម៉ាឡា និងនីការ៉ាហ្គ័រ បានបង្កើនអត្រាពិតនៃការសិក្សារបស់ខ្លួន បានជាង ១០ ភាគរយចំណុច។ នៅអាហ្វ្រិចសាប់សាហារ៉ា អត្រាពិតនៃការសិក្សារបស់ប្រទេសប៊ូរុនឌី កើនឡើងពីតិចជាង ៤១% នៅក្នុងឆ្នាំ ២០០០ ដល់ ៩០% នៅក្នុងឆ្នាំ ២០១០។



### *កុមារដែលមិនបានទៅសាលា មានចំនួនតិចជាងមុន*

ភាគរយនៃកុមារ ដែលមិនបានទៅសាលា មានការថយចុះ នៅក្នុងប្រទេសជាច្រើន។ ក្នុងចំណោមប្រទេស ដែលមានកុមារយ៉ាងហោចណាស់ ២០% មិនបានទៅសាលា នៅក្នុងឆ្នាំ ២០០០ មានប្រទេសចំនួន ១០ ដែលបានកាត់បន្ថយភាគរយនេះបានពាក់កណ្ដាល នៅត្រឹមឆ្នាំ ២០១០។ ភាគរយរបស់កុមារ ដែលមិនបានទៅសាលា មានការថយចុះក្នុងអត្រាគួរឱ្យកត់សម្គាល់ នៅក្នុងប្រទេសអេត្យូពី (ពី ៦៧% នៅក្នុងឆ្នាំ ២០០០ មក ២៨% ក្នុងឆ្នាំ ២០១១) និងក្នុងសាធារណរដ្ឋតង់ហ្សានី (ពី ៤៧% ក្នុងឆ្នាំ ១៩៩៩ មក ១២% នៅក្នុងឆ្នាំ ២០១០)។

### *ប្រទេសមួយចំនួននៅតែមានអ្នកនៅក្រៅសាលាក្នុងចំនួនដ៏ច្រើន*

ប្រទេសដែលមានចំនួនប្រជាជនច្រើនបន្តមានក្រុមកុមារក្រៅសាលា ក្នុងចំនួនដ៏ច្រើន នៅក្នុងឆ្នាំ ២០១២។ ប្រទេសឥណ្ឌាបានបង្កើនអត្រាពិតនៃការសិក្សារបស់ខ្លួនពី ៨៦% ដល់ ៩៩% ប៉ុន្តែប្រទេសនីហ្សេរីយ៉ា និងប៉ាគីស្ថាន សម្រេចបានវឌ្ឍនភាព ទាបជាងការរំពឹងទុកឆ្ងាយ មួយផ្នែកដោយសារតែជម្លោះជាតិសាសន៍ និងសាសនា លទ្ធិប្រជាធិបតេយ្យនៅមានកម្រិតខ្សោយ និងអ្នកដឹកនាំនយោបាយពុករលួយ។

### *ប្រទេសភាគច្រើននៅមានផ្លូវដើរដ៏វែង ដើម្បីសម្រេចឱ្យបាននូវការបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សា ជាពិសេសសម្រាប់ ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រជាងគេ*

ការបញ្ចប់ការសិក្សាកម្រិតបឋមសិក្សា មានការកើនឡើង នៅក្នុងប្រទេសដ៏ច្រើនលើសលុប។ ប្រទេសចំនួន ៨ បានបង្កើនអត្រាបញ្ចប់បឋមសិក្សាជាង ២០ ភាគរយចំណុច ជាអាទិ៍ បេនីន កម្ពុជា អេត្យូពី ហ្គីនី ម៉ាលី មូហ្សាប៊ីច នេប៉ាល់ និងសៀរ៉ាលីអូន។ ប៉ុន្តែ វឌ្ឍនភាពដែលសម្រេចបានទាំងនេះ នៅឆ្ងាយពីកម្រិតគ្រប់គ្រាន់នៅឡើយ ដែល

ជាសញ្ញាបង្ហាញពីបញ្ហាដែលនៅតែមាន ដូចជា លទ្ធភាពចំណាយសម្រាប់ការសិក្សា គុណភាព និងភាពឆ្លើយតប។

*វិឌ្ឍនភាពមានការប្រែប្រួលខុសៗគ្នារវាងប្រទេសនានា*

ការបោះបង់ចោលការសិក្សា គឺជាបញ្ហាធ្ងន់ធ្ងរមួយនៅតាមប្រទេសដែលមានចំណូលទាប ជាពិសេស ក្នុងចំណោមកុមារ ដែលចូលរៀនយឺត និងកុមារក្រីក្រ។ ក្នុងចំណោម ១៣៩ ប្រទេស ដែលមានទិន្នន័យគ្រប់គ្រាន់ ក្នុងប្រទេសចំនួន ៥៤ ភាគច្រើន នៅអាស៊ីកណ្ដាល អឺរ៉ុបភាគកណ្ដាល និងអឺរ៉ុបភាគខាងកើត និងអឺរ៉ុបភាគខាងលិច - កុមារដែលបានចុះឈ្មោះចូលរៀន នៅសាលាបឋមសិក្សាស្ទើរតែទាំងអស់ ទំនងជារៀនដល់ថ្នាក់ចុងក្រោយ មុនឆ្នាំ ២០១៥។ ប៉ុន្តែ នៅក្នុងប្រទេសចំនួន ៣២ ភាគច្រើននៅ អាហ្វ្រិចសាប់សាហារ៉ា មានកុមារយ៉ាងហោចណាស់ ២០% ដែលទំនងជាធ្លាប់បោះបង់ចោលការសិក្សា។

## មានការសម្រេចបានវឌ្ឍនភាពជាច្រើនខាងការលុបបំបាត់ថ្លៃសិក្សា

ឥឡូវនេះ ការសិក្សានៅតាមប្រទេសភាគច្រើន ជាគោលការណ៍ គឺធ្វើឡើង ដោយមិនគិតថ្លៃ។ នៅអាហ្វ្រិចសាប់សាហារ៉ា ចាប់តាំងពីឆ្នាំ ២០០០ មក ប្រទេសចំនួន ១៥ បានអនុម័តច្បាប់ ដែលលុបបំបាត់ការបង់ថ្លៃសិក្សា។ ដោយហេតុថាឧបសគ្គពាក់ព័ន្ធ នឹងចំណាយ ចំពោះការចូលរៀននៅតែមាន ការលុបចោលការបង់ថ្លៃសិក្សាមានឥទ្ធិពលវិជ្ជមានយ៉ាងធំធេង មកលើការចុះឈ្មោះចូលរៀន នៅក្នុងឆ្នាំ ក្រោយពីច្បាប់ទាំងនេះត្រូវបានដាក់អនុវត្ត។ វឌ្ឍនភាពបែបនេះ អាចកើតឡើង មួយផ្នែកដោយសារតែមានការកើនឡើងនូវធនធានហិរញ្ញវត្ថុ សម្រាប់ការអប់រំ។ ការលុបចោលការបង់ថ្លៃសិក្សាក៏ធ្វើឡើង ដោយសារតែនយោបាយក្នុងស្រុកផងដែរ ៖ នេះគឺជារបៀបវារៈពេញនិយមសម្រាប់ការបោះឆ្នោត នៅតាមប្រទេសនៅអាហ្វ្រិច ដែលមានចំណូលទាប។

ការកើនឡើងភ្លាមៗនូវចំនួនកុមារចុះឈ្មោះចូលរៀនក្រោយពេលមានការលុបបំបាត់ការបង់ថ្លៃសិក្សា អាចដាក់បន្ទុកដល់ប្រព័ន្ធអប់រំបឋមសិក្សា ដូចដែលបង្ហាញ តាមរយៈបទពិសោធន៍ កាលពីទសវត្សរ៍ ១៩៩០។ ដូច្នេះ ចាប់តាំងពីពេលនោះមក ប្រទេសភាគច្រើនបានប្រើប្រាស់វិធីសាស្ត្រជាជំហានៗ។ ប៉ុន្តែ ជំនួយដែលផ្ដល់តាមរយៈគំនិតផ្ដួចផ្ដើមលុបបំបាត់ការបង់ថ្លៃសិក្សា ដើម្បីពង្រីកប្រព័ន្ធអប់រំជារឿយៗពុំមានលក្ខណៈគ្រប់គ្រាន់ អនុវត្តមិនបានល្អ និងផ្ដោតមិនចំគោលដៅ។

## អភិក្រមមួយចំនួនទទួលបានជោគជ័យ នៅក្នុងការបង្កើនតម្រូវការ

ការចូលរៀនកម្រិតនឹងផ្ដល់ដោយមិនគិតថ្លៃណាស់ បើទោះបីជាមានការប្ដេជ្ញាចិត្តក្នុងច្បាប់ និងគោលនយោបាយចំពោះ ការលុបចោលការបង់ថ្លៃក៏ដោយ ដោយហេតុថាមានចំណាយជាច្រើនផ្សេងទៀត ដែលគ្រួសារត្រូវរ៉ាប់រង។ គំនិតផ្ដួចផ្ដើម ដើម្បីបង្កើនតម្រូវការបញ្ជូនកូនទៅរៀននៅបឋមសិក្សា កាត់បន្ថយបន្ទុកផ្នែកហិរញ្ញវត្ថុ ដូចជាសម្រាប់ការធ្វើដំណើរ អាហារថ្ងៃត្រង់នៅសាលារៀន និងឯកសណ្ឋានសាលារៀន ជាដើម។ កម្មវិធីគាំពារសង្គមមានដាក់បញ្ចូលនូវវិធានការខាងតម្រូវការ សំដៅធ្វើឱ្យសេវាអប់រំកាន់តែមានភាពប្រសើរជាងមុន ដូចជា ការផ្ទេរសាច់ប្រាក់ កម្មវិធីផ្ដល់អាហារតាមសាលារៀន អាហារូបករណ៍ ប្រាក់ឧបត្ថម្ភ និងប្រាក់ឧបត្ថម្ភបន្តការសិក្សានៅមហាវិទ្យាល័យជាដើម។

*កម្មវិធីផ្ដល់អាហារតាមសាលារៀន*

គំនិតផ្ដួចផ្ដើមស្បៀងសម្រាប់ការអប់រំ បានគ្របដណ្ដប់ដល់កុមារ ៣៦៨ លាននាក់ នៅក្នុងប្រទេសចំនួន ១៦៩។ កម្មវិធី ផ្ដល់អាហារតាមសាលារៀន មិនត្រឹមតែជួយឱ្យកុមារដែលទៅរៀនមានសុខភាពល្អប៉ុណ្ណោះទេ ប៉ុន្តែកុមារដែលចូលរួមក្នុងកម្មវិធីនេះ ច្រើនតែសិក្សា និងមានវត្តមានក្នុងសាលារៀនបានជាប់លាប់ជាងកុមារដែលមិនបានចូលរៀន។

*កម្មវិធីផ្ទេរសាច់ប្រាក់*

ការផ្ទេរសាច់ប្រាក់ដល់គ្រួសារងាយរងគ្រោះ ត្រូវបានបង្កើតដំបូង នៅអាមេរិចឡាទីន ត្រូវបានប្រើប្រាស់ជាទូទៅនៅតាមប្រទេសដែលមានចំណូលកម្រិតមធ្យម និងទាបនៅអាស៊ី និងអាហ្វ្រិចសាប់សាហារ៉ា។ កម្មវិធីផ្ទេរសាច់ប្រាក់ភាគច្រើន បានបង្កើនការចូលរៀន និងវត្តមានរបស់កុមារ និងបានកាត់បន្ថយការបោះបង់ចោលការសិក្សា។

ការផ្ដល់សេវាអប់រំបឋមសិក្សានៅសាលារៀនឯកជន មានការកើនឡើងយ៉ាងហោចណាស់ទ្វេដងនៅតាមប្រទេសជាច្រើន

ប៉ុន្តែ ការផ្ទេរសាច់ប្រាក់ មិនមែនចេះតែនាំឱ្យមានការកែលំអលទ្ធផលនៃការអប់រំសម្រាប់ក្រុមងាយរងគ្រោះនោះទេ។

មានការជជែកវែកញែកអំពីថាតើការផ្ទេរសាច់ប្រាក់ គួរតែមានអមជាមួយនឹងលក្ខខណ្ឌ ដែរឬទេ។ កម្មវិធីនានា អាចទទួលបានការគាំទ្រខាងនយោបាយកាន់តែងាយប្រសិនបើកម្មវិធីទាំងនោះដាក់លក្ខខណ្ឌឱ្យកុមារមករៀននៅសាលា។ ការផ្ទេរសាច់ប្រាក់ ដែលដាក់លក្ខខណ្ឌបែបនេះ មានឥទ្ធិពលមកលើការអប់រំ ជាងការផ្ទេរសាច់ប្រាក់ដែល គ្មានលក្ខខណ្ឌ។

កុមាររៀននៅតាមសាលា ដែលរៀនយឺត ជាងកុមារក្នុងវ័យស្របាល ពួកគេនៅតាមប្រទេសជាច្រើន

## អន្តរាគមន៍ខាងការផ្គត់ផ្គង់បានជួយបង្កើនការចូលរៀននៅបឋមសិក្សា

គម្រោងហេដ្ឋារចនាសម្ព័ន្ធដូចជា ការសាងសង់សាលារៀន និងផ្លូវថ្នល់ជាដើម មានឥទ្ធិពលធំធេងមកលើការទទួលបានការអប់រំ។ កន្លងមក មានការកើនឡើងនូវអន្តរាគមន៍ខាងសុខភាព ដែលក៏មានឥទ្ធិពលយ៉ាងសំខាន់មកលើលទ្ធផលនៃការអប់រំផងដែរ។ លើសពីនេះ គ្រឹះស្ថានមិនមែនរដ្ឋាភិបាល ដូចជា សាលារៀនឯកជន សាលារៀនសហគមន៍ និងសាលារៀនក្រៅប្រព័ន្ធជាដើម កំពុងតែបង្កើនការផ្តល់សេវាអប់រំ អមជាមួយនឹងសាលារៀនរដ្ឋ។

### *ការសាងសង់សាលារៀន និងបន្ទប់រៀន*

ជារឿយៗ ការមានអគារសិក្សា ត្រូវបានចាត់ទុកថាជាជំហានទី ១ ដើម្បីឱ្យកុមារអាចមករៀននៅសាលារៀនបាន។ ឧទាហរណ៍ នៅក្នុងប្រទេសម៉ូហ្សំប៊ិច ការលុបចោលការបង់ថ្លៃសិក្សា និងការបង្កើនចំនួនសាលារៀនបឋមសិក្សា និងសាលារៀនមធ្យមសិក្សា ៣ ដង ចន្លោះពីឆ្នាំ ១៩៩២ និង ២០១០ បានកាត់បន្ថយចំនួនសិស្ស ដែលមិនបានទៅសាលារៀន ក្នុងចំនួនដ៏ច្រើន។

### *ការកែលំអវិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យសុខាភិបាល*

ប្រទេសជាច្រើន បានកែលំអហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ អគ្គិសនី និងទឹក ដែលបង្កើនការចូលរៀនក្នុងសាលា។ ការសិក្សារបស់ក្មេងស្រី គឺមានទំនាក់ទំនងពិសេស ជាមួយនឹងចំងាយ និងការកែលំអហេដ្ឋារចនាសម្ព័ន្ធ ដោយប្រទេសឥណ្ឌា គឺជាឧទាហរណ៍ដ៏សំខាន់មួយ។

### *គ្រឹះស្ថានឯកជន និងគ្រឹះស្ថានមិនមែនរដ្ឋាភិបាលផ្សេងទៀត បានក្លាយជាអ្នកផ្តល់សេវាអប់រំដ៏សំខាន់*

តួនាទីរបស់សាលារៀនឯកជន នៅក្នុងការអប់រំមានការកើនឡើងនៅក្នុងរយៈពេល២ទសវត្សចុងក្រោយនេះ។ នៅអាស៊ីខាងត្បូង មានកុមារអាយុពី ៦ ដល់ ១៨ ឆ្នាំ ១ ភាគ ៣ បានចូលរៀននៅសាលាឯកជន។ ភាគរយនៃការចូលរៀនកម្រិតបឋមសិក្សា នៅសាលាឯកជន មានការកើនឡើងយ៉ាងហោចណាស់ទ្វេដង នៅតាមប្រទេសជាច្រើន នៅរដ្ឋអារ៉ាប់ អឺរ៉ុបភាគកណ្តាល និងខាងកើត និងអាហ្វ្រិចសាប់សាហារ៉ា។

**សាលារៀនសហគមន៍ ជារឿយៗ មានភាពបត់បែនខ្ពស់ មានប្រសិទ្ធភាពចំណាយ ផ្តោតចំលើសិស្ស និងឆ្លើយតបចំពោះតម្រូវការនៅមូលដ្ឋាន ជាងសាលារៀនរបស់រដ្ឋាភិបាល។ សាលារៀនសហគមន៍ជាច្រើន ផ្តល់កម្មវិធីអប់រំនៅតាមតំបន់ ដែលពុំទាន់ មានសេវាគ្រប់គ្រាន់ពីរដ្ឋាភិបាល ដូចជា នៅក្នុងប្រទេសហ្គាណា សាធារណរដ្ឋតង់ហ្សានី និងហ្សាំបៀ ជាដើម។**

**មជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធ** ផ្តល់កម្មវិធីពន្លឿនការរៀនសូត្រ ដែលមានភាពទន់ភ្លន់ សម្រាប់ធ្វើជាស្ពានភ្ជាប់ទៅកាន់ការអប់រំក្នុងប្រព័ន្ធ សម្រាប់កុមារតូចៗ ដែលខកឱកាសចូលរៀន។ នៅក្នុងប្រទេសបង់ក្លាដេស អង្គការមិនមែនរដ្ឋាភិបាលធំមួយ ដែលមានឈ្មោះថា BRAC បានដំណើរការសាលារៀនក្រៅប្រព័ន្ធរាប់ពាន់សាលារៀន។

**សាលារៀនសាសនា បំពេញតម្រូវការរបស់មាតាបិតាជាច្រើននាក់។ នៅក្នុងប្រទេសអាហ្វហ្គានីស្ថាន បង់ក្លាដេស ឥណ្ឌូនេស៊ី និងប៉ាគីស្ថាន សាលារៀនឥស្លាម ដែលគេហៅថា** madrasas បានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់ការអប់រំដល់ក្រុម ដែលមិនសូវមានឱកាស។ អង្គការ Fe y Alegria នៅអាមេរិចឡាទីន បានបង្កើនការចុះឈ្មោះ

ចូលរៀនដល់កុមារប្រមាណជា ១ លាននាក់ នៅក្នុងប្រទេស ចំនួន ១៧។

## *ការផ្តល់សេវាដល់ក្រុមមិនមានឱកាស មានសារៈសំខាន់ ចំពោះសកលកម្មនៃការអប់រំបឋមសិក្សា*

វឌ្ឍនភាពខាងច្បាប់ និងគោលនយោបាយ បានបង្កើនការរៀននៅបឋមសិក្សា ដល់កុមារជួបការលំបាកជាច្រើនក្រុម។ ប៉ុន្តែ ក្រុមដែលបាត់បង់ឱកាស បន្តជួបនឹងឧបសគ្គក្នុងការទទួលបានការអប់រំ ដោយសារតែភាពក្រីក្រ យេនឌ័រ វណ្ណៈ ជាតិពន្ធុ និងភាសា ពូជសាសន៍ ពិការភាព ទីតាំងភូមិសាស្ត្រ និងកម្រិតជីវភាពរស់នៅ។ កុមារជួបការលំបាក ជារឿយៗ រងផលប៉ះពាល់ ដោយសារការលំបាកជាច្រើន ដែលការលំបាកមួយ នាំឱ្យមានការលំបាកមួយទៀត ទៅវិញទៅមក។

## *ជនជាតិភាគតិច និងក្រុមភាសាភាគតិច*

នៅតាមប្រទេសជាច្រើន មានគម្លាតដ៏ធំនៅក្នុងការចូលរៀន និងការបញ្ចប់ការសិក្សារវាងប្រជាជនភាគច្រើន ដែលនិយាយភាសាដែលមានគេនិយាយច្រើននៅក្នុងប្រទេស និងក្រុមភាគតិច ដែលនិយាយភាសាផ្សេងទៀត។ នៅក្នុងបរិបទមួយចំនួន ការបង្រៀនដោយភាសាកំណើត និងពីរភាសា ត្រូវបានគេមើលឃើញថា បានបង្កើនការទទួលបានអប់រំសម្រាប់កុមារដែលនិយាយភាសាភាគតិច។ ប៉ុន្តែ សំណួរ

ជម្លោះនៅតែជារបាំងដ៏ស្រួចស្រាវមួយសម្រាប់ការអប់រំរបស់កុមារជាច្រើននាក់



Credit: Philippe Body

នៅតែមានអំពីគុណភាពនៃការអប់រំ ដែលត្រូវបានផ្តល់ជាភាសាទាំងនេះ។

### *កុមារដែលធ្វើការងារ*

ពលកម្មកុមារ មានផលប៉ះពាល់លើការទទួលបានការអប់រំ និងការបញ្ចប់ការសិក្សា។ ការមានសេវាអប់រំ និងការពង្រឹងការអនុវត្តច្បាប់អប់រំ អាចកាត់បន្ថយពលកម្មកុមារ ដែលនាំឱ្យលទ្ធផលខាងការអប់រំកាន់តែប្រសើរជាងមុន និងកាត់បន្ថយភាពក្រីក្រ។ ចំនួនកុមារអាយុពី ៥ ដល់ ១១ ឆ្នាំ ដែលចូលរួមក្នុងពលកម្មកុមារ បានថយចុះពី ១៣៩ លាននាក់ នៅក្នុងឆ្នាំ ២០០០ មក ៧៣ លាននាក់ នៅក្នុងឆ្នាំ ២០១២។ នៅតាមប្រទេសជាច្រើន សិស្សសាលា ដែលធ្វើការត្រូវបានរកឃើញថា ពេលដល់ អាយុ ១៣ ឆ្នាំ ពួកគេមិនបានរៀនឡើងថ្នាក់ ដូចសិស្សរៀនស្របាលពួកគេ ដែលមិនមែនជាអ្នកធ្វើការនោះទេ។

### *សហគមន៍ពនេចរ*

ប្រជាពលរដ្ឋរស់នៅតាមវាលស្មៅ នៅតែស្ថិតក្នុងចំណោមក្រុមដែលទទួលបានសេវាអប់រំតិចតួចជាងគេនៅក្នុងសកលលោកនេះ។ ចាប់តាំងពីឆ្នាំ ២០០០ មកផែនការអប់រំសម្រាប់ក្រុមពនេចរ ត្រូវបានរៀបចំឡើងនៅក្នុងប្រទេសអេត្យូពី នីហ្សេរីយ៉ា ស៊ូដង់ និងសាធារណរដ្ឋតង់ហ្សានី ប៉ុន្តែមិនបានបង្កើនការចុះឈ្មោះចូលរៀនឡើយ។ ការរៀនសូត្រដោយចំហ ពីចំងាយ ដែលជាគំរូដ៏មានសារៈប្រយោជន៍ជាសក្តានុពល សម្រាប់សហគមន៍ពនេចរ នៅតែមានកម្រិតនៅឡើយ។

### *កុមារដែលរងផលប៉ះពាល់ដោយសារមេរោគ និងជំងឺអេដស៍*

ចាប់តាំងពីក្របខ័ណ្ឌដាកាមក ការកើនឡើងនូវការផ្តល់ថវិកា គោលនយោបាយ និងសេវាគាំទ្រ ពាក់ព័ន្ធជាមួយនឹងកុមារ ដែលរងផលប៉ះពាល់ដោយសារមេរោគ និងជំងឺអេដស៍ បានផ្តោតការយកចិត្តទុកដាក់លើការថែទាំ ការព្យាបាល និងសុខុមាលភាព សង្គមរបស់ពួកគេ ប៉ុន្តែមិនបានផ្តល់អាទិភាពលើការអប់រំឡើយ។ គោលនយោបាយដំបូងៗ ដែលផ្តោតលើការទទួលបានការអប់រំ សម្រាប់កុមារកំព្រា និងកុមារងាយរងគ្រោះ លេចចេញជារូបរាងនៅពាក់កណ្តាលទសវត្សរ៍ ២០០០។ ប្រទេសជាច្រើននៅអាហ្វ្រិចសាប់សាហារ៉ា និងអាស៊ីភាគខាងត្បូង និងខាងលិច បានរៀបចំនូវផែនការសកម្មភាពជាតិ សម្រាប់កុមារទាំងនោះ តាំងពីពេលនោះមក។

### *កុមាររស់នៅតាមតំបន់មិនរៀបរយ*

នៅក្នុងឆ្នាំ ២០០០ រដ្ឋាភិបាលភាគច្រើនមានមតិផ្ទុយគ្នាអំពីការផ្តល់ការអប់រំ នៅតាមតំបន់សំណង់មិនរៀបរយ។ ចាប់តាំងពីពេលនោះមក បញ្ហារបស់អ្នករស់នៅក្នុងសំណង់មិនរៀបរយ បានក្លាយជាបញ្ហាកាន់តែមានសារៈសំខាន់ជាពិសេស នៅពេលដែលមានការធ្វើទេសន្តរប្រវេសន៍ក្នុងចំនួនដ៏ច្រើនពីតំបន់ជនបទមក។ នៅក្នុងករណីដែលមិនមានគោលនយោបាយ និងផែនការគ្រប់គ្រងពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនបានបំពេញតួនាទីយ៉ាងសំខាន់។ សាលារៀនឯកជន ដែលយក ថ្លៃទាបបានកើនឡើងច្រើន នៅតាមតំបន់សំណង់ មិនរៀបរយក្នុងប្រទេសនានា ដូចជា ប្រទេសឥណ្ឌា កេនយ៉ា និង នីហ្សេរីយ៉ា ជាដើម។

### *កុមារពិការ*

មានកុមារចន្លោះពី ៩៣ លាននាក់ ដល់ ១៥០ លាននាក់ ត្រូវបានគេប៉ាន់ប្រមាណថា ជាកុមារពិការ ដែលនាំឱ្យពួកគេកាន់តែងាយត្រូវបានគេផាត់ចេញពីការអប់រំ។ នៅតាមប្រទេសកំពុងអភិវឌ្ឍ ពិការភាព ច្រើនតែមានទំនាក់ទំនងជាមួយនឹងភាពក្រីក្រ ហើយពិការភាពនេះធ្វើឱ្យរាំងស្ទះដល់ការទទួលបានអប់រំ ជាងកត្តាផ្សេងទៀត ដូចជា ស្ថានភាពសង្គម-សេដ្ឋកិច្ច កន្លែងរស់នៅជនបទ ឬយេនឌ័រ។ ក្មេងស្រីពិការ អាចជួបប្រទះការលំបាកជាពិសេស។ ការទទួលបានការអប់រំរបស់កុមារពិការ ជារឿយៗត្រូវទទួលរងការកំហិត ដោយសារតែកង្វះការយល់ដឹងអំពីទម្រង់ផ្សេងៗនៃពិការភាព និងពីតម្រូវការរបស់កុមារពិការ ក៏ដូចជាកង្វះការបណ្តុះបណ្តាលគ្រូ និងការពុំមានសម្ភាររូបវន្តគ្រប់គ្រាន់ និងអាកប្បកិរិយារើសអើងចំពោះពិការភាព និងលក្ខណៈផ្សេងខុសពីគេ។

ប្រទេសជាច្រើន បានចាប់ផ្តើមបញ្ចូលកុមារពិការទៅក្នុងការអប់រំទូទៅ បើទោះបីជាប្រទេសមួយចំនួន នៅតែចង់បានការអប់រំដាច់ពីគេ សម្រាប់កុមារពិការក៏ដោយ។ ក្នុងការអនុវត្តជាក់ស្តែង ប្រទេសភាគច្រើនមានគោលនយោបាយ

កូនកាត់ និងកំពុងកែលំអការអប់រំបែបបញ្ចូលគ្នាបន្តិចម្តងៗ។ អភិក្រម ដែលមានការចូលរួមពីសហគមន៍ មាតាបិតា និង កុមារខ្លួនឯង ទំនងជានឹងផ្តល់នូវដំណោះស្រាយប្រកប ដោយនិរន្តរភាពពាក់ព័ន្ធ និងជម្រុញឱ្យមានការចូលរួម។

## ការអប់រំ នៅក្នុងស្ថានភាពអាសន្ន ដែលមានលក្ខណៈ ស្មុគស្មាញ គឺជាបញ្ហាដែលមានការរីឡ

ការអប់រំ នៅក្នុងស្ថានភាពអាសន្នស្មុគស្មាញ ដូចជា នៅក្នុងស្ថានភាពដែលមានសង្គ្រាម ការបះបោរក្នុងប្រទេស និងការផ្លាស់ទីរបស់មនុស្សក្នុងទ្រង់ទ្រាយធំ គឺជាបញ្ហាដែល មានការរីឡ និងជាបញ្ហាធ្ងន់ធ្ងរមួយ។ ស្ថានភាពអាសន្ន អាចនាំឱ្យមានការ វាយប្រហារលើ សាលារៀន ឬអំពើ ហិង្សាផ្លូវភេទក្នុងចំនួនច្រើន ដែលនាំឱ្យក្រុមដែលជួបការ លំបាកទៅហើយ កាន់តែរងការលំបាកបន្ថែមទៀត។ ក្មេង ប្រុស និងក្មេងស្រី ប្រឈមនឹងការជ្រើសរើសធ្វើការងារ ដោយបង្ខំ ពេលខ្លះត្រូវបានជ្រើសចេញពីថ្នាក់រៀនរបស់ ពួកគេតែម្តង និងកេងប្រវ័ញ្ចធ្វើជាទាហានជួរមុខ ជាគិញ សំងាត់ ជាអ្នកបំផ្ទុះគ្រាប់បែបអត្តឃាត ឬជាទាសករ ផ្លូវភេទ។ ក្មេងស្រី ជាអ្នកងាយរងគ្រោះពិសេស នៅក្នុងស្ថានភាព ជម្លោះបែបនេះ។

ចាប់តាំងពីឆ្នាំ ២០០០ មក បណ្តាញអន្តរភ្នាក់ងារ សម្រាប់ការអប់រំក្នុងស្ថានភាពអាសន្ន បានក្លាយខ្លួនជា បណ្តាញ ដ៏ធំមួយ របស់អង្គការ និងបុគ្គល នៅក្នុងជាង ១៧០ ប្រទេស។ ការកំណត់ស្តង់ដាអប្បបរមា សម្រាប់ ការអប់រំ នៅក្នុងស្ថានភាពអាសន្ន កាលពីឆ្នាំ ២០០៣ គឺជា ជំហានដ៏មានសារៈសំខាន់មួយ។ ជំហានសំខាន់មួយទៀត គឺការបង្កើនការសន្យាផ្តល់ជំនួយហិរញ្ញវត្ថុពីសំណាក់ភាព ជាដៃគូសកលសម្រាប់ការអប់រំ។ ប៉ុន្តែ បើទោះបីជាមាន ភាពជឿនលឿនទាំងនេះក៏ដោយ កង្វះថវិកាសម្រាប់ការអប់រំ នៅក្នុងកញ្ចប់ថវិកាសម្រាប់មនុស្សធម៌ នៅតែជាបញ្ហាដ៏ធំ មួយ។



# ប័ណ្ណរាយការណ៍ ២០០០-២០១៥

## គោលដៅទី ៣ ជំនាញសម្រាប់យុវជន និងមនុស្សពេញវ័យ

**ធានាឱ្យមានការឆ្លើយតបចំពោះតម្រូវការរៀនសូត្ររបស់យុវជន និងមនុស្សពេញវ័យទាំងអស់ តាមរយៈការចូលរួមក្នុងកម្មវិធីរៀនសូត្រ និងកម្មវិធីបំណិនជីវិតប្រកបដោយសមធម៌**

### ពិន្ទុសកល *

*ក្នុងចំណោមប្រទេសចំនួន ១៦៧ ដែលមានទិន្នន័យ
- ការចុះចូលរៀននៅកម្រិតអនុវិទ្យាល័យ

| នៅឆ្ងាយខ្លាំងពីគោលដៅ | នៅឆ្ងាយពីគោលដៅ | កៀកនឹងគោលដៅ | បានសម្រេចគោលដៅ |
|---|---|---|---|
| 2% | 21% | 5% | 71% |

### ជោគជ័យ

**ការចុះឈ្មោះចូលរៀន**

↑27%
សកលលោកទាំងមូល

ជាងពីរដង
នៅអាហ្វ្រិច សាប់សាហារ៉ា
1999
បច្ចុប្បន្ននេះ

**អត្រារួមនៃការសិក្សាមានការកើនឡើង**




**ចំនួនក្មេងជំទង់ក្រៅសាលាមានការថយចុះ**

1999
99 លាននាក់
2012
63 លាននាក់

### កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើង

**សាលាមធ្យមសិក្សាបឋមភូមិ**

**94**
ប្រទេស ផ្តល់ដោយមិនគិតថ្លៃ
ប្រទេសមួយចំនួនបានដាក់បញ្ចូល ទៅក្នុងការអប់រំថ្នាក់មូលដ្ឋាន

**27** ប្រទេស
កំណត់ការអប់រំ កម្រិតនេះថាជាការអប់រំតម្រូវដោយច្បាប់
ចាប់តាំងពីឆ្នាំ ២០០០ មក ប្រទេសជាច្រើនផ្អាកការប្រឡងចូល

**ការរៀបចំឱ្យមានការវាយតម្លៃផ្ទាល់លើជំនាញ**

PIAAC
STEP

**ចាប់តាំងពីឆ្នាំ ២០០០ មក**
មានការយល់ដឹងច្រើនជាងមុន អំពីមេរោគ និងជំងឺអេដស៍

### បញ្ហាប្រឈមដែលនៅបន្តមាន

**ក្មេងជំទង់ក្រៅសាលា**

63
លាននាក់
នៅក្នុងឆ្នាំ 2012

**ការបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ**

ក្មេងជំទង់ ១ ភាគ ៣ នៅក្នុងប្រទេសដែលមានចំណូលទាប និងមធ្យម នឹងមិនបានរៀនចប់មធ្យមសិក្សាបឋមភូមិឡើយ នៅក្នុងឆ្នាំ ២០១៥

**ជំនាញ**

?
កង្វះភាពច្បាស់លាស់ អំពី ប្រភេទជំនាញ

**យុវជនដែលធ្វើការងារ**

ចំនួនមិនបានថយចុះ

**ការអប់រំឱកាសទី ២**

ភាពចាំបាច់ដែលមានយូរយាមកហើយ ដើម្បីបង្កើនការចូលរៀន

### វិឱ្សមភាពមិនស្មើគ្នា

**ការចុះឈ្មោះចូលរៀននៅកម្រិត មធ្យមសិក្សាបឋមភូមិ/ទុតិយភូមិ**




**ទ្រព្យសម្បត្តិ**

ចាប់តាំងពីឆ្នាំ ២០០០ មក គម្លាតរវាងការឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិ ទៅទុតិយភូមិរវាងកុមារមកពីគ្រួសារជីវភាពធូរធា និងកុមារមកពីគ្រួសារក្រីក្រ មានការប្រែប្រួលតិចតួច

**ទីតាំង**

មានប្រទេសមួយចំនួនតូច ដែលបានកាត់បន្ថយបានយ៉ាងច្រើន នូវវិសមភាពរវាងតំបន់ជនបទ និងតំបន់ប្រជុំជន នៃការចូលរៀននៅសាលា មធ្យមសិក្សាបឋមភូមិ (ជាពិសេស ប្រទេសវៀតណាម នេប៉ាល់ និងឥណ្ឌូនេស៊ី)

### អនុសាសន៍ សម្រាប់ក្រោយឆ្នាំ ២០១៥

១. ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ត្រូវតែធ្វើឲ្យមានជាសកល
២. កម្មវិធីរៀនសូត្រឱកាសទី ២ ត្រូវតែពង្រីកបន្ថែមទៀត
៣. ចាំបាច់ត្រូវមានការកំណត់ពីនិយមន័យជំនាញឲ្យបានប្រសើរជាងមុន និងទិន្នន័យពាក់ព័ន្ធក្រោយ ២០១៥

ឱកាសក្នុងការធ្វើឲ្យប្រសើរឡើង

# គោលដៅទី ៣ ជំនាញសម្រាប់យុវជន និងមនុស្សពេញវ័យ

*ធានាឱ្យមានការឆ្លើយតបចំពោះតម្រូវការរៀនសូត្ររបស់យុវជន និងមនុស្សពេញវ័យទាំងអស់តាមរយៈការចូលរួមក្នុងកម្មវិធីរៀនសូត្រ និង កម្មវិធីបំណិនជីវិតប្រកបដោយសមធម៌*

គោលដៅអប់រំសម្រាប់ទាំងអស់គ្នាទី ៣ នេះ មិនត្រឹមតែផ្តោតលើការអប់រំក្រៅផ្លូវការក្នុងសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តោតលើបទពិសោធន៍ ក្រៅសាលាទៀតផង ដូចជា ការបណ្តុះបណ្តាលនៅកន្លែងធ្វើការជាក់ស្តែង និងឱកាសផ្សេងទៀត នៅក្នុងជីវិត។ ការផ្តោតទូលាយពេករបស់គោលដៅទី ៣ នេះ ធ្វើឱ្យបាត់បង់នូវភាពច្បាស់លាស់ ៖ គោលដៅនេះខ្វះចំណុចដៅច្បាស់លាស់ ដែលអាចវាស់វែងបាន និងលើកឡើងពីផលសម្រេចមួយ គឺបំណិនជីវិតដែលគេអាចយល់បានច្រើនបែបច្រើនយ៉ាង។

របាយការណ៍ពិនិត្យតាមដានសកលនេះផ្តោតលើជំហាន ៣ ប្រភេទ។ ជំនាញជាមូលដ្ឋាន សំដៅលើជំនាញទាំងឡាយដែលចាំបាច់ដើម្បីបានការងារធ្វើឬបន្តការបណ្តុះបណ្តាល។ ជំនាញដែលអាចផ្ទេរបាន អាចកែសម្រួលឱ្យស្របតាមបរិស្ថានផ្សេងៗ ដូចជា បរិស្ថានពាក់ព័ន្ធនឹងការងារជាដើម។ ជំនាញបច្ចេកទេស និងវិជ្ជាជីវៈ សំដៅលើចំណេះធ្វើជាក់លាក់ ដែលពាក់ព័ន្ធនឹងសកម្មភាពការងារជាក់លាក់។

សូចនាករសំខាន់ជាងគេ ដែលបង្ហាញពីវឌ្ឍនភាពនៃឱកាសទទួលបានជំនាញមូលដ្ឋាន គឺការចូលរៀនក្នុងសាលាមធ្យមសិក្សា។ បើទោះបីជា មានវឌ្ឍនភាពធំមួយខាងការពង្រីកការចូលរៀននៅសាលាមធ្យមសិក្សាបឋមភូមិ និងអាចដល់ទុតិយភូមិក៏ដោយ វិសមភាពពាក់ព័ន្ធនឹងចំណូល និងទីតាំងនៅតែមាន។ កុមារជាច្រើននាក់ ជាពិសេស កុមារមកពីគ្រួសារក្រីក្រ ជារឿយៗ ត្រូវបំពេញការងារ ដែលមានផលប៉ះពាល់ជាអវិជ្ជមានមកលើការចូលរួម ការបន្តការសិក្សា និងជោគជ័យរបស់ពួកគេ នៅក្នុងការអប់រំកម្រិតមធ្យមសិក្សា។ ស្ថានភាពខាង ច្បាប់មួយចំនួនរបស់កុមារចំណាកស្រុកច្រើននាក់ ធ្វើឱ្យពួកគេត្រូវទទួលរងការលំបាក

ការផ្តោតទូលាយពេករបស់គោលដៅទី ៣ នេះ ធ្វើឱ្យបាត់បង់នូវភាពច្បាស់លាស់

**រូបភាពទី ៦ ៖ ភាគរយក្មេងជំទង់ក្នុងសាលា បានកើនឡើង ១២ ភាគរយចំណុច នៅក្នុងរយៈពេលនៃក្របខ័ណ្ឌដាការនេះ**

អត្រាពិត្យនៃការសិក្សាសរុបនៅកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងពិភពលោក និងតាមតំបន់ ១៩៩០-២០១២ និង ២០១៥ (ចំណោល)




*ប្រភព ៖* មូលដ្ឋានទិន្នន័យ *UIS: Bruneforth (2015)*

បន្ថែមទៀត លុះត្រាតែប្រទេសនានាធានាយ៉ាងណាឱ្យកុមារទាំងនោះបានទទួលការអប់រំនៅកម្រិតមធ្យមសិក្សា។

## ជំនាញមូលដ្ឋាន ៖ ការចូលរួមក្នុងការទទួលបានការអប់រំកម្រិតមធ្យមសិក្សា មានការកើនឡើង

ជំនាញមូលដ្ឋាន រួមមាន ជំនាញអក្ខរកម្ម និងលេខនពន្ធ ដែលចាំបាច់ ដើម្បីមានការងារសមរម្យធ្វើ ពោលគឺការងារដែលផ្ដល់នូវប្រាក់ឈ្នួលក្នុងកម្រិតគ្រប់គ្រាន់ ដើម្បីបំពេញទៅតាមតម្រូវការប្រចាំថ្ងៃ។ ជំនាញមូលដ្ឋានដែលទទួលបាននៅតាមសាលាមធ្យមសិក្សា ក៏អាចចាត់ទុក ថាជាជំនាញដែលមានសារៈសំខាន់ សម្រាប់អភិវឌ្ឍន៍អាជីព ការបំពេញតួនាទីសកម្មក្នុងនាមជាប្រជាពលរដ្ឋ និងជម្រើសប្រកបដោយសុវត្ថិភាព អំពីសុខភាពផ្ទាល់ខ្លួន។ ការចូលរួមក្នុងការអប់រំកម្រិតមធ្យមសិក្សា មានការកើនឡើងយ៉ាងឆាប់រហ័សចាប់តាំងពីឆ្នាំ ១៩៩៩ មក ដោយមានសិស្សចំនួន ៥៥១ លាននាក់ បានចុះឈ្មោះចូលរៀន នៅក្នុងឆ្នាំ ២០១២។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សា មានការកើនឡើង នៅក្នុងប្រទេសដែលមានចំណូលទាបផង (ពី ២៩% ដល់ ៤៤%) និងប្រទេសចំណូលមធ្យមផង (ពី ៥៦% ដល់ ៧៤%)។

ការលុបចោលការបង់ថ្លៃសិក្សា បានរួមចំណែកបង្កើនការសិក្សានៅកម្រិតមធ្យមសិក្សា។ ក្នុងចំណោម ១០៧ ប្រទេស ដែលមានចំណូលកម្រិតទាប និងមធ្យម ដែលមានទិន្នន័យប្រទេសចំនួន ៩៤ បានដាក់ការផ្ដល់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិដោយមិនគិតថ្លៃ នៅក្នុងច្បាប់។ កំណើនអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា ក្នុងប្រទេសជាច្រើន ក៏បានរួមចំណែកនាំឱ្យមានក្រុមសិស្សកាន់តែច្រើននាក់ជាងមុន អាចបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀតបាន។

តម្រូវការ និងចំណាប់អារម្មណ៍លើការអប់រំកម្រិតមធ្យមសិក្សា តាមសាលាឯកជន មានការកើនឡើងជាងមុន។ ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១២ ភាគរយនៃការចុះឈ្មោះចូលរៀន នៅគ្រឹះស្ថានមធ្យមសិក្សាឯកជន មានការកើនឡើងពី ១៥% ដល់ ១៧% ក្នុងប្រទេសកំពុងអភិវឌ្ឍ។ ការកើនឡើងបែបនេះមានជាពិសេស នៅរដ្ឋអារ៉ាប់ និងអាស៊ីបូព៌ា។

## វិសមភាពក្នុងការអប់រំកម្រិតមធ្យមសិក្សា នៅតែបន្តមាន

ខណៈពេលដែលសកលកម្មនៃការអប់រំមធ្យមសិក្សា កាន់តែត្រូវបានសម្រេចជាបណ្ដើរៗ ជាធម្មតា ការអប់រំកម្រិតនេះត្រូវបានទទួល ដំបូងគេ ដោយក្រុមដែលមានប្រៀប និងក្រោយមក ដោយក្រុមដែលជួបការលំបាក ក្រុមដែលមានជីវភាពក្រីក្រ និងអ្នកដែលរស់នៅតំបន់ជនបទ។ ការទទួលបានការអប់រំមធ្យមសិក្សាបឋមភូមិមិនស្មើគ្នា ជារឿយៗមានន័យថា ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ក៏នៅតែបន្ត ឬក្លាយជាប្រភពនៃវិសមភាព។ និន្នាការនេះត្រូវបានរកឃើញ សូម្បីតែនៅក្នុងប្រទេស ដែលសន្យាថានឹងផ្ដល់ការអប់រំដល់កុមារ ដោយមិនគិតពីលទ្ធភាពបង់ថ្លៃរបស់ពួកគេក៏ដោយ។

បើទោះបីជាការគ្របដណ្ដប់នៃសាលារៀនមានការកើនឡើងក៏ដោយ ក្នុងប្រទេសភាគច្រើន ក្មេងជំទង់ដែលដល់អាយុចូលរៀន នៅសាលាមធ្យមសិក្សាមួយភាគធំ បន្តធ្វើការងារក្រៅសាលារៀន។ កុមារមួយចំនួនបបួលគ្នាបោះបង់ចោលការសិក្សា ខណៈពេលដែលកុមារផ្សេងទៀត ធ្វើការបណ្ដើរ រៀនបណ្ដើរ។ សិស្សដែលរៀនបណ្ដើរ ធ្វើការបណ្ដើរ មានភាពយឺតយ៉ាវ ក្នុងការទទួលបានជំនាញមូលដ្ឋាន។ ភាគរយ សិស្សដែលធ្វើការបណ្ដើរ រៀនបណ្ដើរ ទំនងជាត្រូវបានគេប៉ាន់ប្រមាណមិនដល់ចំនួនពិតប្រាកដ ដោយសារតែមាតាបិតាអាចមានការស្ទាក់ស្ទើរ ក្នុងការប្រាប់ដល់អ្នកសម្ភាសថា កូនរបស់ពួកគេកំពុងធ្វើការងារនៅឡើយ។

ការឆ្លើយតបចំពោះតម្រូវការជំនាញ របស់យុវជនចំណាកស្រុក បានក្លាយជាបញ្ហាបន្ទាន់មួយ នៅគ្រប់តំបន់ទាំងអស់ និងទាមទារឱ្យមានការផ្ដល់ធនធានហិរញ្ញវត្ថុបន្ថែមទៀត។ ការអង្កេតលើគោលនយោបាយទេសន្តរប្រវេសន៍ នៅក្នុងប្រទេសអភិវឌ្ឍចំនួន ១៤ និងប្រទេសកំពុងអភិវឌ្ឍចំនួន ១៤ រកឃើញថា មានប្រទេសអភិវឌ្ឍ ៤០% និងប្រទេសកំពុងអភិវឌ្ឍជាង ៥០ មិនបានអនុញ្ញាត

ឱ្យកុមារដែលពុំមាន ស្ថានភាពស្របច្បាប់ ឱ្យចូលរៀននៅតាមសាលាឡើយ។ គោលនយោបាយអប់រំភាសា មានសារៈសំខាន់យ៉ាងខ្លាំង ចំពោះការអប់រំយុវជនចំណាកស្រុក និងចំពោះការចូលរួមរបស់ពួកគេ ក្នុងទីផ្សារការងារនាពេលអនាគត។

## *ចាំបាច់ត្រូវផ្តល់ការអប់រំតាមជម្រើសផ្សេងៗ ដល់យុវជន និងមនុស្សពេញវ័យ ដែលឈប់រៀនទៅហើយ*

ទន្ទឹមគ្នានឹងការពង្រីកកម្មវិធីអប់រំក្នុងប្រព័ន្ធ ប្រទេសជាច្រើនបានប្តេជ្ញាដោយខ្លួនឯងថា នឹងខិតខំបំពេញតម្រូវការនៃការអប់រំយុវជនក្រៅសាលា និងមនុស្សពេញវ័យដែលលែងមានឱកាសរៀនសូត្រក្នុងប្រព័ន្ធទៀត។ ខាងក្រោម គឺជាឧទាហរណ៍បង្ហាញពី ជម្រើសកម្មវិធីអប់រំក្រៅប្រព័ន្ធ "ឱកាសទីពីរ" មួយចំនួន ៖

នៅក្នុងប្រទេសបង់ក្លាដេស កម្មវិធីរបស់អង្គការ BRAC មានគោលបំណងនាំយកកុមារក្រៅសាលា ឱ្យមកទទួលការអប់រំបឋមសិក្សា និងត្រៀមរៀបចំពួកគេ សម្រាប់ការអប់រំកម្រិតមធ្យមសិក្សា។ អ្នកបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សារបស់កម្មវិធី BRAC ជាង ៩៧% បន្តការសិក្សានៅក្នុងសាលាមធ្យមសិក្សាក្នុងប្រព័ន្ធ។

នៅក្នុងប្រទេសឥណ្ឌា វិទ្យាស្ថានជាតិផ្តល់នូវការអប់រំបើកចំហផ្តល់ "កម្មវិធីអប់រំថ្នាក់មូលដ្ឋានបើកចំហ" ដល់កុមារអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ។ សិស្សក៏ទទួលបានវគ្គសិក្សាវិជ្ជាជីវៈ និងកម្មវិធីបំណិនជីវិតផងដែរ។

គិតត្រឹមឆ្នាំ ២០១១ មានសិស្សសរុបចំនួន ២,២ លាននាក់ ដែលបានទទួលប្រយោជន៍ពីកម្មវិធីទាំងនេះ។

នៅក្នុងប្រទេសថៃ ផែនការសកម្មភាពជាតិ បានបញ្ចូលគោលដៅទី ៣ និងគោលដៅទី ៤ ចូលទៅក្នុងគោលដៅរួមតែមួយ ដោយផ្តោត លើអក្ខរកម្មមនុស្សពេញវ័យ និងលើការអប់រំថ្នាក់មូលដ្ឋាន និងការអប់រំបន្ត សម្រាប់មនុស្សពេញវ័យទាំងអស់។ នេះបង្កើតបានជាជម្រើសមួយ សម្រាប់ក្រុមដែលជួបការលំបាកផ្សេងៗ ដូចជា អ្នកជាប់ពន្ធនាគារ និងកុមារអនាថា ជាដើម។

## ជំនាញដែលអាចផ្ទេរបាន ៖ សមត្ថភាពដែលផ្តល់លទ្ធភាពឱ្យមានការរីកចម្រើនក្នុងសង្គម

បន្ថែមពីលើការសន្យាក្នុងគោលដៅទី ៣ ដើម្បីឱ្យយុវជន និងមនុស្សពេញវ័យបានទទួលឱកាសរៀនសូត្រ និងបំណិនជីវិតប្រកបដោយសមធម៌ ក្របខ័ណ្ឌសកម្មភាពដាកាលើកឡើងថា ៖ "រាល់យុវជន និងមនុស្សពេញវ័យទាំងអស់ត្រូវតែទទួលបានឱកាស ដើម្បីទទួលបានចំណេះដឹង និងអភិវឌ្ឍគុណតម្លៃ អាកប្បកិរិយា និងជំនាញ ដែលនឹងផ្តល់លទ្ធភាពឱ្យពួកគេអភិវឌ្ឍសមត្ថភាពធ្វើការងាររបស់ពួកគេ ចូលរួមពេញ លេញក្នុងសង្គម គ្រប់គ្រងលើជីវិតខ្លួនឯង និងបន្តការរៀនសូត្រទៅមុខទៀត"។ ការពិនិត្យតាមដានលើគោលដៅ ដែលមានលក្ខណៈទូលំទូលាយ បែបនេះ តម្រូវឱ្យមានព័ត៌មានអំពីគុណតម្លៃ អាកប្បកិរិយា និងជំនាញមិនពាក់ព័ន្ធជាមួយនឹងការសិក្សា ដែលកន្លងមក មិនត្រូវបានគេវាយតម្លៃ ជាអន្តរជាតិ ឬរាយការណ៍ប្រព័ន្ធអប់រំជាតិឡើយ។

មានមនុស្សពេញវ័យជិត១០ លាននាក់ បានចូលរួមក្នុងកម្មវិធីអប់រំនានា នៅក្នុងប្រទេសវៀតណាម នៅក្នុងឆ្នាំ២០០៨

របាយការណ៍ពិនិត្យតាមដានសកល ២០១៥ បង្ហាញឱ្យឃើញពីបំណិនជីវិត ២ ប្រភេទ ដែលពាក់ព័ន្ធជាមួយនឹងសុខភាព និងសង្គម ៖ ចំណេះដឹងអំពីមេរោគ និងជំងឺអេដស៍ និងអាកប្បកិរិយា ចំពោះសមភាពយេនឌ័រ។

ចំណេះដឹងអំពីមេរោគនិងជំងឺអេដស៍មានការកើនឡើង ប៉ុន្តែនៅឆ្ងាយពីកម្រិតសកល ៖ ការអង្កេតកាលពីពេលថ្មីៗនេះ បង្ហាញឱ្យឃើញពីការកើនឡើងនូវចំណេះដឹងអំពីមេរោគ និងជំងឺអេដស៍ ក្នុងចំណោមយុវជន នៅក្នុងប្រទេសចំនួន ៩ និងក្នុងចំណោមយុវតី នៅក្នុងប្រទេសចំនួន ១៣។ ប្រទេស ដែលបង្ហាញពីការកើនឡើងជាងគេ ហាក់បីដូចជាប្រទេស ដែលមានការឆ្លងរាលដាលមេរោគអេដស៍ជាងគេ។ ទំនងជាសាលារៀនបានផ្តោតការយកចិត្តទុកដាក់ខ្លាំងជាងមុនលើការអប់រំអំពីមេរោគអេដស៍ នៅក្នុងប្រទេស

ទាំងនេះ ហើយការអប់រំបំណិនជីវិត ក៏ទំនងជាបានបំពេញតួនាទីរួមចំណែកផងដែរ។

អាកប្បកិរិយាចំពោះសមធម៌មេរោគអេដស៍ មិនបានបានរីកចម្រើនដូចៗគ្នានោះឡើយ ៖ នៅក្នុងរយៈពេលជាង ២០ ឆ្នាំចុងក្រោយនេះ ការអង្កេតលើគុណតម្លៃរបស់ពិភពលោក (World Values Survey) បានសួរទៅ អ្នកតបសម្ភាសន៍ថាតើពួកគេយល់ស្របថា ការអប់រំកម្រិត សកលវិទ្យាល័យ មានសារៈសំខាន់ចំពោះបុរស ជាងស្ត្រី ដែរឬទេ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ក្នុងប្រទេសមួយចំនួន (ដូចជា ប្រទេសអ៊ុយក្រែន និងម៉ារ៉ុក) អ្នកតបសម្ភាសន៍ច្រើនតែមិនយល់ស្របជាមួយនឹងការលើកឡើងបែបនេះឡើយ ហើយពួកគេបង្ហាញពីអាកប្បកិរិយាវិជ្ជមាន ចំពោះស្ត្រីដែលទទួលបានការអប់រំខ្ពស់។ ប៉ុន្តែ នៅក្នុងប្រទេសផ្សេងទៀត ពុំមានការប្រែប្រួលឡើយ ហើយនៅក្នុងប្រទេសមួយចំនួន (ដូចជា ប្រទេសគីហ្សីស្ថាន និងប៉ាគីស្ថាន ជាដើម) អាកប្បកិរិយារបស់អ្នកតបសម្ភាសន៍ចំពោះសមធម៌យេនឌ័រ កាន់តែអាក្រក់ជាងមុនទៅទៀត)។

## ជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ៖ អភិក្រមកំពុងមានការវិវឌ្ឍ

ជំនាញបច្ចេកទេស និងវិជ្ជាជីវៈ អាចទទួលបានតាមរយៈការអប់រំកម្រិតមធ្យមសិក្សា និងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈក្នុងប្រព័ន្ធ ឬតាមរយៈការបណ្តុះបណ្តាលនៅកន្លែងធ្វើការ ដូចជា ការហ្វឹកហាត់ធ្វើការងារ និងការបណ្តុះបណ្តាល តាមរយៈសហករណ៍កសិកម្ម ជាដើម។ មានប្រទេសចំនួន ២៨ ដែលបង្ហាញមានការកើនឡើង ឬការថយចុះយ៉ាងច្រើននូវភាគរយសិស្ស ដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីវិជ្ជាជីវៈ ផ្ទុយពីកម្មវិធីចំណេះទូទៅ បើធៀបជាមួយនឹងការចុះឈ្មោះចូលរៀនសរុបនៅកម្រិតមធ្យមសិក្សា។ នៅក្នុងប្រទេសចំនួន ១២ ក្នុងចំណោមប្រទេសទាំងនេះ ភាគរយមានការកើនឡើង ហើយនៅក្នុងប្រទេសចំនួន ១៦ ភាគរយនេះមានការថយចុះ។

នៅក្នុងឆ្នាំ ២០០០ មានអ្នកតស៊ូមតិតែមួយចំនួនតូចដែលគាំទ្រដល់ជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នាងវេទិកាអប់រំពិភពលោកទីក្រុង ដាកា ហើយជាលទ្ធផល គោលដៅទី ៣ មិនត្រូវបានកំណត់ឱ្យបានច្បាស់ឡើយ។ ប៉ុន្តែ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ មានការយកចិត្តទុកដាក់កាន់តែច្រើនជាងមុនលើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេស ពីសំណាក់សហភាពអឺរ៉ុប និងអង្គការ OECD។ មូលហេតុមួយទៀត ដែលនាំឱ្យមានការផ្តោតការយកចិត្តទុកដាក់បែបនេះ គឺដោយសារតែនិយមន័យរបស់ពាក្យថាជំនាញនេះ បានពង្រីកហួសពីជំនាញ ដែលពាក់ព័ន្ធជាមួយនឹងមុខរបរចិញ្ចឹមជីវិតទៅទៀត។ ឥឡូវនេះ អ្នកតស៊ូមតិភាគច្រើន មិនចាត់ទុកការបណ្តុះបណ្តាលជំនាញថាជា ការបណ្តុះបណ្តាលដោយឡែកនោះទេ ប៉ុន្តែជាការបណ្តុះបណ្តាល ដែលមានសារៈសំខាន់ចំពោះការអប់រំចំណេះទូទៅ ដែលផ្តល់នូវជំនាញមូលដ្ឋាន និងជំនាញដែលអាចផ្ទេរបានក្នុងពេលជាមួយគ្នា នឹងជំនាញសម្រាប់ធ្វើការងារដែរ។

## ការអប់រំបន្ត និងការអប់រំមនុស្សពេញវ័យ ៖ ករណីផ្ទុយគ្នាចំនួន ៤

ប្រសិនបើពុំមានការរៀបចំឱកាសឱ្យបានប្រុងប្រយ័ត្ននោះទេ ការអប់រំមនុស្សពេញវ័យច្រើនតែទទួលបាន ដោយអ្នកដែលបានទទួលប្រយោជន៍ពីការអប់រំក្នុងប្រព័ន្ធរួចទៅហើយ។ ប្រទេសចំនួន ៤ ដែលបានព្យាយាមដោះស្រាយបញ្ហាសមភាពឱកាសក្នុងការអប់រំ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានសម្រេចនូវលទ្ធផលខុសៗគ្នា ៖

កម្មវិធីអប់រំជំនាញសម្រាប់យុវជន និងមនុស្សពេញវ័យរបស់ប្រទេសប្រេស៊ីល មានគោលបំណងផ្តោតលើអ្នកដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ដែលមិនបានបញ្ចប់ការអប់រំក្នុងប្រព័ន្ធ។ នៅក្នុងឆ្នាំ ២០១២ មានសិស្សជាង ៣ លាននាក់ បានចុះឈ្មោះសិក្សា ក្នុងនោះមាន ជនចំណាកស្រុក ពលករនៅជនបទ និងអ្នកដែលមកពីគ្រួសារក្រីក្រ ឬគ្រួសារក្នុងវណ្ណៈការងារ។ ប៉ុន្តែ គុណភាពនៃការអប់រំដែលទទួលបាន នៅខ្វះខាត ហើយអត្រាបោះបង់ចោលការសិក្សា នៅមានកម្រិតខ្ពស់។

នៅក្នុងឆ្នាំ ២០០៦ ប្រទេសណរវេ បានជម្រុញឱ្យមានគំនិតផ្តួចផ្តើមធំមួយ ដែលផ្តល់មូលនិធិដល់និយោជកដើម្បីរៀបចំវគ្គសិក្សា សម្រាប់និយោជិត ដែលមានកម្រិតជំនាញទូទៅទាប ដូចជា អក្ខរកម្ម លេខនព្វន្ត បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងការប្រាស្រ័យទាក់

ទងផ្ទាល់មាត់។ ប្រព័ន្ធអប់រំមនុស្សពេញវ័យរបស់ប្រទេសនេះមានលក្ខណៈចម្រុះ ៖ កម្មវិធីក្រៅប្រព័ន្ធ រួមមានផងដែរនូវ "វិទ្យាល័យសម្រាប់មនុស្សពេញវ័យ" សមាគមអប់រំ មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាសម្រាប់ជនអន្តោប្រវេសន៍ និងការអប់រំពីចំងាយ។

កាលពីឆ្នាំ ២០០៧ ប្រទេសកូរ៉េបានធ្វើការកែសម្រួលការសម្របសម្រួលការអភិវឌ្ឍ និងការអនុវត្តការអប់រំមនុស្សពេញវ័យរបស់ខ្លួន។ សកម្មភាពជាច្រើនត្រូវបានរៀបចំឡើងវិញ ដើម្បីកៀងគរអ្នកពាក់ព័ន្ធនានា ដូចជា យុទ្ធនាការជ្រើសរើស និងអភិវឌ្ឍន៍ទីក្រុងដែលផ្តល់ឱកាសរៀនសូត្រពេញមួយជីវិត ជាដើម។ អត្រានៃការចូលរួមមានការកើនឡើងពីប្រហែល ២៦% នៅក្នុងឆ្នាំ ២០០៨ រហូតដល់ប្រហែលជា ៣៦% នៅក្នុងឆ្នាំ ២០១២។ រដ្ឋាភិបាលក៏បានបង្កើតគំនិតផ្តួចផ្តើមចំនួន ៤ ដើម្បីលើកកម្ពស់ជំនាញពាក់ព័ន្ធនឹងការងារ សម្រាប់និយោជិតរបស់សហគ្រាសខ្នាតតូច និងមធ្យមផងដែរ។

នៅក្នុងប្រទេសវៀតណាម ការអប់រំក្រៅប្រព័ន្ធសម្រាប់មនុស្សពេញវ័យ និងកម្មវិធីអក្ខរកម្មមនុស្សពេញវ័យបានក្លាយជាសមាសភាគ សំខាន់នៃប្រព័ន្ធអប់រំទាំងមូល នៅក្នុងឆ្នាំ ២០០៥។ មានមនុស្សជិត ១០ លាននាក់ បានចូលរួមក្នុងកម្មវិធីរៀនសូត្រ និងអប់រំក្រៅប្រព័ន្ធសម្រាប់មនុស្សពេញវ័យ នៅក្នុងឆ្នាំ ២០០៨ បើធៀបជាមួយនឹងត្រឹមតែជាងកន្លះលាននាក់ កាលពីឆ្នាំ ១៩៩៩។

## ការវាស់វែងដោយផ្ទាល់លើជំនាញរឹង និងទន់ កំពុងលេចចេញជារូបរាង នៅតាមប្រទេសជាច្រើន

ជំនាញចិត្តសង្គម (ជំនាញ "ទន់") ជាជំនាញដែលគេអាចរៀន តាមរយៈបទពិសោធន៍ជាវិជ្ជមានក្នុងសាលារៀន និងជាជំនាញដែលអាចមានសារៈសំខាន់ដូចគ្នានឹងជំនាញចំណេះដឹង (ជំនាញ "រឹង") ផងដែរ នៅក្នុងការសម្រេចឱ្យបាននូវលទ្ធផលជាវិជ្ជមានក្នុងទីផ្សារការងារ។ ឧទាហរណ៍ចំនួនពីរ ដែលបង្ហាញពីការវាស់វែងដោយផ្ទាល់លើជំនាញរឹង និងទន់ គឺការសិក្សាលើកម្មវិធីវាយតម្លៃជាអន្តរជាតិលើសមត្ថភាពរបស់មនុស្សពេញវ័យ (PIAAC) របស់អង្គការ OECD និងកម្មវិធីបន្តបណ្តុះបណ្តាលជំនាញ ដើម្បីការងារ និងផលិតភាព (STEP) របស់ធនាគារពិភពលោក។ លទ្ធផលរបស់កម្មវិធីទាំងពីរនេះអាច និងគួរប្រើប្រាស់ ដើម្បីឆ្លើយទៅនឹងសំណួរសំខាន់ៗអំពីរបៀបដែលការអប់រំប្រភេទផ្សេងៗ រួមចំណែកដល់ការអភិវឌ្ឍជំនាញ និងការរៀនសូត្រ និងរបៀបដែលជំនាញទាំងនេះបង្កើនឱកាសការងារ និងការចូលរួមក្នុងសង្គមរបស់បុគ្គល ម្នាក់ៗ។

កម្មវិធី PIAAC ធ្វើការវាយតម្លៃលើជំនាញអក្ខរកម្ម និងជំនាញលេខនពន្ធរបស់មនុស្សពេញវ័យ និងសមត្ថភាពរបស់ពួកគេ ក្នុងការដោះស្រាយបញ្ហា នៅក្នុងបរិយាកាសដែលសម្បូរដោយបច្ចេកវិទ្យា។ ភស្តុតាងបង្ហាញថា ជំនាញទាំងនេះមិនត្រឹមតែអាចរៀន ក្រោយពេលដែលអ្នកទាំងនោះឈប់រៀនពីសាលាប៉ុណ្ណោះទេ ជំនាញទាំងនេះក៏អាចបាត់បង់ផងដែរ ប្រសិនបើគេមិនយកមកប្រើឱ្យបានជាប្រចាំនោះ។ ការសិក្សានេះក៏បានបង្ហាញផងដែរថា អ្នកដែលបានចូលរួមក្នុងកម្មវិធីវិជ្ជាជីវៈ មានកម្រិតជំនាញទាបជាងអ្នកដែលបានចូលរួម ក្នុងកម្មវិធីចំណេះទូទៅ។

កម្មវិធី STEP គឺជាការសិក្សា ផ្អែកលើសំណាកគំរូគ្រួសារ និងសហគ្រាស ជាពិសេស នៅតំបន់ប្រជុំជននៃប្រទេសដែលមានចំណូលមធ្យម។ កម្មវិធីនេះធ្វើការអង្កេតលើភាពស្ទាត់ជំនាញខាងការអាន និងលើជំនាញសម្រាប់បំពេញកិច្ចការជាក់លាក់ រាប់បញ្ចូលទាំងជំនាញលេខនពន្ធ និងការប្រើប្រាស់កុំព្យូទ័រ ដែលអាចប្រើក្នុងការងារផង និងក្រៅការងារផង។ កម្មវិធី STEP បានបញ្ជាក់ពីតម្លៃរបស់ជំនាញទន់និយាយជាទូទៅ និងនិយាយដោយឡែក បានរកឃើញថា "ភាពបើកចំហ" បង្កើនប្រាក់ចំណូលដែលរកបាន សូម្បីតែនៅពេលដែលចំនួនឆ្នាំនៃការទទួលបានការអប់រំ ត្រូវបានគិតបញ្ចូលក៏ដោយ។

# ប័ណ្ណរាយការណ៍ ២០០០-២០១៥

## គោលដៅទី ៤ ជំនាញសម្រាប់យុវជន និងមនុស្សពេញវ័យ

សម្រេចឱ្យបាននូវការកែលំអកម្រិតអក្ខរកម្មមនុស្សពេញវ័យ ៥០ ភាគរយ ត្រឹមឆ្នាំ ២០១៥ ជាពិសេស សម្រាប់ស្ត្រី និងការទទួលបានការអប់រំ ថ្នាក់មូលដ្ឋាន និងការអប់រំបន្តប្រកបដោយសមធម៌ សម្រាប់មនុស្សពេញវ័យទាំងអស់

### ពិន្ទុសកល *

*ក្នុងចំណោមប្រទេសចំនួន ៧៣ ដែលមានទិន្នន័យ




### ជោគជ័យ

អត្រាអនក្ខរកម្មមនុស្សពេញវ័យ




អាស៊ីកណ្ដាល និងអឺរ៉ុបកណ្ដាល និងខាងកើត នឹងអាចកាត់បន្ថយអត្រាអនក្ខរកម្មរបស់ខ្លួនបានពាក់កណ្ដាល នៅត្រឹមឆ្នាំ ២០១៥



ចាប់តាំងពីឆ្នាំ ២០០០ មក អត្រាអនក្ខរកម្មមនុស្សពេញវ័យ ថយចុះបាន ៖




### កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើង

យុទ្ធនាការ និងការប្តេជ្ញាចិត្ត ជា សកលថែមទៀត




តម្រូវការអក្ខរកម្ម ខ្ពស់ជាងមុន




ការវាយតម្លៃលើអក្ខរកម្ម ២០០០ មានលក្ខណៈអត្តនោម័ត




ឥឡូវនេះ ដោយផ្ទាល់




### បញ្ហាប្រឈមដែលនៅបន្តមាន

យ៉ាងហោចណាស់មានមនុស្ស ពេញវ័យ ៧៨១ លាននាក់ មិនមានជំនាញអក្ខរកម្មជាមូលដ្ឋាន



ក្នុងចំណោមមនុស្សពេញវ័យមិនចេះអក្សរនៅក្នុងឆ្នាំ ២០១៥ មាន ៦៤% ជាស្ត្រី



- ពុំមានការប្រែប្រួល ចាប់តាំងពីឆ្នាំ ២០០០ មក

វឌ្ឍនភាពខាងអក្ខរកម្មមនុស្ស ពេញវ័យកើតឡើងភាគច្រើន ដោយសារតែមនុស្សវ័យក្មេង ដែលបានទទួលការអប់រំ ឈានចូលវ័យជាមនុស្សពេញវ័យ



### វិឌ្ឍនភាពមិនស្មើគ្នា

ការប្រមូលទិន្នន័យល្អជាងមុន



បច្ចេកវិទ្យាថ្មី



ការយល់ដឹងប្រសើរជាងមុនអំពីជំនាញអក្ខរកម្ម ថាជាជំនាញដែលមានកម្រិត




ការយល់ដឹងប្រសើរជាងមុនអំពីឥទ្ធិពលនៃអក្ខរកម្មមកលើ សុខភាព លទ្ធិប្រជាធិបតេយ្យ ការផ្តល់ភាពអង់អាច



### អនុសាសន៍ សម្រាប់ក្រោយឆ្នាំ ២០១៥

១. ចាំបាច់ត្រូវមានទិន្នន័យ ដើម្បីឆ្លុះបញ្ចាំងពីការបកស្រាយថ្មីៗដែលថា ជំនាញអក្ខរកម្មមិនមែនជាជំនាញ ខ្មៅ និងស នោះទេ ប៉ុន្តែជាជំនាញដែលមានកម្រិតរបស់វា

២. ប្រទេសនានាត្រូវបញ្ជាក់ពីកម្រិតអក្ខរកម្មវិជ្ជាជីវៈដែលមនុស្សពេញវ័យទាំងអស់គួរទទួលបាន ស្របទៅតាម កិច្ចព្រមព្រៀងអន្តរជាតិ

ចាំបាច់ត្រូវមានការគិតពិចារណាសារជាថ្មី

# គោលដៅទី ៤ អក្ខរកម្មមនុស្សពេញវ័យ

*សម្រេចឱ្យបាននូវការកែលំអកម្រិតអក្ខរកម្មមនុស្សពេញវ័យ ៥០ ភាគរយ ត្រឹមឆ្នាំ ២០១៥ ជាពិសេស សម្រាប់ស្ត្រី និងការទទួលបានការអប់រំថ្នាក់មូលដ្ឋាន និងការអប់រំបន្តប្រកបដោយសមធម៌ សម្រាប់មនុស្សពេញវ័យទាំងអស់*

ចាំបាច់ត្រូវតែមានការទទួលស្គាល់ថា អភិក្រមសម្រាប់ផ្តល់ជំនាញអក្ខរកម្មដល់មនុស្សពេញវ័យ ចាប់តាំងពីឆ្នាំ ២០០០ មក មានការអភិវឌ្ឍវិជ្ជមានជាច្រើន។ កន្លងមកមាននិន្នាការបង្ហាញយ៉ាងច្បាស់ ក្នុងការឈានទៅវាស់វែងជំនាញអក្ខរកម្ម ជាកម្រិតៗពីទាប ទៅខ្ពស់ ផ្ទុយទៅនឹងការវាស់វែង ដែលកំណត់ថាមនុស្សពេញវ័យ ចេះអក្សរ ឬមិនចេះអក្សរនោះ ដែលកត្តានេះមានឥទ្ធិពលលើការរៀបចំគោលនយោបាយ និងកម្មវិធីនៅតាមប្រទេសជាច្រើន។ ប៉ុន្តែមានប្រទេសតែមួយចំនួនតូចប៉ុណ្ណោះ ដែលបានបំពេញទៅតាមចំណុចដៅអក្ខរកម្មនៃការអប់រំសម្រាប់ទាំងអស់គ្នា ដែលកំណត់ថា ត្រូវកាត់បន្ថយអត្រាអក្ខរកម្មមនុស្សពេញវ័យឱ្យបានពាក់កណ្តាលត្រឹមឆ្នាំ ២០១៥។

វឌ្ឍនភាព ក្នុងការឈានទៅសម្រេចគោលដៅទី ៤ នៃការអប់រំសម្រាប់ទាំងអស់គ្នា មានល្បឿនយឺតយ៉ាវជាងវឌ្ឍនភាពក្នុងការឈានសម្រេចគោលដៅផ្សេងទៀត។ មានមនុស្សពេញវ័យជិត ៧៨១ លាននាក់ ពុំមានជំនាញអក្ខរកម្មគ្រប់គ្រាន់ឡើយ។ ការថយចុះនូវអត្រាអនក្ខរកម្មមនុស្សពេញវ័យ មួយផ្នែក ឆ្លុះបញ្ចាំងពីការចូលរបស់ក្រុមមនុស្សក្មេងៗ ដែលមានកម្រិតវប្បធម៌ខ្ពស់ ទៅក្នុងវ័យជាមនុស្សពេញវ័យ ជាជាងជាការរីកចម្រើនខាងអក្ខរកម្មរបស់ក្រុមមនុស្សពេញវ័យ ដែលបានឆ្លងផុតអាយុរៀននៅសាលាហើយនោះ។

## ប្រទេសភាគច្រើននៅឆ្ងាយពីការសម្រេចគោលដៅទី ៤

ការពិនិត្យតាមដានអក្ខរកម្មមនុស្សពេញវ័យ តម្រូវឱ្យមានការផ្តល់ព័ត៌មានប្រកបដោយសង្គតិភាព ដើម្បីបង្កលក្ខណៈឱ្យគេអាចធ្វើការប្រៀបធៀបគ្នាបាន។ ប៉ុន្តែ ដោយសារតែចាប់តាំងពីឆ្នាំ ២០០០ មក និយមន័យអក្ខរកម្មមានការប្រែប្រួល ការទទួលបានព័ត៌មានបែបនេះអាចជាការលំបាក។ នៅពេលផ្តោតការយកចិត្តទុកដាក់លើប្រទេស ដែលមានអត្រាអក្ខរកម្មទាបជាង ៩៥% នៅក្នុងរយៈពេលពីឆ្នាំ ១៩៩៥ ដល់ ២០០៤ និងដែលព័ត៌មានផ្អែកលើការប្រកាសដោយខ្លួនឯងរបស់អ្នកតបសម្ភាសន៍ មានប្រទេសតែ ១៧ ក្នុងចំណោម ៧៣ ប្រទេសប៉ុណ្ណោះ ដែល ត្រូវបានព្យាករថាបានកាត់បន្ថអត្រាអនក្ខរកម្មមនុស្សពេញវ័យបានយ៉ាងហោចណាស់ពាក់កណ្តាល គិតត្រឹមឆ្នាំ ២០១៥។ ប្រទេសក្រីក្របន្តនៅឆ្ងាយបំផុតពីសម្រេចចំណុចដៅនេះ។

ប្រទេសចំនួន១៧ នឹងសម្រេចបានតាមគោលដៅអក្ខរកម្មនៅត្រឹមឆ្នាំ ២០១៥

ការវិភាគលើប្រទេសទាំង ៧៣ នេះ បង្ហាញថា ការផ្លាស់ប្តូរ ដែលត្រូវបានព្យាករថានឹងកើតឡើងមុនឆ្នាំ ២០១៥ គឺមានល្បឿនលឿនជាងសម្រាប់ស្ត្រី បើធៀបជាមួយនឹងបុរស។ ប្រទេសទាំងអស់ ដែលរៀងរាល់បុរស ១០០ នាក់ មានស្ត្រី ៩០ នាក់ ចេះអក្សរ នៅក្នុង ឬប្រហែលជុំវិញឆ្នាំ ២០០០ គឺជាប្រទេស ដែលបានបោះជំហានទៅរកយុគភាពយេនឌ័រ។

## ការអង្កេតអន្តរជាតិ និងជាតិ បង្កលក្ខណៈឱ្យមានការវាយតម្លៃដោយផ្ទាល់លើអក្ខរកម្ម

ការអង្កេតគ្រួសារដែលបំពេញបានតាមស្តង់ដាភាគច្រើន ដែលធ្វើការវាយតម្លៃលើជំនាញអក្ខរកម្មធ្វើឡើងដោយផ្អែកទៅតាមការបែងចែកដែលមានលក្ខណៈសាមញ្ញ រវាងអក្ខរកម្ម

និងអនក្ខរកម្ម។ ប៉ុន្តែ ចាប់តាំងពីឆ្នាំ ២០០០ មក អក្ខរកម្មកាន់តែត្រូវបានគេទទួលយកថាជាជំនាញ ដែលមានកម្រិតរបស់វា។ ដូច្នេះ ប្រទេស និងទីភ្នាក់ងារអន្តរជាតិនានាបានធ្វើការស្រាវជ្រាវ ដែលមានលក្ខណៈស្មុគស្មាញ ដើម្បីវាស់វែង មិនត្រឹមតែលើថាតើមនុស្សពេញវ័យ "ចេះអក្សរ" ឬ "មិនចេះអក្សរ" នោះទេ ប៉ុន្តែថែមទាំងវាស់វែងលើកម្រិតអក្ខរកម្មរបស់ពួកគេទៀតផង។

ចាប់តាំងពីឆ្នាំ ២០០០ មក កម្មវិធីអង្កេតគ្រួសារជាអន្តរជាតិធំៗចំនួន ២ ពោលគឺការអង្កេតប្រជាសាស្ត្រ និងសុខភាព និងការអង្កេត សំណុំសូចនាករចម្រុះ បានខិតខំវាយតម្លៃលើអក្ខរកម្មដោយផ្ទាល់ តាមរយៈការឱ្យអ្នកតបសម្ភាសន៍អានប្រយោគមួយ ដែលសរសេរដាក់លើប័ណ្ណមួយ។ នៅពេលការប៉ាន់ប្រមាណធ្វើឡើង ផ្អែកទៅតាមការវាយតម្លៃផ្ទាល់បែបនេះមានមនុស្សពេញវ័យច្រើនជាងមុន ដែលពុំមានជំនាញអានគ្រប់គ្រាន់ បើធៀបជាមួយនឹងពេលដែលការប៉ាន់ប្រមាណធ្វើឡើង ចេញពីការប្រកាសដោយខ្លួនឯង។

វឌ្ឍនភាពភាគច្រើននៃគោលដៅទី ៤ នេះ គឺ កើតឡើងដោយសារតែមនុស្សវ័យក្មេងដែលបានទទួលការអប់រំឈានចូលវ័យជាមនុស្សពេញវ័យ

កម្មវិធី PIAAC របស់ OECD ដែលធ្វើការអង្កេតលើមនុស្សអាយុពី ១៦ ដល់ ៦៥ ឆ្នាំចំនួន ១៦៦០០០ នាក់ នៅក្នុងសង្គមដែលមាន កម្រិតអក្ខរកម្មខ្ពស់ បង្ហាញថា សូម្បីតែនៅតាមប្រទេសដែលមានចំណូលខ្ពស់ មានមនុស្សពេញវ័យមួយភាគតិចចេះអានក្នុងកម្រិតទាបបំផុត។ នៅតាមប្រទេសមួយចំនួន ដូចជា ប្រទេសបារាំង អ៊ីតាលី និងអេស្ប៉ាញ ក្នុងចំណោមមនុស្សពេញវ័យ ៤ នាក់ មានជាង ១ នាក់ មានជំនាញ អក្ខរកម្មទាប។

វិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូ បានផ្តួចផ្តើមរៀបចំនូវកម្មវិធីតាមដាន និងវាយតម្លៃអក្ខរកម្ម (LAMP) មួយ ដើម្បីរកឱ្យឃើញពី ទិដ្ឋភាពចម្រុះនៃអក្ខរកម្ម ដោយវាស់វែងតាមរយៈអំណានពាក្យរាយ អំណានឯកសារ និងលេខនព្វន្ត។ កម្មវិធី LAMP បានបង្កើតនូវសំណាកគំរូមនុស្សពេញវ័យមកពីតំបន់ជនបទផង និងប្រជុំជនផង នៅក្នុងប្រទេសចរដន់ ម៉ុងហ្គោលី ប៉ាឡេស្ទីន និងប៉ារ៉ាហ្គាយ។ កម្មវិធីនេះបានកំណត់កម្រិតអក្ខរកម្មដែលត្រូវមានជា ៣ កម្រិត។ លទ្ធផលពីប្រទេសប៉ារ៉ាហ្គាយបានបង្ហាញថា មនុស្សពេញវ័យនៅតំបន់ជនបទមានជំនាញអានពាក្យរាយ ទាបជាងអ្នករស់នៅតំបន់ប្រជុំជន ដែលប្រើប្រាស់ភាសាអេស្ប៉ាញជាភាសាកំណើត។

## *ការវាយតម្លៃថ្នាក់ជាតិលើអក្ខរកម្មមនុស្សពេញវ័យ*

ប្រទេសដែលមានកម្រិតអក្ខរកម្មទាបជាច្រើន បានចាប់ផ្តើមប្រើប្រាស់ការវាយតម្លៃអក្ខរកម្មលើកម្រិតមួយៗ។ ការវាយតម្លៃទាំងនេះ ផ្តល់នូវលទ្ធផលកាន់តែសុក្រឹតជាងការអង្កេត ដែលផ្អែកលើការប្រកាសរបស់អ្នកតបសម្ភាសន៍ថាពួកគេជាអ្នកចេះអក្សរ ឬមិនចេះអក្សរ។ ឧទាហរណ៍ ការអង្កេតថ្នាក់ជាតិលើអក្ខរកម្មមនុស្សពេញវ័យ របស់ប្រទេសកេនយ៉ា នៅក្នុងឆ្នាំ ២០០៦ បានរកឃើញពីភាពខុសប្លែកគ្នាច្រើនរវាងតំបន់ប្រជុំជន និងតំបន់ជនបទ និងបានរកឃើញថា អត្រាអក្ខរកម្មរបស់មនុស្សពេញវ័យនៅថ្នាក់ជាតិ

**រូបភាពទី ៧ ៖ នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ជំនាញអក្ខរកម្មរបស់មនុស្សពេញវ័យកម្រនឹងរីកចម្រើនណាស់**

អត្រាអក្ខរកម្មរបស់ស្ត្រី តាមប្រទេសមួយចំនួន និងក្រុមអាយុមួយចំនួន ឆ្នាំ ២០០០ និង ២០១០




សម្គាល់ ៖ ១. អក្ខរកម្មត្រូវបានវាស់វែងដោយផ្ទាល់។ ២. សម្រាប់ប្រទេសនីមួយៗ បន្ទាត់ដាប់ គឺទៅតាមពេលវេលា ដែលស្ត្រីអាយុ ២០-៣៤ ឆ្នាំ នៅចំណុចសង្កេតដំបូង ឧទាហរណ៍ បន្ទាប់ជាបន្ទា នៅក្នុងប្រទេសម៉ាឡាវី គឺតាមស្ត្រីអាយុ ២០-៣៤ ឆ្នាំ នៅក្នុងឆ្នាំ ២០០០ ដែលមានអាយុ ៣០-៤៤ ឆ្នាំ នៅឆ្នាំ ២០១០។ បន្ទាត់ដាច់ៗមើលតាមក្រុមអាយុតែមួយនេះ ឧទាហរណ៍ បន្ទាត់ដាច់ៗ មើលតាមស្ត្រីដែលមានអាយុ ២០-៣៤ ឆ្នាំ នៅក្នុងឆ្នាំ ២០០០ និង ២០១០។ ៣. នៅក្នុងឆ្នាំ ២០០១ ការអង្កេតប្រជាសាស្ត្រ និងសុខភាពរបស់ប្រទេសនេប៉ាល់ យកតែស្ត្រីដែលមាន រៀបការហើយមកធ្វើជាសំណាកគំរូប៉ុណ្ណោះ ប៉ុន្តែនៅក្នុងឆ្នាំ ២០០៦ និង ២០១១ ការអង្កេតនេះយកស្ត្រីទាំងអស់មកធ្វើជាសំណាកគំរូ។

*ប្រភព* ៖ Barakat (2015) និងក្រុមការងារ EFA GMR ផ្អែកតាមការវិភាគទិន្នន័យនៃការអង្កេតប្រជាសាស្ត្រ និងសុខភាព

មានកម្រិត ៥៩% សម្រាប់ស្ត្រី ពោលគឺ ១៣ ចំណុចទាបជាងអត្រា ដែល UIS បានប៉ាន់ប្រមាណ ផ្អែកទៅតាមស្វ័យប្រកាសពីសមត្ថភាពអានផ្ទាល់ខ្លួនរបស់អ្នកតបសម្ភាសន៍។ លទ្ធផល សម្រាប់បុរស ៦៤% គឺ ១៥ ចំណុចទាបជាងអត្រាដែលប៉ាន់ប្រមាណដោយ UIS ។

## ការប្រៀបធៀបក្រុមកូហត បង្ហាញថាអក្ខរកម្មមនុស្សពេញវ័យស្ទើរតែពុំមានការរីកចម្រើនទាន់តែសោះ ចាប់តាំងពីឆ្នាំ ២០០០ មក

អត្រាអក្ខរកម្មមនុស្សពេញវ័យ សម្រាប់វាយតម្លៃលើជោគជ័យនៃកម្មវិធីអក្ខរកម្ម ជួបប្រទះនឹងឧបសគ្គ ដោយសារតែអត្រានេះផ្អែក ទៅតាមមនុស្សពេញវ័យក្នុងក្រុមផ្សេងៗគ្នា នៅពេលខុសៗគ្នា។ ដូច្នេះ បើទោះបីជាមិនមានមនុស្សពេញវ័យណាម្នាក់ បានផ្លាស់ប្តូរស្ថានភាពអក្ខរកម្មរបស់ខ្លួនយ៉ាងណាក៏ដោយ អត្រាអក្ខរកម្មមនុស្សពេញវ័យអាចមានការផ្លាស់ប្តូរ ពោលគឺមានការកើនឡើង ឧទាហរណ៍ ប្រសិនបើមនុស្សវ័យក្មេង ដែលមានជំនាញអក្ខរកម្មខ្ពស់ឈានចូលដល់វ័យជាមនុស្សពេញវ័យ ហើយក្នុងពេលជាមួយគ្នា មនុស្សដែលមានអាយុច្រើនជាង និងមានជំនាញអក្ខរកម្មទាបជាង ចាកចេញពីក្រុមអាយុនេះ។

ម្យ៉ាងវិញទៀត ប្រសិនបើមានមនុស្សមួយក្រុម ឬកូហតមួយ មានអាយុចន្លោះពី ២០ ដល់ ៣០ ឆ្នាំ នៅក្នុងឆ្នាំ ២០០០ និងមានអាយុពី ៣០ ដល់ ៤០ ឆ្នាំ នៅក្នុងឆ្នាំ ២០១០ ការផ្លាស់ប្តូរកើតឡើង មិនមែនដោយសារតែការផ្លាស់ប្តូរពាក់ព័ន្ធនឹងការរៀនសូត្រក្នុងសាលានោះទេ ប៉ុន្តែដោយសារតែការទទួលបានជំនាញអក្ខរកម្ម តាមរយៈកម្មវិធីអក្ខរកម្ម ឬឱកាសក្នុងជីវិតផ្សេងទៀត។ ការវិភាគថ្មីដែលធ្វើឡើងសម្រាប់របាយការណ៍ពិនិត្យតាមដានសកលឆ្នាំ ២០១៥ នេះ ប្រើប្រាស់អភិក្រមនេះ។

ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងទូរស័ព្ទដៃអាចជួយលើកកម្ពស់បរិយាកាសអក្ខរកម្មឱ្យបានរឹតតែខ្លាំងក្លាថែមទៀត

លទ្ធផលគឺ គេអាចឃើញប្រទេសមួយចំនួនកំពុងមានការរីកចម្រើនខាងអត្រាអក្ខរកម្មរបស់ស្ត្រីវ័យក្មេងពិតប្រាកដមែន ប៉ុន្តែក្នុងកម្រិតមួយទាប ប៉ុន្តែការរីកចម្រើនទាំងនេះបានរលាយបាត់ពីក្រុមកូហតនេះ។ ឧទាហរណ៍ នៅក្នុងប្រទេសម៉ាឡាវី អត្រាអក្ខរកម្មរបស់ស្ត្រីអាយុពី ២០ ដល់ ៣៤ ឆ្នាំ គឺ ៤៩% នៅក្នុងឆ្នាំ ២០០០ និង ៦៣% នៅក្នុងឆ្នាំ ២០១០។ ប៉ុន្តែ អត្រាអក្ខរកម្មរបស់ក្រុមស្ត្រី ដែលមានអាយុពី ២០ ដល់ ៣៤ ឆ្នាំ នៅក្នុងឆ្នាំ ២០០០ និងអាយុពី ៣០ ដល់ ៤៤ ឆ្នាំ នៅក្នុងឆ្នាំ ២០១០ នៅទ្រឹងត្រឹម ៤៩%។

ក្នុងចំណោម ៣០ ប្រទេស ដែលត្រូវបានវិភាគ មានប្រទេសភាគច្រើន ដែលអត្រាអក្ខរកម្មរបស់ក្រុមណាមួយ នៅទ្រឹង ឬកាន់តែថយ ចុះទៅទៀត នៅពេលដែលជំនាញនេះមិនសូវជាត្រូវបានគេយកមកប្រើប្រាស់។ ប្រទេសនេប៉ាល់ គឺជាប្រទេសតែមួយគត់ ដែលការរីកចម្រើននៅបានជាប់បន្ត ដូចដែលបញ្ជាក់នៅកម្រិតកូហត នៅក្នុង


Credit: UNESCO Phnom Penh

ការអង្កេតចំនួន ៣ ដង។ មូលហេតុមួយ អាចដោយសារតែជោគជ័យនៃការវិនិយោគរបស់ រដ្ឋាភិបាលក្នុងទឹកប្រាក់ ៣៥ លានដុល្លារ លើយុទ្ធនាការអក្ខរកម្មជាតិរបស់ខ្លួនពីឆ្នាំ ២០០៨ ដល់ ២០១២។

## ការពន្យល់ពីវឌ្ឍនភាពតិចតួចនៃអក្ខរកម្មមនុស្សពេញវ័យ

ប្រសិនបើជំនាញអក្ខរកម្មរបស់មនុស្សពេញវ័យ ដែលមានអាយុលើសពីអាយុដែលត្រូវចូលរៀននៅសាលា ពុំមានការរីកចម្រើន នៅក្នុងប្រទេសកំពុងអភិវឌ្ឍភាគច្រើន នោះគេនៅមានមន្ទិលសង្ស័យច្រើនលើលទ្ធផលដែលកិច្ចខិតខំប្រឹងប្រែងបង្កើនបំណិនអក្ខរកម្មនេះ មានចាប់តាំងពីឆ្នាំ ២០០០ មក។ មានកត្តាចំនួន ៤ ដែលអាចជួយពន្យល់ពីវឌ្ឍនភាពយឺតយ៉ាវបែបនេះ ៖ កម្រិតនៃការប្តេជ្ញាចិត្តនយោបាយកម្រិតសកល ប្រសិទ្ធភាពនៃយុទ្ធនាការ និងកម្មវិធីអក្ខរកម្ម វិសាលភាពនៃការខិតខំលើកកម្ពស់កម្មវិធីអក្ខរកម្មដោយប្រើភាសាកំណើត និងភាពឆ្លើយតបរបស់កម្មវិធីចំពោះតម្រូវការខាងអក្ខរកម្ម។

### *ការប្តេជ្ញាចិត្តជាសកលចំពោះអក្ខរកម្មមនុស្សពេញវ័យពុំមានភាពច្បាស់លាស់*

សហគមន៍អន្តរជាតិ បានចេញសេចក្តីប្រកាសជាបន្តបន្ទាប់ថានឹងធ្វើការលើកកម្ពស់អត្រាអក្ខរកម្ម នៅក្នុងរយៈពេល ១ ភាគ ៤ ចុង ក្រោយនៃសតវត្សរ៍នេះ។ ចំណុចដៅដែលត្រូវបានប្រកាសនេះបានបង្កើនការរំពឹងទុកថា បញ្ហាអនក្ខរកម្មនឹងធ្វើដំណើរតាមមាគ៌ាដូចគ្នានឹងជំងឺ គ្រុនស្វិតដៃជើង និងអាច "លុបំបាត់បាន"។ ការវិភាគនៅក្នុងរបាយការណ៍ពិនិត្យតាមដានសកលនេះ លើផែនការអប់រំជាតិរបស់ប្រទេសចំនួន ៣០ ដែលទទួលបានប្រហែលជានៅក្នុងឆ្នាំ ២០០០ និងក្រោយឆ្នាំ ២០០៧ បានរកឃើញថា អក្ខរកម្មមនុស្សពេញវ័យ មិនត្រូវបានគេយកចិត្តទុកដាក់ឡើយ បើធៀបជាមួយនឹងគោលដៅផ្សេងទៀតនៃការអប់រំសម្រាប់ទាំងអស់គ្នា។

បើទោះបីជាមានគំនិតផ្តួចផ្តើមសកលជាច្រើន ចាប់តាំងពីឆ្នាំ ២០០០ មក ដើម្បីកំណត់សាជាថ្មីនូវទស្សនទានអក្ខរកម្មមនុស្សពេញវ័យ និងផ្តួចផ្តើមឱ្យមានកម្មវិធីផ្សេងៗ (ដូចជាកម្មវិធីគំនិតផ្តួចផ្តើមអក្ខរកម្ម ដើម្បីផ្តល់ភាពអង់អាច) ដែលក្តោបលើទស្សនទានថ្មីៗក៏ដោយ ប្រសិទ្ធភាពនៃកម្មវិធីទាំងនេះ នៅក្នុងការអនុវត្តជាក់ស្តែង នៅមានកម្រិតនៅឡើយ។ កម្មវិធីជាច្រើនត្រូវបានរកឃើញថាខ្វះចក្ខុវិស័យរយៈពេលវែង ឱ្យស្របជាមួយនឹងយុទ្ធសាស្ត្រអប់រំជាតិ។

### *យុទ្ធនាការ និងកម្មវិធីអក្ខរកម្ម មានការផ្លាស់ប្តូរ ប៉ុន្តែលទ្ធផលរបស់យុទ្ធនាការ និងកម្មវិធីទាំងនេះ នៅមិនទាន់ឃើញមានជាក់ស្តែង*

ចំណាប់អារម្មណ៍របស់អង្គការថ្នាក់តំបន់ និងរដ្ឋាភិបាលនានា នៅក្នុងការប្រកាសអនុវត្តយុទ្ធនាការអក្ខរកម្ម មានការកើនឡើងចាប់តាំងពីឆ្នាំ ២០០០ មក ជាពិសេសនៅអាមេរិចឡាទីន។ យុទ្ធនាការភាគច្រើនដាក់ចេញនូវចំណុចដៅប្រកបដោយមហិច្ឆតា ប៉ុន្តែ កាលបរិច្ឆេទ កំណត់បានកន្លងផុតទៅហើយ ហើយនៅក្នុងករណីមួយចំនួនចំណុចដៅទាំងនេះនៅតែមិនអាចបំពេញបានទៀត។

យុទ្ធនាការធំៗ សុទ្ធតែមានហានិភ័យ។ យុទ្ធនាការទាំងនោះអាចបង្កើននូវការរំពឹងទុក ដោយមិនមានលក្ខណៈប្រាកដនិយម ហើយយុទ្ធនាការទាំងនោះមិនបានយកចិត្តទុកដាក់ចំពោះតម្រូវការផ្សេងៗគ្នា ជានិច្ចកាលនោះទេ។ ភាសា ដែលប្រើដោយយុទ្ធនាការទាំងនេះ ជារឿយៗបង្ហាញថា បញ្ហាអនក្ខរកម្មគឺជា "ជំងឺសង្គម" ដែលអាច "លុបបំបាត់" បានជាមួយនឹងអន្តរាគមន៍ចំគោលដៅ។ នេះអាចជាការមាក់ងាយដល់អនក្ខរជន មិនផ្តល់ការលើកទឹកចិត្តដល់អ្នកដែលមានជំនាញអក្ខរកម្មទាប និងនាំឱ្យពួកគេលាក់កំបាំងស្ថានភាពរបស់ខ្លួន។ ជារួម យុទ្ធនាការអក្ខរកម្មចាប់តាំងពីឆ្នាំ ២០០០ មក ពុំមានលទ្ធផលជាដុំកំភួននាំឱ្យមានការកែលំអជំនាញអក្ខរកម្មក្នុងពិភពលោកទាំងមូលឡើយ។

### *វឌ្ឍនភាព នៅក្នុងការទទួលស្គាល់សារៈសំខាន់នៃភាសាកំណើត*

ចាប់តាំងពីឆ្នាំ ២០០០ មក លក្ខខណ្ឌនានាកាន់តែមានលក្ខណៈអំណោយផល នៅតាមប្រទេសដែលមានកម្រិតអក្ខរកម្មទាបជាច្រើន ក្នុងការបង្កើនការយកចិត្តទុកដាក់លើការប្រើប្រាស់ភាសាកំណើតធ្វើជាមធ្យោបាយសម្រាប់បង្រៀននៅក្នុងកម្មវិធីអក្ខរកម្មមនុស្សពេញវ័យ។ ប៉ុន្តែ ដោយសារតែឧបសគ្គខាងផ្នែកភស្តុភារ ឬការយល់ផ្ទុយគ្នារបស់អ្នកដឹក

នាំនយោបាយ កម្មវិធីទាំងនេះនៅមិនទាន់បានរួមចំណែកជាដុំកំភួន ចំពោះការលើកកម្ពស់ជំនាញអក្ខរកម្មមនុស្សពេញវ័យ ក្នុងកម្រិតមួយធំនៅឡើយទេ។

### *ការផ្លាស់ប្តូរ នៅក្នុងជីវិតប្រចាំថ្ងៃ មិនបាននាំឱ្យមានការកើនឡើងខ្លាំងនូវតម្រូវការអក្ខរកម្មឡើយ*

អក្ខរកម្មត្រូវការមិនត្រឹមតែការផ្តល់ឱកាសរៀនសូត្រឱ្យបានកាន់តែប្រសើរជាងមុននោះទេ ប៉ុន្តែថែមទាំងឱកាសបន្ថែមទៀត ដើម្បីប្រើប្រាស់ កែលំអ និងរក្សាជំនាញអក្ខរកម្មទៀតផង។ ឱកាសបែបនេះបាន និងកំពុងកើនឡើងចាប់តាំងពីឆ្នាំ ២០០០ មក។ របាយការណ៍ពិនិត្យ តាមដានសកលឆ្នាំ ២០១៥ នេះ ធ្វើការពិនិត្យលើឧទាហរណ៍ខាងទីផ្សារ កសិកម្ម អន្តរាគមន៍សុខភាពសាធារណៈ គំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុ និង ការវិនិយោគលើការគ្រប់គ្រងទឹក។ បើទោះបីជាមានការទទួលស្គាល់កាន់តែច្រើនឡើងថា កម្មវិធីអក្ខរកម្មចាំបាច់ត្រូវតែភ្ជាប់ជាមួយនឹងឱកាស បែបនេះក៏ដោយ ឥទ្ធិពលរបស់វាមកលើការទទួលបានជំនាញអក្ខរកម្ម នៅមិនទាន់ឃើញចេញជារូបរាងនៅឡើយ។

ប៉ុន្តែ ការផ្លាស់ប្តូរមួយទៀត ពោលគឺការពង្រីកយ៉ាងឆាប់រហ័សនូវបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ផ្តល់នូវសក្តានុពលដ៏ធំមួយ។ គេអាចទាញប្រយោជន៍ពីការប្រើប្រាស់ទូរស័ព្ទដៃជាទូទៅ ដើម្បីពង្រឹងបរិយាកាសអក្ខរកម្ម និងអំណានបន្ថែមទៀត បើទោះបីជាគេមិនទាន់ ឃើញមានភស្តុតាងច្បាស់លាស់ ដែលបង្ហាញពីឥទ្ធិពល ដែលបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍មានមកលើជំនាញអក្ខរកម្មក៏ដោយ។

# បណ្ណរបាយការណ៍ ២០០០-២០១៥

## គោលដៅទី ៥ យុគភាព និងសមភាពយេនឌ័រ

លុបបំបាត់គម្លាតយេនឌ័រ នៅបឋមសិក្សា និងមធ្យមសិក្សា ត្រឹមឆ្នាំ ២០០៥ និងសម្រេចឱ្យបាននូវសមភាពយេនឌ័រ ក្នុងការអប់រំ ត្រឹមឆ្នាំ ២០១៥ ដោយផ្តោតការយកចិត្តទុកដាក់លើការធានាឱ្យស្ត្រីអាចមានលទ្ធភាពពេញលេញ នឹងស្មើភាពគ្នាក្នុងការទទួលបាន និងសម្រេចលទ្ធផល ក្នុងការអប់រំថ្នាក់មូលដ្ឋាន ប្រកបដោយគុណភាពល្អ

### ពិន្ទុសកល *

*ក្នុងចំណោមប្រទេសចំនួន ១៧០ ដែលមានទិន្នន័យសម្រាប់បឋមសិក្សា និង ១៥៧ ប្រទេសដែលមានទិន្នន័យនៅកម្រិតមធ្យមសិក្សា

| | នៅឆ្ងាយខ្លាំងពីគោលដៅ | នៅឆ្ងាយពីគោលដៅ | កៀកនឹងគោលដៅ | បានសម្រេចគោលដៅ |
|---|---|---|---|---|
| បឋមសិក្សា | 0.6% | 21% | 10% | 69% |
| មធ្យមសិក្សា | 10% | 35% | 7% | 48% |

### ជោគជ័យ

**គម្លាតយេនឌ័រនៅមធ្យមសិក្សាមានការថយចុះ**

ប្រទេសដែលមានក្មេងស្រីតិចជាង ៩០ នាក់ចុះឈ្មោះចូលរៀនសម្រាប់រៀងរាល់ ក្មេងប្រុស ១០០ នាក់

30 → 19

1999 — បច្ចុប្បន្ននេះ

(ក្នុងចំណោម ១៣៣ ប្រទេស)

**ការធានាសិទ្ធិ**

ក្នុងចំណោមរដ្ឋជាសមាជិក ចំនួន ៥៩ ដែលឆ្លើយតប មាន ៤០ រដ្ឋ បានលើកឡើងជាក់ លាក់ពីការធានាសិទ្ធិទទួលការអប់រំរបស់ស្ត្រី

**ក្មេងស្រីដែលបញ្ចប់ការអប់រំមធ្យមសិក្សាបឋមភូមិ**

2000 — ៨១ នាក់ ក្នុងក្មេងប្រុស ១០០ នាក់

2010 — ៩៣ នាក់ ក្នុងក្មេងប្រុស ១០០ នាក់

### កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើង

**ការតស៊ូមតិ ដើម្បីការអប់រំរបស់ក្មេងស្រី**

FAIR PLAY FOR GIRLS!

នៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ

**គម្រោងផ្តល់ប្រាក់ឧបត្ថម្ភ**

បានបង្កើនចំនួនក្មេងស្រីដែលបានចុះឈ្មោះចូលរៀននៅប្រទេសមួយចំនួន

**គ្រូស្រីច្រើនជាងមុន**

ឧ. នៅក្នុងប្រទេសនេប៉ាល់

1999 — 23%

2012 — 42%

(៦០% នៃគ្រូទាំងនេះ គឺជាគ្រូចេញថ្មី)

### បញ្ហាប្រឈមដែលនៅបន្តមាន

**អាពាហ៍ពិពាហ៍ និងការមានផ្ទៃពោះរបស់កុមារ**

**ការបណ្តុះបណ្តាលគ្រូ**

អំពីគោលវិធីដែលគិតគូរពីយេនឌ័រ ចាំបាច់ត្រូវតែពង្រីកបន្ថែមទៀត

**អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រនៅតាមសាលា**

ផ្លូវកាយ — ផ្លូវចិត្ត — ផ្លូវភេទ

**សមភាពយេនឌ័រ**

ការលំបាកក្នុងការកំណត់ និងវាស់វែង

### វិឌ្ឍនភាពមិនស្មើគ្នា

**ក្មេងស្រីមកពីគ្រួសារក្រីក្រជាងគេនៅតែទំនងជាចុះឈ្មោះចូលរៀនតិចតួចជាងគេ**

នៅក្នុងប្រទេសប៉ាគីស្ថាន រៀងរាល់ក្មេងប្រុស ១០០ នាក់ មានក្មេងស្រីតិចជាង ៧០ នាក់ ដែលបានទៅរៀននៅសាលារៀន

**ការរៀនមិនបានពូកែ**

របស់ក្មេងស្រីក្នុងមុខវិជ្ជា គណិតវិទ្យា និងក្មេងប្រុសក្នុង មុខវិជ្ជាអំណាន

**គម្លាតយេនឌ័រ បើធៀបជាមួយនឹងក្មេងប្រុស**

នៅកម្រិតអប់រំមធ្យមសិក្សា នៅអាមេរិចឡាទីន និងការីបៀន និងប្រទេសក្រីក្រមួយចំនួន (ជាពិសេស បង់ក្លាដេស មីយ៉ាន់ម៉ា និងរវ៉ាន់ដា)

### អនុសាសន៍ សម្រាប់ក្រោយឆ្នាំ ២០១៥

១. សាលារៀនគួរតែជាផ្តល់នូវការបង្រៀន និងរៀនប្រកបដោយសុវត្ថិភាព មានការចូលរួម និងគិតគូរពីយេនឌ័រ ដែលផ្តល់ភាពអង់អាចដល់សិស្ស និងលើកកម្ពស់ទំនាក់ទំនងយេនឌ័រជាវិជ្ជមាន

២. ធនធានទាំងឡាយត្រូវតែផ្តោតឱ្យចំសហគមន៍ ដែលគម្លាតយេនឌ័រកើតមានជាទូទៅ

ចាំបាច់ត្រូវមានការខិតខំប្រឹងប្រែងបន្ថែមទៀត

# គោលដៅទី ៥ យុគភាព និងសមភាពយេនឌ័រ

*លុបបំបាត់គម្លាតយេនឌ័រ នៅបឋមសិក្សា និងមធ្យមសិក្សា ត្រឹមឆ្នាំ ២០០៥ និងសម្រេចឱ្យបាននូវសមភាពយេនឌ័រ ក្នុងការអប់រំ ត្រឹមឆ្នាំ ២០១៥ ដោយផ្តោតការយកចិត្តទុកដាក់លើការធានាឱ្យស្ត្រីអាចមានលទ្ធភាពពេញលេញ និងស្មើភាពគ្នាក្នុងការទទួលបាន និងសម្រេចលទ្ធផល ក្នុងការអប់រំថ្នាក់មូលដ្ឋាន ប្រកបដោយគុណភាពល្អ*

គម្លាតយេនឌ័រនៅក្នុងការបញ្ចប់ការសិក្សាកម្រិតបឋមសិក្សានៅតែមានទំហំធំក្នុងចំណោមកុមារក្រីក្រជាងគេ

ចាប់តាំងពីឆ្នាំ ២០០០ មក វឌ្ឍនភាពក្នុងការឈានទៅសម្រេចយុគភាពយេនឌ័រនៅក្នុងការអប់រំកម្រិតបឋមសិក្សាមិនមានដូចៗគ្នាឡើយ។ ចំណុចដៅខាងយុគភាពយេនឌ័រនៃការចុះឈ្មោះចូលរៀននៅបឋមសិក្សា នៅឆ្នាំ ២០០៥ ត្រូវបានខកខានមិនអាចបំពេញបាន ខណៈពេលដែលមានប្រទេសតែ ៦៩% ប៉ុណ្ណោះ ដែលនឹងសម្រេចតាមចំណុចដៅនេះ នៅត្រឹមឆ្នាំ ២០១៥។ សម្រាប់ការអប់រំមធ្យមសិក្សា មានប្រទេសតែ ៤៨% ប៉ុណ្ណោះ ដែលនឹងសម្រេចបាននូវយុគភាពយេនឌ័រ ត្រឹមឆ្នាំ ២០១៥។

សមភាពយេនឌ័រ មានលក្ខណៈស្មុគស្មាញជាងយុគភាពយេនឌ័រ និងពិបាកវាស់វែងជាង។ សមភាពយេនឌ័រតម្រូវឱ្យគេធ្វើការស្វែងយល់ ពីគុណភាពនៃបទពិសោធន៍របស់ក្មេងស្រី និងក្មេងប្រុស នៅក្នុងថ្នាក់រៀន និងនៅក្នុងសហគមន៍សាលារៀន លទ្ធផលដែលពួកគេសម្រេចបាន នៅក្នុងគ្រឹះស្ថានអប់រំ និងបំណងប្រាថ្នារបស់ពួកគេនាពេលអនាគត។

## វឌ្ឍនភាពឆ្ពោះទៅសម្រេចយុគភាពយេនឌ័រ

គម្លាតយេនឌ័រ នៅក្នុងការចុះឈ្មោះចូលរៀននៅបឋមសិក្សា មានការថយចុះយ៉ាងច្រើន ចាប់តាំងពីឆ្នាំ ១៩៩៩ មក ប៉ុន្តែមិនទាន់បានលុបបំបាត់នៅឡើយ។ ក្នុងចំណោម ១៦១ ប្រទេស ដែលមានទិន្នន័យ សម្រាប់ឆ្នាំ ១៩៩៩ និង ២០១២ តួលេខយុគភាព ដែលវាស់វែងតាមសន្ទស្សន៍យុគភាពយេនឌ័រ (GPI) គឺចន្លោះពី ០,៩៧ និង ១,០៣ កើនឡើងពី ៨៣ ដល់ ១០៤ ប្រទេស។ ចំនួនប្រទេសដែលមាន GPI ក្រោម ០,៩៧ ពោលគឺមានក្មេងស្រីចុះឈ្មោះចូលរៀនតិចជាងចំនួនក្មេងប្រុស មានការថយចុះពី ៧៣ មក ៤៨ ប្រទេស។ ក្នុងចំណោមប្រទេស ដែលមិនទាន់សម្រេចបានយុគភាពយេនឌ័រ ត្រឹមឆ្នាំ ២០១២ ប្រទេសភាគច្រើនមានគម្លាតយេនឌ័រ ដោយមានចំនួនក្មេងស្រីតិចជាង និងមានប្រទេសតែ ៩ ប៉ុណ្ណោះ ដែលមានចំនួនក្មេងប្រុសតិចជាង។

មានការរីកចម្រើនគួរឱ្យកត់សម្គាល់ នៅក្នុងការកាត់បន្ថយគម្លាតយេនឌ័រ ក្នុងការចុះឈ្មោះចូលរៀនកម្រិតបឋមសិក្សា នៅអាស៊ីភាគខាងត្បូង និងខាងលិច ដែលមាន GPI កើនឡើងពី ០,៨៣ នៅក្នុងឆ្នាំ ១៩៩៩ ដល់ ១,០០ នៅក្នុងឆ្នាំ ២០១២។ គម្លាតយេនឌ័រក៏ត្រូវបានកាត់បន្ថយនៅក្នុងរដ្ឋអារ៉ាប់ (ពី ០,៨៧ ដល់ ០,៩៣) និងអាហ្វ្រិចសាប់សាហារ៉ា (ពី ០,៨៥ ដល់ ០,៩២) ប៉ុន្តែនៅឆ្ងាយពីយុគភាពនៅឡើយ។

## *វឌ្ឍនភាពនៅតាមប្រទេស ដែលក្មេងស្រីជួបប្រទះនឹងការលំបាកបំផុត*

ចាប់តាំងពីឆ្នាំ ១៩៩៩ មក មានការសម្រេចបាននូវវឌ្ឍនភាពសំខាន់ៗ ក្នុងការកាត់បន្ថយគម្លាតយេនឌ័រ នៅក្នុងការចុះឈ្មោះចូលរៀននៅបឋមសិក្សា នៅក្នុងប្រទេសជាច្រើន ដែលក្មេងស្រីជួបប្រទះនឹងការលំបាកជាងគេ។ ក្នុងចំណោម ១៦១ ប្រទេស ដែលមានទិន្នន័យ ប្រទេសចំនួន ៣៣ ក្នុងនោះមាន ២០ ប្រទេសនៅអាហ្វ្រិច

សាប់សាហារ៉ា មាន GPI ក្រោម ០,៩០ នៅក្នុងឆ្នាំ ១៩៩៩។ ហើយនៅត្រឹមឆ្នាំ២០១២ចំនួននេះមានការថយចុះមកនៅ ១៦ ប្រទេស។

### *ក្មេងស្រីមកពីគ្រួសារក្រីក្រជាងគេ នៅតែទំនងជាចុះឈ្មោះចូលរៀនតិចតួចជាងគេ*

នៅតាមប្រទេស ដែលមានកុមារច្រើនមានអាយុចូលរៀននៅបឋមសិក្សា ដែលមិនដែលបានចូលរៀននៅសាលា ក្មេងស្រី នៅតែមានលទ្ធភាពតិចជាងក្មេងប្រុស ក្នុងការទៅរៀននៅសាលារៀន ជាពិសេស ក្នុងចំណោមកុមារក្រីក្រជាងគេ។ កុមារក្រៅសាលាក្នុងពិភពលោក ប្រមាណជា ៤៣% មិនដែលបានទៅសាលាឡើយ ៖ ក្មេងស្រីដែលទំនងជាមិនដែលទៅរៀននៅសាលា មាន ៤៨% បើធៀបជាមួយនឹងក្មេងប្រុស ៣៧%។

នៅអាមេរិកឡាទីន និងការីបៀន មានក្មេងប្រុសតែ ៩៣ នាក់ ប៉ុណ្ណោះ ដែលចុះឈ្មោះចូលរៀនសម្រាប់រាល់ក្មេងស្រី ១០០ នាក់

### *នៅពេលដែលបានរៀនក្នុងសាលាហើយ ក្មេងស្រីបន្តរៀនជាមួយនឹងក្មេងប្រុសដែរ*

បន្ទាប់ពីបានចុះឈ្មោះចូលរៀនរួច ក្មេងស្រីមានឱកាសស្មើ ឬប្រសើរជាងក្មេងប្រុស ក្នុងការបន្តទៅរៀននៅថ្នាក់លើៗនៃសាលាបឋម សិក្សា ៖ ក្នុងប្រទេសជាច្រើន អត្រាគង់វង្សបន្តទៅដល់ថ្នាក់ទី ៥ សម្រាប់ក្មេងស្រី គឺស្មើគ្នា ឬខ្ពស់ជាងអត្រារបស់ក្មេងប្រុស។ ក្នុងចំណោម ៦៨ ប្រទេស ដែលមានទិន្នន័យ សម្រាប់ទាំងពីរឆ្នាំ មានប្រទេសចំនួន ៥៧ នៅក្នុងឆ្នាំ ២០០០ ដែលមានយុគភាពយេនឌ័រក្នុងអត្រា

**រូបភាពទី ៨ ៖ ចាប់តាំងពីឆ្នាំ ១៩៩៩ មក ភាគរយស្ត្រីនៅក្នុងបុគ្គលិកបង្រៀននៅបឋមសិក្សា មានការកើនឡើង ហើយនៅតាមប្រទេសជាច្រើន មួយភាគធំនៃចំនួនគ្រូបង្រៀនចូលថ្មី គឺជាស្ត្រី**

ភាគរយនៃគ្រូបង្រៀនជាស្ត្រីនៅកម្រិតបឋមសិក្សា ឆ្នាំ ១៩៩៩ និង ២០១២, ភាគរយគ្រូបង្រៀនចូលថ្មីជាស្ត្រី ២០០៩-២០១២




*ប្រភព* ៖ ឧបសម្ព័ន្ធ តារាងស្ថិតិ ៨ (បោះពុម្ព) និង 10A (គេហទំព័រ GMR), ការគណនារបស់ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានសកល លើការអប់រំសម្រាប់ទាំងអស់គ្នា (២០១៤) ដោយប្រើប្រាស់ទិន្នន័យពីមូលដ្ឋានទិន្នន័យរបស់ UIS

គង់វង្ស នៅថ្នាក់ទី ៥ ឬមាន GPI ដែលក្មេងប្រុសមានចំនួនតិចជាងក្មេងស្រី និង ៥៨ ប្រទេស នៅក្នុងឆ្នាំ ២០១១។

### *ភាពក្រីក្រនាំឱ្យគម្លាតយេនឌ័រកាន់តែជ្រាលជ្រៅ នៅក្នុងការបញ្ចប់ការអប់រំកម្រិតបឋមសិក្សា*

គម្លាតយេនឌ័រ នៅក្នុងការបញ្ចប់ការអប់រំនៅកម្រិតបឋមសិក្សា ក្នុងចំណោមកុមារក្រីក្រជាងគេ នៅតែមានទំហំធំធ្ងាយជាងកុមារ ដែលមានជីវភាពធូរធារជាងគេ។ នៅតាមបណ្ដាប្រទេសមួយចំនួន ដូចជា ប្រទេសឡាវ ម៉ូហ្សំប៊ិច និងអ៊ូហ្គាន់ដា ជាដើម ដែលសម្រេចបាននូវយុគភាពយេនឌ័រចាប់តាំងពីឆ្នាំ ១៩៩៩ មក សម្រាប់ក្មេងស្រីដែលមកពីគ្រួសារមានជីវភាពធូរធារជាងគេ ក្មេងស្រីក្រីក្រជាងគេ នៅតែនៅក្រោយឆ្ងាយពីក្មេងប្រុសក្រីក្រជាងគេ។

### *គម្លាតយេនឌ័រមានទំហំកាន់តែធំ និងមានប្រែប្រួលខុសៗគ្នានៅកម្រិតអប់រំមធ្យមសិក្សា*

គម្លាតយេនឌ័រ ក្នុងការអប់រំមធ្យមសិក្សា ត្រូវបានរកឃើញក្នុងច្រើនប្រទេសជាង ក្នុងការអប់រំកម្រិតបឋមសិក្សា។ ត្រឹមឆ្នាំ ២០១២ ក្នុងចំណោមប្រទេសដែលមានទិន្នន័យមាន ៦៣% ពុំទាន់បានសម្រេចយុគភាពយេនឌ័រនៅក្នុងការចុះឈ្មោះចូលរៀននៅមធ្យមសិក្សានៅឡើយទេ។ ភាគរយនៃប្រទេស ដែលមានគម្លាតយេនឌ័រ ដោយក្មេងប្រុសមានចំនួនតិចជាង និងក្មេងស្រីមានចំនួនតិចជាង គឺស្មើគ្នាពោលគឺជិត ៣២% ម្នាក់។ នៅអាហ្វ្រិចសាប់សាហារ៉ា និងអាស៊ីខាងត្បូង និងខាងលិច ក្មេងស្រីបន្តជួបការលំបាកក្នុងការចូលរៀននៅមធ្យមសិក្សាច្រើនជាង។ ផ្ទុយទៅវិញ នៅអាមេរិកឡាទីន និងការីប៉ៀន មានក្មេងប្រុសតែ ៩៣ នាក់ប៉ុណ្ណោះ ដែលចុះឈ្មោះចូលរៀន សម្រាប់រាល់ក្មេងស្រី ១០០ នាក់ ដែលជាកម្រិតដូចកាលពីឆ្នាំ ១៩៩៩ ដែរ។

## ការជម្រុញលើកកម្ពស់បរិយាកាសអំណោយផល

ការបន្តការតស៊ូមតិនៅកម្រិតសកល នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បាននាំឱ្យមានការផ្ដល់ការគាំទ្រមិនធ្លាប់មានពីរដ្ឋាភិបាល និងសង្គមស៊ីវិល ដល់យុគភាព និងសមភាពយេនឌ័រ ក្នុងវិស័យអប់រំ។ រដ្ឋាភិបាលបានអនុវត្តកំណែទម្រង់ច្បាប់ និងគោលនយោបាយ បញ្ជ្រាបយេនឌ័រទៅក្នុងរចនាសម្ព័ន្ធស្ថាប័នអប់រំ ការរៀបចំផែនការ និងថវិកា និងកសាងនូវការគាំទ្រពីមហាជននៅក្នុងសង្គម។

### *ការបញ្ជ្រាបយេនឌ័រ និងការរៀបចំថវិកា កំណត់ពីចំណុចដែលត្រូវផ្ដោតការយកចិត្តទុកដាក់*

ការបញ្ជ្រាបយេនឌ័រ មានគោលបំណងធ្វើឱ្យសមភាពយេនឌ័រ ក្លាយជាគំនិតសំខាន់មួយ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធ និងការអនុវត្ត នៅតាមស្ថាប័ននានា និងក្នុងសង្គមទាំងមូល ជាជាងជាបញ្ហា ឬវិស័យដោយឡែក។ មូលនិធិអភិវឌ្ឍន៍ស្ត្រីរបស់សហប្រជាជាតិ ដែលបច្ចុប្បន្ននេះហៅថា UN Women ខិតខំជម្រុញឱ្យមានការរៀបចំថវិកាឆ្លើយតបយេនឌ័រ នៅក្នុងប្រទេសជាង ៦០ ទូទាំងពិភពលោក។ ប៉ុន្តែ នៅតាមប្រទេសជាច្រើន ធនធានដើម្បីនាំឱ្យមានការផ្លាស់ប្ដូរ នៅមិនទាន់មានគ្រប់គ្រាន់នៅឡើយ អង្គភាពយេនឌ័រនៅតែពុំទទួលបានឱកាសគ្រប់គ្រាន់នៅក្នុងស្ថាប័ន ការគាំទ្រដល់ការងារតស៊ូមតិពុំមានគ្រប់គ្រាន់ ហើយការអនុវត្តត្រូវទទួលរងការកំហិត ដោយសារតែការរើសអើង ដែលចាក់ឫសយ៉ាងជ្រៅ។

### *កំណែទម្រង់ច្បាប់ និងគោលនយោបាយ គឺជាកត្តាដែលនាំឱ្យមានវឌ្ឍនភាព*

នៅក្នុងទិដ្ឋភាពសង្ខេប ដែលរៀបចំឡើងដោយយូណេស្កូកាលពីពេលថ្មីៗនេះ ក្នុងចំណោមរដ្ឋជាសមាជិកចំនួន ៥៩ ដែលបានធ្វើការរាយការណ៍ មានរដ្ឋជាសមាជិកចំនួន ៤០ បានលើកឡើងយ៉ាងជាក់ច្បាស់ពីការធានាសិទ្ធិទទួលបានការអប់រំ សម្រាប់ក្មេងស្រី និងស្ត្រី ឬអំពីការហាមឃាត់មិនឱ្យមានការរើសអើង ពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងរដ្ឋធម្មនុញ្ញជាតិ ច្បាប់ ឬគោលនយោបាយ ជាក់លាក់។ ប៉ុន្តែ ស្ថាប័នសង្គមបន្តធ្វើឱ្យអន្តរាយដល់ សមភាពយេនឌ័រ។ ច្បាប់ ឬការអនុវត្តដែលមានបង្កប់ការរើសអើងតាមពីដើមរៀងមក នៅតែបន្តមាន ហើយការធាប់រៀបការទាំងវ័យក្មេង នៅតែមានកម្រិតខ្ពស់ ដែលមិនអាចទទួលយកបាន។

## ការបង្កើនតម្រូវការ និងការគាំទ្រដល់សិទ្ធិទទួលបានការអប់រំ

រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលបានខិតខំជំនះឧបសគ្គខាងសេដ្ឋកិច្ច និងសង្គម-វប្បធម៌

ការសាងសង់អគារសិក្សា និងការកែលំអសម្ភារបរិក្ខារសាលារៀន អាចបង្កើនវត្តមានរបស់ក្មេងស្រី ក្នុងសាលារៀន

ដែលរារាំងដល់ការចូលរៀន និងកាត់បន្ថយគម្លាតយេនឌ័រ តាមវិធីសាស្ត្រសំខាន់ៗចំនួន ៣ ៖ លើកកម្ពស់គុណតម្លៃ និងអាកប្បកិរិយាវិជ្ជមាន ចំពោះការអប់រំរបស់ក្មេងស្រី តាមរយៈយុទ្ធនាការកៀងគរសហគមន៍ និងតស៊ូមតិ, ការផ្តល់ការលើកទឹកចិត្ត ដើម្បីកាត់កងការបង់ថ្លៃសិក្សា និងការខាតបង់ឱកាស និងការដោះស្រាយបញ្ហាធាប់រៀបការទាំងវ័យក្មេង និងការមានផ្ទៃពោះរបស់ក្មេងជំទង់។

ជារឿយៗគោលនយោបាយអប់រំរបស់ប្រទេសកំពុងអភិវឌ្ឍច្រើនតែមើលរំលងការចុះឈ្មោះចូលរៀន និងការបញ្ចប់ការសិក្សារបស់ក្មេងប្រុស

## *ការផ្លាស់ប្តូរអាកប្បកិរិយា និងការកៀងគរការគាំទ្រដល់ការអប់រំរបស់ក្មេងស្រី*

យុទ្ធនាការជាតិ ត្រូវបានប្រើប្រាស់ ជាផ្នែកមួយនៃក្របខ័ណ្ឌគោលនយោបាយទូលំទូលាយ ដើម្បីធ្វើការផ្លាស់ប្តូរអាកប្បកិរិយារបស់មាតាបិតា និងកសាងនូវមូលដ្ឋានសម្រាប់ផ្តល់ការគាំទ្រដល់ការអប់រំរបស់ក្មេងស្រី។ យុទ្ធនាការដែលមានប្រសិទ្ធភាព ក្នុងការជម្រុញឱ្យមានការចូលរួមពីច្រើនវិស័យ បានទទួលការគាំទ្រពីផែនការ និងគោលនយោបាយនៅថ្នាក់ជាតិ និងមានការចូលរួមដោយផ្ទាល់ពីអង្គការ និងសហគមន៍នៅមូលដ្ឋាន។

## *ការកាត់បន្ថយការបង់ថ្លៃសិក្សា*

ចំណាយពាក់ព័ន្ធនឹងសាលារៀនអាចមានផលប៉ះពាល់លើក្មេងស្រីដោយមិនសមាមាត្រ។ ការលើកលែងការបង់ថ្លៃ និងកម្មវិធីអាហារូបករណ៍ ដែលផ្តោតចំគោលដៅ អាចកាត់កងការបង់ថ្លៃសិក្សាដោយផ្ទាល់ ហើយប្រាក់ឧបត្ថម្ភអាចជួយកាត់បន្ថយចំណាយបន្ថែម សម្រាប់គ្រួសារ។ ប៉ុន្តែ បញ្ហាសមធម៌នៅតែជាក្តីបារម្ភមួយ។ ឧទាហរណ៍ នៅក្នុងប្រទេសបង់ក្លាដេស បើទោះបីជាមានការបញ្ជាក់ពីជោគជ័យនៃកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ក្មេងស្រីជនបទដែលរៀននៅតាមសាលាមធ្យមសិក្សាក៏ដោយក្មេងស្រី ដែលមកពីគ្រួសារមានជីវភាពធូរធា និងមាន ដីធ្លី បានទទួលប្រយោជន៍លើសលុបពីកម្មវិធីនេះ។

## *ការធាប់រៀបការទាំងវ័យក្មេង និងការមានផ្ទៃពោះពេលនៅវ័យជំទង់*

ការធាប់រៀបការទាំងវ័យក្មេង និងការមានផ្ទៃពោះពេលនៅវ័យជំទង់ ជាកត្តាដាក់កំហិតលើការទទួលបានការអប់រំ និងការបន្តការអប់រំរបស់ក្មេងស្រី ប៉ុន្តែវឌ្ឍនភាព ក្នុងការឈានទៅលុបបំបាត់ការរៀបការរបស់កុមារ នៅក្នុងសកលលោកទាំងមូល នៅមានភាពយឺតយ៉ាវនៅឡើយ។ ទិន្នន័យសម្រាប់ឆ្នាំ ២០០០-២០១១ បានបង្ហាញថា ក្នុង ៤១ ប្រទេស ស្ត្រីអាយុពី ២០ ដល់ ២៤ ឆ្នាំ ចាប់ពី ៣០% ឡើងទៅបានរៀបការឬរស់នៅជាមួយដៃគូតាំងពីមុនអាយុ ១៨ ឆ្នាំ។ ច្បាប់តែមួយគត់ មិនអាចជាកត្តារារាំងប្រកបដោយប្រសិទ្ធភាព ចំពោះការអនុវត្តបែបនេះឡើយ។ ការវាយតម្លៃលើច្បាប់ជាតិស្តីពីអាពាហ៍ពិពាហ៍ឆ្នាំ ១៩៧៤ របស់ប្រទេសឥណ្ឌូនេស៊ី បានរកឃើញថា ពុំមានការចាកឆ្ងាយពីនិន្នាការនៃការរៀបអាពាហ៍ពិពាហ៍របស់កុមារឡើយ ក្រោយពេលដែលច្បាប់នេះត្រូវបានដាក់ឱ្យអនុវត្ត។ ប៉ុន្តែ ករណីអាពាហ៍ពិពាហ៍កុមារមានការថយ ចុះយ៉ាងច្រើន នៅតាមប្រទេសមួយចំនួន។ នៅក្នុងប្រទេសអេត្យូពី ប្រេវ៉ាឡង់នៃអាពាហ៍ពិពាហ៍កុមារ មានការថយចុះជាង ២០% ចន្លោះពីឆ្នាំ ២០០៥ និង ២០១១ ដោយសារតែការផ្លាស់ប្តូរក្នុងច្បាប់ ការតស៊ូមតិ និងយុទ្ធនាការតាមសហគមន៍។

## ពង្រីក និងកែលំអហេដ្ឋារចនាសម្ព័ន្ធសាលារៀន

គោលដៅនៃយុគភាព និងសមភាពយេនឌ័រ ទទួលបានការគាំទ្រដោយផ្ទាល់ និងដោយប្រយោលពីគោលនយោបាយដើម្បីបង្កើនការមាន និងភាពគ្រប់គ្រាន់នៃហេដ្ឋារចនាសម្ព័ន្ធសាលារៀន។ ការបង្កើនចំនួនសាលារៀន រាប់បញ្ចូលទាំងសាលារៀនតែសម្រាប់សិស្សស្រី និងការកែលំអសម្ភារបរិក្ខារ ក្នុងសាលារៀន ជាពិសេស សម្ភារបរិក្ខារទឹក និងអនាម័យ អាចបង្កើនវត្តមានរបស់ក្មេងស្រីក្នុងថ្នាក់រៀនបាន។

## *កាត់បន្ថយចំងាយទៅកាន់សាលារៀន*

ការសាងសង់សាលារៀន នៅតាមសហគមន៍ ដែលមិនបានទទួលសេវាគ្រប់គ្រាន់ បានជួយជំនះឧបសគ្គពាក់ព័ន្ធនឹងចំងាយ ចំពោះការអប់រំរបស់ក្មេងស្រី។ នៅក្នុងខេត្ត Ghor ប្រទេសអាហ្វហ្គានីស្ថាន នៅតាមភូមិ ដែលត្រូវបានជ្រើសរើសតាមបែបចៃដន្យ ដើម្បីទទួលបានអគារសិក្សាកម្រិតបឋមសិក្សា ការចុះឈ្មោះចូលរៀនសរុបមានការកើនឡើង ៤២ ភាគរយចំណុច ហើយការចុះឈ្មោះចូលរៀនរបស់ក្មេងស្រី កើន ឡើង ១៧ ភាគរយចំណុច ច្រើនជាងការចុះ

ឈ្មោះចូលរៀនរបស់ក្មេងប្រុស ដែលនាំឱ្យគម្លាតយេនឌ័រត្រូវបានលុបបំបាត់។

### *កែលំអសម្ភាររូបវន្តទឹក និងអនាម័យ*

ការផ្តល់សម្ភាររូបវន្តអនាម័យ ដែលមានសុវត្ថិភាព និងដោយឡែកដល់ក្មេងស្រី គឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយ ដើម្បីបង្កើនវត្តមានរបស់ ក្មេងស្រីក្នុងសាលារៀន និងលើកកម្ពស់បរិយាកាសក្នុងសាលារៀនឱ្យកាន់តែមានសមធម៌។ ការផ្តល់ទឹក និងអនាម័យក្នុងសាលារៀន នៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើន មានការកើនឡើងនៅក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ប៉ុន្តែវឌ្ឍនភាពនៅមានភាពយឺតយ៉ាវនៅឡើយ ៖ ក្នុងចំណោម ១២៦ ប្រទេស ដែលមានទិន្នន័យ ភាគរយមធ្យមនៃសាលាបឋមសិក្សា ដែលមានការគ្របដណ្តប់សេវាអនាម័យគ្រប់គ្រាន់ បានកើនឡើងពី ៥៩% នៅក្នុងឆ្នាំ ២០០៨ ដល់ ៦៨% នៅក្នុងឆ្នាំ ២០១២។

### គោលនយោបាយ ដើម្បីបង្កើនការចូលរួមរបស់ក្មេងប្រុសក៏ចាំបាច់ត្រូវមានផងដែរ

ខណៈពេលដែលក្មេងស្រី នៅតែមានលទ្ធភាពតិចជាងក្មេងប្រុស ក្នុងការចូលរៀននៅសាលារៀនពីដំបូង នៅក្នុងប្រទេសជាច្រើន ក្មេងប្រុសប្រឈមនឹងការមិនបានឡើងទៅថ្នាក់ខ្ពស់ និងបញ្ចប់វដ្តនៃការអប់រំខ្ពស់ជាងក្មេងស្រី។ អត្រាបោះបង់ចោលការសិក្សាខ្ពស់របស់ក្មេងប្រុស ក៏មានភាពពាក់ព័ន្ធយ៉ាងទូលំទូលាយដល់ទំនាក់ទំនងយេនឌ័រផងដែរ។ ការស្រាវជ្រាវ នៅក្នុងឆ្នាំ ២០០៩ និង ២០១០ នៅក្នុងប្រទេសប្រេស៊ីល ឈីលី ក្រូអាត ឥណ្ឌា ម៉ិចស៊ិច និងរវ៉ាន់ដា បានរកឃើញថា បុរសដែលមានការអប់រំកាន់តែតិច និងសម្តែងការយល់ឃើញដែលមានការរើសអើងផ្នែកយេនឌ័រ ច្រើនតែប្រព្រឹត្តអំពើហិង្សាក្នុងផ្ទះ ហើយប្រសិនបើពួកគេធ្វើជាឪពុក ពួកគេមិនសូវចូលរួមមើលថែកូនឡើយ។

### *មានកត្តាជាច្រើន ដែលបង្កើនហានិភ័យបោះបង់ចោលការសិក្សារបស់ក្មេងប្រុស*

មានក្មេងប្រុសជាច្រើននាក់ ធាប់បោះបង់ចោលការសិក្សា ដោយសារតែភាពក្រីក្រ និងកាតព្វកិច្ច ឬបំណងប្រាថ្នាចង់ធ្វើការងារដែលជារឿយៗកើតឡើងគួបផ្សំនឹងការចូលរៀនយឺត ការរៀនមិនបានពូកែ និងការមិនចាប់អារម្មណ៍គ្រប់គ្រាន់លើសាលា ក៏ដូចជាកត្តាផ្សេងទៀត ដូចជាជាតិពន្ធ និងការបាត់បង់ឱកាសក្នុងទម្រង់ផ្សេងទៀត។

### *គោលនយោបាយ ដើម្បីឆ្លើយតបចំពោះការបោះបង់ចោលការសិក្សារបស់ក្មេងប្រុស នៅមានកម្រិត*

ជារឿយៗ គោលនយោបាយអប់រំរបស់ប្រទេសកំពុងអភិវឌ្ឍ ផ្តោតការយកចិត្តទុកដាក់តិចតួចលើការបង្កើនការចុះឈ្មោះចូលរៀន របស់ក្មេងប្រុស និងការបញ្ចប់ការសិក្សារបស់ពួកគេ សូម្បីតែនៅក្នុងប្រទេសដែលមានគម្លាតយេនឌ័រខ្លាំង ដែលចំនួនក្មេងប្រុស មានតិចជាងចំនួនក្មេងស្រីក៏ដោយ។ ប្រទេសនៅការីបៀន បានធ្វើការចែករំលែកយ៉ាងសកម្មនូវព័ត៌មានអំពីយុទ្ធសាស្ត្រ និងអន្តរាគមន៍របស់ខ្លួន ដូចជា ការផ្តល់ ការណែនាំផ្ទាល់ គំនិតផ្តួចផ្តើមឱកាសទីពីរ ការបណ្តុះបណ្តាល និងកិច្ចពិគ្រោះយោបល់សហគមន៍ ក្នុងគោលបំណងឆ្លើយតបចំពោះការបោះបង់ចោលការសិក្សា។

ចំនួនស្ត្រី នៅក្នុងបុគ្គលិកបង្រៀន មានការថយចុះ នៅពេលដែលកម្រិតនៃការអប់រំកាន់តែមានការកើនឡើង

### បរិយាកាសប្រកបដោយសមធម៌ក្នុងសាលារៀន និងថ្នាក់រៀន

សមភាពយេនឌ័រ នៅក្នុងការអប់រំ ទាមទារឱ្យមានមិនត្រឹមតែសមភាពក្នុងការទទួលបានការអប់រំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសមភាព នៅក្នុងដំណើរការនៃការរៀនសូត្រ លទ្ធផលនៃការអប់រំ និងលទ្ធផលខាងក្រៅទៀតផង។ មានកត្តាចំនួន ៤ ដែលមានសារៈសំខាន់ ចំពោះការបង្កើនគុណភាពនៃការរៀនសូត្រ ជាពិសេស សម្រាប់ក្មេងស្រី ៖ ការបង្កើនចំនួន និងគុណភាពរបស់គ្រូ រាប់បញ្ចូលទាំងគ្រូស្រីផងដែរ, ការលុបបំបាត់ភាពលំអៀងខាងយេនឌ័រចេញពីកម្មវិធីសិក្សា និងសៀវភៅសិក្សា, ការធ្វើឱ្យការអនុវត្តក្នុងថ្នាក់រៀនកាន់តែគិតគូរពីយេនឌ័រច្រើនជាងមុន តាមរយៈការបណ្តុះបណ្តាល, និងការដោះស្រាយអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។

### *ការជ្រើសរើសគ្រូបង្រៀនភេទស្រី*

វត្តមានរបស់របស់អ្នកគ្រូ អាចបន្ធូរបន្ថយការភ័យខ្លាចខាងសន្តិសុខរបស់មាតាបិតា និងបង្កើនតម្រូវការនៃការរៀនសូត្ររបស់ក្មេងស្រី ជាពិសេស នៅតាមប្រទេស ដែលមានរបាំងវប្បធម៌ និងសង្គម ចំពោះការចុះឈ្មោះចូលរៀនរបស់ក្មេងស្រី។ នៅក្នុងសកលលោកទាំងមូល ភាគរយស្ត្រី

ក្នុងបុគ្គលិកបង្រៀននៅបឋមសិក្សា បានកើនឡើង ចាប់តាំងពីឆ្នាំ ១៩៩៩ មកពី ៥៨% ដល់ ៦៣% នៅក្នុងឆ្នាំ ២០១២។ សម្រាប់ការអប់រំកម្រិតមធ្យមសិក្សា ចំនួនគ្រូបង្រៀនជាស្ត្រីជាមធ្យម នៅមិនមានការផ្លាស់ប្តូរ ដោយមានកម្រិត ៥២%។ សូម្បីតែនៅក្នុងករណីដែលគ្រូ ភាគច្រើនជាស្ត្រីក៏ដោយ បើគិតជាសមាមាត្រ មានស្ត្រីតិចជាងបុរស ដែលកាន់តួនាទីជាអ្នកដឹកនាំ។

## *ការបណ្តុះបណ្តាលគិតគូរពីយេនឌ័រ សម្រាប់អនុវត្តក្នុងថ្នាក់រៀន*

អាកប្បកិរិយា ការអនុវត្ត និងការរំពឹងទុករបស់គ្រូលើក្មេងប្រុស និងក្មេងស្រី នៅក្នុងថ្នាក់រៀន អាចនាំឱ្យកើតឡើងជាថ្មីនូវផ្នត់គំនិតយេនឌ័រ និងមានផលប៉ះពាល់មកលើការលើកទឹកចិត្ត ការចូលរៀន និងលទ្ធផលនៃការរៀនសូត្ររបស់ក្មេងស្រី និងក្មេងប្រុស។ នៅក្នុងបរិបទជាច្រើន ការសង្កេតមើលថ្នាក់រៀនបង្ហាញថា គ្រូបង្រៀនទាំងពីរភេទ ធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងក្មេងប្រុសញឹកញាប់ជាង ដែលលើកទឹកចិត្ត ឱ្យក្មេងស្រីមិនសូវមានសកម្មភាព។ ការអប់រំគ្រូពាក់ព័ន្ធជាមួយនឹងការអប់រំបញ្ចូលគ្នា គរុកោសល្យដែលគិតគូរពីយេនឌ័រ និងការគ្រប់គ្រងថ្នាក់រៀន អាចកាត់បន្ថយភាពលំអៀង និងកសាងនូវបរិស្ថានសាលារៀន ដែលកាន់តែផ្តល់ការគាំទ្រច្រើនជាងមុន។ ប៉ុន្តែ សូម្បីតែនៅក្នុងករណីដែលគោលនយោបាយទាំងនេះមានក៏ដោយ ការពុំមានយុទ្ធសាស្ត្រដែលច្បាប់លាស់ ការអនុវត្ត និងការត្រួតពិនិត្យនៅមានកម្រិតខ្សោយ និងការវាយតម្លៃមិនគ្រប់គ្រាន់ជារឿយៗ ជាកត្តាដាក់កំហិតលើប្រសិទ្ធភាពនៃគោលនយោបាយទាំងនេះ។

## *កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សា ដើម្បីលើកកម្ពស់សមភាពយេនឌ័រ*

បើទោះបីជាមានការខិតខំប្រឹងប្រែង ដើម្បីបង្កើនគុណភាពយេនឌ័រយ៉ាងណាក៏ដោយ ភាពលំអៀងខាងសៀវភៅសិក្សា នៅតែកើតមានជាទូទៅ នៅប្រទេសជាច្រើន មួយផ្នែក ដោយសារតែកង្វះឆន្ទៈនយោបាយ និងការគាំទ្រនៅក្នុងសង្គមទាំងមូល។ កម្មវិធីសិក្សា ដែលឆ្លើយតបចំពោះយេនឌ័រ មានសក្តានុពលផ្តល់ការគាំទ្រដល់ការរៀនសូត្រ និងជម្រុញលើកកម្ពស់ទំនាក់ទំនងយេនឌ័រដែលវិជ្ជមាន។ ការអប់រំផ្លូវភេទ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺជាធាតុផ្សំដ៏សំខាន់មួយរបស់កម្មវិធីសិក្សា សម្រាប់លើកកម្ពស់សមភាពយេនឌ័រ ប៉ុន្តែកម្មវិធីអប់រំផ្លូវភេទ អាចខកខានមិនបានផ្តោតលើទំនាក់ទំនងយេនឌ័រ ដែលមានអមជាមួយនឹងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជឡើយ។

## *ការដោះស្រាយអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ នៅតាមសាលារៀន*

អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ នៅក្នុងសាលារៀន កើតមានជាទូទៅ។ ក្មេងប្រុសទទួលរងអំពើហិង្សាផ្លូវកាយច្រើនជាង ខណៈពេល ដែលក្មេងស្រីច្រើនតែទទួលរងការបៀតបៀន និងការរំលោភបំពានផ្លូវភេទ ដែលបង្កឡើងដោយសិស្សប្រុស និងគ្រូ។ ការអុកឡុករំខានអ្នកស្រឡាញ់ភេទដូចគ្នា និងការអុកឡុករំខានតាមអ៊ីនធឺណិត ក៏ត្រូវបានទទួលស្គាល់ថាជាបញ្ហាគួរឱ្យព្រួយបារម្ភផងដែរ។ បណ្តាប្រទេសនៅអាហ្វ្រិចសាប់សាហារ៉ា គឺជាប្រទេសដែលស្ថិតនៅជួរមុខ នៅក្នុងការរៀបចំគោលនយោបាយ ដើម្បីដោះស្រាយបញ្ហាហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ជាពិសេស អំពើហិង្សាផ្លូវភេទ។ ក្លឹបកុមារី និងកម្មវិធីលើកកម្ពស់ភាពអហិង្សាក្នុងចំណោមបុរស និងក្មេងប្រុស បានបង្ហាញឱ្យឃើញពីការផ្លាស់ប្តូរអាកប្បកិរិយាជាវិជ្ជមាន។ ប៉ុន្តែ ជារួមមានភស្តុតាងតិចតួច ដែលបង្ហាញថា ការកើនឡើងនូវការ យល់ដឹងអំពីប្រេវ៉ាឡង់នៃអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ តាមសាលារៀន ត្រូវបានគេបម្លែងឱ្យទៅជាសកម្មភាពប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយអំពើហិង្សានោះ។

## គាំទ្រឱ្យមានសមភាពនៅក្នុងលទ្ធផលនៃការរៀនសូត្រ

ការសម្រេចឱ្យបាននូវសមភាពយេនឌ័រ នៅក្នុងវិស័យអប់រំ តម្រូវឱ្យមានមិនត្រឹមតែការកាត់បន្ថយគម្លាតនៃឱកាសអប់រំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលទ្ធផលនៃការសិក្សាផងដែរ។ ការវាយតម្លៃលើការរៀនសូត្រនៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ បង្ហាញថា នៅក្នុងប្រទេសភាគច្រើន ក្មេងស្រីសម្រេចបានលទ្ធផលជារួមខាងអំណានបានល្អជាង ហើយក្មេងប្រុសសម្រេចបានលទ្ធផលល្អជាងខាងគណិតវិទ្យា បើទោះបីជាគម្លាតនៃលទ្ធផលសិក្សាខាងគណិតវិទ្យានេះកាន់តែរួមតូចទៅៗក៏ដោយ។ លទ្ធផលសិក្សាខាងវិទ្យាសាស្ត្រមានការប្រែ

ប្រួល ដោយនៅក្នុងប្រទេសជាច្រើន ពុំមានចំណុចខុសគ្នាគួរឱ្យកត់សម្គាល់រវាងក្មេងប្រុស និងក្មេងស្រីឡើយ។

### *នៅតាមប្រទេសក្រីក្រ ក្មេងស្រីបន្តជួបការលំបាក នៅក្នុងការសម្រេចបាននូវលទ្ធផលសិក្សា*

នៅតាមប្រទេសក្រីក្រមួយចំនួន ដែលក្មេងស្រីធ្លាប់ជួបប្រទះនឹងឧបសគ្គកន្លងមក ដែលនាំឱ្យពួកគេមិនអាចចូលរួមដោយស្មើភាពក្នុងការអប់រំបាន ពួកគេបន្តជួបការលំបាកក្នុងការទទួលបានជំនាញសំខាន់ៗ។ នៅតំបន់ជនបទនៃប្រទេសប៉ាគីស្ថាន គម្លាតយេនឌ័រមានកម្រិតទាប ក្នុងចំណោមសិស្សថ្នាក់ទី ៥ ដោយនៅក្នុងករណីខ្លះ សិស្សស្រីមានចំនួនច្រើនជាង។ ប៉ុន្តែ នៅពេលដែលគេរាប់ចូលទាំងក្មេងស្រី ដែលមិនកំពុង ស្ថិតនៅក្នុងសាលារៀន លទ្ធផលសិក្សាជៀបរបស់ក្មេងស្រីមានលក្ខណៈអន់ជាង ក្នុងចំណោមកុមារអាយុពី ១០ ដល់ ១២ ឆ្នាំ ជាពិសេសនៅតាមខេត្ត និងដែនដីក្រីក្រ និងមិនសូវមានការអភិវឌ្ឍ។

### *ការដោះស្រាយបញ្ហាលទ្ធផលសិក្សាទាបរបស់ក្មេងប្រុស*

ក្តីបារម្ភពាក់ព័ន្ធជាមួយនឹងការសម្រេចបានលទ្ធផលសិក្សាទាបរបស់ក្មេងប្រុស ជាពិសេស ខាងអំណាន មានការកើនឡើង ចាប់តាំងពី ឆ្នាំ ២០០០ មក។ ប៉ុន្តែ មានប្រទេសតែមួយចំនួនតូចប៉ុណ្ណោះ ដែលមានក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ ដើម្បីដោះស្រាយក្តីបារម្ភនេះ។ យុទ្ធសាស្ត្រ និងអន្តរាគមន៍ទ្រង់ទ្រាយតូចលើការបង្រៀន និងរៀន ដែលមានសក្តានុពលក្នុងការដោះស្រាយបញ្ហាលទ្ធផលសិក្សាទាបរបស់ក្មេងប្រុស រួមមាន ការផ្តោតការយកចិត្តទុកដាក់លើជំនាញដែលអាចផ្ទេរបាន គោលវិធីក្នុងថ្នាក់រៀនដែលជម្រុញឱ្យមានការរៀនសូត្រឱ្យបានសកម្ម ការពិនិត្យតាមដានសិស្សម្នាក់ៗនិងការដាក់ចេញនូវចំណុចដៅនិងក្រមសីលធម៌សាលារៀន ដែលលើកកម្ពស់ឱ្យមានការគោរពគ្នា និងការ សហការគ្នា។

# ប័ណ្ណរបាយការណ៍ ២០០០-២០១៥

## គោលដៅទី ៦ គុណភាពនៃការអប់រំ

កែលំអគ្រប់ទិដ្ឋភាពទាំងអស់នៃគុណភាពនៃការអប់រំ និងធានាឱ្យមានឧត្តមភាពសម្រាប់ទាំងអស់គ្នា ដើម្បីឱ្យមានការសម្រេចបាននូវលទ្ធផល សិក្សាដែលមានការទទួលស្គាល់ និងអាចវាស់វែងបាន ដោយមនុស្សទាំងអស់គ្នា ជាពិសេស ខាងអក្ខរកម្ម ចំណេះដឹងអំពីលេខនព្វ និងបំណិន ជីវិតសំខាន់ៗ

### ពិន្ទុសកល *

*ក្នុងចំណោមប្រទេសដែលមានទិន្នន័យ

**ផលធៀបសិស្ស-គ្រូ នៅបឋមសិក្សា**




**ផលធៀបសិស្ស-គ្រូដែលបាន ទទួលការបណ្តុះបណ្តាលនៅបឋមសិក្សា**




### ជោគជ័យ

**ការចូលរៀន និងការរៀនសូត្រ**

មិនចាំបាច់មានមួយអត់មួយ




**ផលធៀបសិស្ស-គ្រូ**

នៅកម្រិតបឋមសិក្សា ផលធៀបសិស្ស-គ្រូ មានការថយចុះ នៅក្នុងប្រទេសចំនួន ១២១ ក្នុងចំណោម ១៤៦ ប្រទេស




ប្រទេសកុងហ្គោ និងម៉ាលី បានកាត់បន្ថយផលធៀបសិស្ស-គ្រូរបស់ខ្លួន ចំនួនសិស្ស ១០ នាក់ ក្នុងគ្រូម្នាក់ ហើយក្នុងពេលជាមួយគ្នា បង្កើនចំនួនសិស្ស ចុះឈ្មោះចូលរៀនទ្វេដង




### កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើង

**ការវាយតម្លៃថ្នាក់ជាតិ**

ដើម្បីវាស់វែងលទ្ធផលនៃការរៀនសូត្រ




**កម្មវិធីគាំពារសង្គមចំគោលដៅ**



នៅក្នុងប្រទេសម៉ិចស៊ិកូ ដោយផ្តោតលើកុមារផង និង មនុស្សពេញវ័យផង ផ្តោតសំខាន់លើគ្រួសារជួបការលំបាក ជួយបង្កើនលទ្ធផលសិក្សា

**គោលនយោបាយ ដើម្បីកែលំអ**

ការបណ្តុះបណ្តាលគ្រូ

នៅក្នុងប្រទេសនេប៉ាល់ ដើម្បីកាត់បន្ថយផលធៀបសិស្ស-គ្រូ នៅបឋមសិក្សា




### បញ្ហាប្រឈមដែលនៅបន្តមាន

**កង្វះគ្រូដែលបានទទួលការបណ្តុះបណ្តាល**

នៅក្នុងឆ្នាំ ២០១២ នៅក្នុងប្រទេស ១ ភាគ ៣




**ការខ្វះចន្លោះក្នុងការរៀនសូត្រចាប់ផ្តើមតាំងពីថ្នាក់ដំបូង**




កុមារជាច្រើននាក់មិនបានរៀនចេះចំណេះដឹងជាមូលដ្ឋានឡើយ

**កង្វះឯកសារ និងសម្ភារ**



សៀវភៅសិក្សា និងសម្ភារឧបទ្ទេស និងសង្ហារឹមក្នុងថ្នាក់រៀន

### វិឡនភាពមិនស្មើគ្នា

**គ្រូដែលបានទទួលការបណ្តុះបណ្តាល**




នៅក្នុងប្រទេសអង់ហ្គោឡា បេនីន ហ្គីនីនៅអេក្វាទ័រ ហ្គីនីប៊ីសាវ និងស៊ូដង់ភាគខាងត្បូង

**ការអប់រំពហុភាសា**



ចាំបាច់ត្រូវតែមាននិរន្តរភាព ដើម្បីធ្វើឱ្យការសិក្សាកាន់តែមាន ភាពល្អប្រសើរជាងមុន

**គម្លាតរវាងតំបន់ប្រជុំជន និងជនបទ**



មានភាពល្អប្រសើរជាងមុន នៅក្នុងប្រទេសអាមេរិចឡាទីន ចំនួន ៨ ប៉ុន្តែ ៦ ប្រទេស នៅមានភាពយឺតយ៉ាវខាងការ រៀនសូត្រ

### អនុសាសន៍ សម្រាប់ក្រោយឆ្នាំ ២០១៥

១. ចាំបាច់ត្រូវមានគ្រូបង្រៀនច្រើនជាងមុន និងទទួលបានការបណ្តុះបណ្តាលប្រសើរជាងមុន កែលំអឯកសារសិក្សា និងកម្មវិធីសិក្សាដែលពាក់ព័ន្ធ

២. ចាំបាច់ត្រូវមានការវាយតម្លៃលើការរៀនសូត្រ ដើម្បីគាំទ្រដល់ការអប់រំ ដែលមានគុណភាពល្អ និងលទ្ធផលនៃការរៀនសូត្រប្រកបដោយសមធម៌

**ត្រូវប្រឹងប្រែងថែមទៀត**

# គោលដៅទី ៦ គុណភាពនៃការអប់រំ

*កែលំអគ្រប់ទិដ្ឋភាពទាំងអស់នៃគុណភាពនៃការអប់រំ និងធានាឱ្យមានឧត្តមភាពសម្រាប់ទាំងអស់គ្នា ដើម្បីឱ្យមានការសម្រេចបាននូវលទ្ធផលសិក្សាដែលមានការទទួលស្គាល់ និងអាចវាស់វែងបាន ដោយមនុស្សទាំងអស់គ្នា ជាពិសេស ខាងអក្ខរកម្ម ចំណេះដឹងអំពីលេខនព្វន្ធ និងបំណិនជីវិតសំខាន់ៗ*

ខណៈពេលដែលមានប្រទេសជាច្រើនបានសម្រេចនូវវឌ្ឍនភាពគួរឱ្យចាប់អារម្មណ៍ ខាងការទទួលបានការអប់រំ ចាប់តាំងពីមានក្របខ័ណ្ឌដាកាមក ការកែលំអគុណភាពមិនបានតាមឱ្យទាន់វឌ្ឍនភាពនេះឡើយ។ ការផ្លាស់ប្តូរដោយប្រុងប្រយ័ត្ន ក្នុងការផ្តោតការយកចិត្តទុកដាក់លើគុណភាព និងការរៀនសូត្រ ទំនងជាកាន់តែមានសារៈសំខាន់ចំពោះក្របខ័ណ្ឌសកល ក្រោយឆ្នាំ ២០១៥ ដោយហេតុថា ដូចដែលបង្ហាញ នៅក្នុងរបាយការណ៍ពិនិត្យតាមដានសកល ២០១៣/១៤ មានកុមារ ២៥០ លាននាក់ មិនមានឱកាសរៀនសូត្រចំណេះដឹងមូលដ្ឋានឡើយ បើទោះបីជាក្នុងចំណោមនេះ មានកុមារ ១៣០ លាននាក់ បានចំណាយពេលយ៉ាងហោចណាស់ ៤ ឆ្នាំ ក្នុងសាលារៀនក៏ដោយ។

## គេអាចបង្កើនការចូលរៀន និងការរៀនសូត្រប្រកបដោយសមធម៌ ក្នុងពេលជាមួយគ្នា

ខណៈពេលដែលការចុះឈ្មោះចូលរៀនមានការកើនឡើង កុមារដែលចូលមកក្នុងប្រព័ន្ធរបស់សាលារៀន ច្រើនតែមានប្រភពពីក្រុម ដែលជួបការលំបាក មានពិការភាព ឬរងផលប៉ះពាល់ ដោយសារកង្វះអាហារូបត្ថម្ភ និងភាពក្រីក្រ។ សិស្សដែលចូលរៀនថ្មី ច្រើនតែមកពីគ្រួសារ ដែលមាតាបិតាមិនសូវចេះអក្សរ ឬគ្រួសារដែលនិយាយភាសាមិនប្រើជាផ្លូវការក្នុងប្រទេស។ ផលប៉ះពាល់ដោយសារកត្តាទាំងនេះ អាចនាំឱ្យ ការសិក្សាមានកម្រិតទាបកើតឡើង នៅពេលដែលការចុះឈ្មោះចូលរៀនមានការកើនឡើង។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលរកឃើញពីការវាយតម្លៃលើការសិក្សានៅថ្នាក់តំបន់ និងអន្តរជាតិភាគច្រើន មិនបានឆ្លុះបញ្ចាំងពីចំណុចនេះឡើយ។

នៅក្នុងប្រទេសមួយចំនួន នៅអាហ្វ្រិចសាប់សាហារ៉ា ចំនួនកុមារ ដែលចូលរៀន និងបញ្ចប់ការសិក្សា មានការកើនឡើងចាប់ពីឆ្នាំ ២០០០ ដល់ ២០០៧។ ក្នុងពេលជាមួយគ្នា លទ្ធផលសិក្សាមានភាពប្រសើរជាងមុន ឬត្រូវបានរក្សាឱ្យនៅដដែល។ នៅកម្រិតអប់រំមធ្យមសិក្សាវិញក៏ដូច្នេះដែរ ដោយការចូលរៀន និងការរៀនសូត្រប្រកបដោយសមធម៌ មានការកើនឡើងទន្ទឹមគ្នា។ នៅក្នុងប្រទេសម៉ិចស៊ិច ការចុះឈ្មោះចូលរៀនរបស់កុមារអាយុ ១៥ ឆ្នាំ មានការកើនឡើងជិត ១២ ភាគរយចំណុចចន្លោះពីឆ្នាំ ២០០៣ ដល់ ២០១២ ខណៈពេលដែលពិន្ទុគណិតវិទ្យាជាមធ្យម នៅក្នុងកម្មវិធីវាយតម្លៃសិស្សជាអន្តរជាតិ (PISA) របស់ OECD មានការកើនឡើងពី ៣៨៥ ដល់ ៤១៣ ពិន្ទុ។

**មានការវាយតម្លៃលើការសិក្សាថ្នាក់ជាតិជាង១០០លើកត្រូវបានធ្វើឡើងចាប់តាំងពីមានក្របខ័ណ្ឌដាកាមក**

## គួរមានការពិនិត្យតាមដានលើវឌ្ឍនភាពនៃលទ្ធផលសិក្សា

យុទ្ធសាស្រ្តប្រកបដោយប្រសិទ្ធភាព ដើម្បីវាយតម្លៃ និងតាមដានចំណេះដឹង និងជំនាញ តម្រូវឱ្យមានការវាយតម្លៃលើការរៀនសូត្រក្នុងទ្រង់ទ្រាយធំ ដោយប្រើប្រាស់ការអង្កេតលើសំណាកគំរូជាគោល ដែលផ្តល់នូវព័ត៌មានអំពីលទ្ធផលសិក្សា ដែលសម្រេចបាននៅទូទាំង ប្រទេស។ ការវាយតម្លៃថ្នាក់ជាតិជាច្រើនទៀត កំពុងត្រូវបានធ្វើឡើង ចាប់តាំងពីមានក្របខ័ណ្ឌដាកាមក ចាប់ពីមានការវាយតម្លៃសរុបចំនួន ២៨៣ នៅក្នុងឆ្នាំ ១៩៩០-៩៩ រហូតដល់ ១១៦៧ នៅក្នុងឆ្នាំ ២០០០-១៣។ ប្រេវ៉ាឡង់នៃការវាយតម្លៃនេះ

កើតឡើងមិនត្រឹមតែនៅក្នុង ចំណោមប្រទេសដែលមានធនធានច្រើននោះទេ ប៉ុន្តែក៏មាននៅក្នុងប្រទេសក្រីក្រផងដែរ។

ការវាយតម្លៃថ្នាក់ជាតិភាគច្រើន អំពាវនាវឱ្យអាជ្ញាធរអប់រំបង្កើនកម្រិតចំណេះដឹង និងសមត្ថភាពរបស់សិស្ស។ ការពិនិត្យលើការសិក្សាចំនួន ៥៤ បង្ហាញថាមានការរៀបចំគោលនយោបាយអប់រំជាច្រើន ដោយប្រើប្រាស់ទិន្នន័យដែលបានពីការវាយតម្លៃថ្នាក់ជាតិនេះ ចាប់ពីកំណែទម្រង់កម្មវិធីសិក្សា និងការកែសម្រួលសៀវភៅសិក្សា រហូតដល់ការអប់រំ និងវិក្រឹតការគ្រូ ការរៀបចំឯកសារបង្រៀន ការជម្រុញឱ្យមាន ការចូលរួមពីមាតាបិតា ស្តង់ដានៃលទ្ធផលសិក្សា និងការវិភាជន៍ធនធាន ដើម្បីគាំទ្រដល់សាលារៀនដែលបំពេញការងារនៅខ្សោយ។

## *ការវាយតម្លៃដឹកនាំដោយប្រជាពលរដ្ឋ កាន់តែមានការកើនឡើង*

អង្គការសង្គមស៊ីវិល កាន់តែចូលរួមនៅក្នុងសកម្មភាពវាយតម្លៃ ដើម្បីផ្តល់ព័ត៌មានដល់ការរៀបចំគោលនយោបាយអប់រំជាតិ។ ការវាយតម្លៃតាមគ្រួសារ ដឹកនាំដោយប្រជាជនលើជំនាញលេខ និងអក្សររបស់កុមារ បានចាប់ផ្តើមធ្វើឡើងនៅក្នុងប្រទេសឥណ្ឌា នៅក្នុងឆ្នាំ ២០០៥ និងត្រូវបានអនុវត្តតាម នៅក្នុងប្រទេសប៉ាគីស្ថាន (ចាប់តាំងពីឆ្នាំ ២០០៨ មក) អ៊ូហ្គាន់ដា និងសាធារណរដ្ឋតង់ហ្សានី (២០០៩) ម៉ាលី (២០១១) និងសេណេហ្គាល់ (២០១២)។ រួមគ្នាការវាយតម្លៃទាំងនេះគ្របដណ្តប់លើកុមារបានជាង ១ លាននាក់ នៅក្នុងឆ្នាំ ២០១២។

ពិភពលោកខ្វះគ្រូបង្រៀន ៤ លាននាក់ដើម្បីឱ្យកុមារទាំងអស់បានចូលរៀនក្នុងសាលានៅឆ្នាំ២០១៥

## *ការវាយតម្លៃត្រូវបានប្រើប្រាស់ ដើម្បីវាយតម្លៃលើការរៀនសូត្រនៅថ្នាក់ដំបូង*

ចន្លោះពីឆ្នាំ ២០០៧ ដល់ពាក់កណ្តាលឆ្នាំ ២០១៤ មានប្រទេសជាង ៦០ បានធ្វើការវាយតម្លៃលើអំណានថ្នាក់ដំបូង (EGRAs) ចាប់ពីមួយលើកឡើងទៅ។ គិតត្រឹមពាក់កណ្តាលឆ្នាំ ២០១៤ មានប្រទេសជាង ២០ បានធ្វើការវាយតម្លៃលើគណិតវិទ្យាថ្នាក់ដំបូង (EGMAs)។ លទ្ធផលបង្ហាញពីរូបភាពគួរឱ្យព្រួយបារម្ភ ៖ កុមារជាច្រើននាក់ចំណាយពេល ២ ឬ ៣ ឆ្នាំ ក្នុងសាលា ដោយពុំចេះអានពាក្យសូម្បីតែមួយម៉ាត់ ហើយសាលារៀនជាច្រើនមិនបានបង្រៀនកុមារអំពីចំណេះដឹងមូលដ្ឋានពីជគណិត នៅឆ្នាំដំបូងៗឡើយ។ លទ្ធផលដែលបានពី EGRAs/EGMAs នេះបានជម្រុញឱ្យរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយគិតសារជាថ្មីពីគោលនយោបាយនានា ដើម្បីឱ្យសិស្សអាចសម្រេចបាននូវស្តង់ដារៀនសូត្រកម្រិត អប្បបរមាខាងអំណាន និងគណិតវិទ្យា។

## *ការវាយតម្លៃនៅថ្នាក់តំបន់ និងអន្តរជាតិ រួមចំណែកវាស់វែងសមធម៌ ក្នុងការរៀនសូត្រ*

បន្ថែមពីលើកំណើននៃការប្រើប្រាស់ការវាយតម្លៃថ្នាក់ជាតិ ប្រទេសនានាបានចូលរួមកាន់តែច្រើនឡើង នៅក្នុងការប្រៀបធៀបលទ្ធផលសិក្សារបស់សិស្សជាលក្ខណៈអន្តរជាតិ និងអន្តរប្រព័ន្ធ។ ការសិក្សាដែលធ្វើឡើងនៅអាមេរិចឡាទីនដែលហៅថា PERCE, SERCE និង TERCE ផ្តល់លទ្ធភាពឱ្យគេអាចធ្វើការវាយតម្លៃលើសមាសភាគនានា ដែលពាក់ព័ន្ធនឹងកម្រិតស្ទាត់ជំនាញក្នុងការសិក្សារបស់សិស្ស ដូចជាការរៀបចំកម្មវិធីសិក្សា និងសាវតារគ្រួសារ ជាដើម ក៏ដូចជា

**រូបភាពទី ៩ ៖ គម្លាតនៃផលធៀបសិស្ស-គ្រូ រវាងតំបន់មួយ និងតំបន់មួយទៀតនៅតែមានទំហំធំ**

ផលធៀបសិស្ស-គ្រូ ក្នុងពិភពលោក និងតាមតំបន់មួយចំនួន ១៩៩០-២០១២




*ប្រភព* ៖ មូលដ្ឋានទិន្នន័យ UIS

លើវឌ្ឍនភាពជារួមនៅថ្នាក់ជាតិ រួមទាំង ក្នុងការឈានទៅកាត់បន្ថយវិសមភាពផង។ ការវាយតម្លៃ PISA របស់ OECD ធ្វើការប្រមូលព័ត៌មានអំពីសិស្សអាយុ ១៥ ឆ្នាំ ដែលអាចឱ្យគេ

ធ្វើការភ្ជាប់ទំនាក់ទំនងវិសមភាព ក្នុងដើមកំណើតសង្គម ជាមួយនឹងជំនាញអក្ខរកម្ម និងលេខនព្វន្តបាន។

ប្រទេស OECD ភាគច្រើន បានផ្តួចផ្តើមឱ្យមានកំណែទម្រង់គោលនយោបាយ និងគំនិតផ្តួចផ្តើម ជាការឆ្លើយតបចំពោះលទ្ធផល PISA នេះ។ ការវាយតម្លៃលើការរៀនសូត្រក៏មានឥទ្ធិពលលើកំណែទម្រង់កម្មវិធីសិក្សា និងការបង្រៀននៅក្នុងប្រទេសជាច្រើនផងដែរ។ ប៉ុន្តែ ការវាយតម្លៃនៅថ្នាក់តំបន់ និងអន្តរជាតិ អាចនាំឱ្យមានបញ្ហាកើតមានឡើង។ ការបោះពុម្ពផ្សាយលទ្ធផលនៃការប្រៀបធៀប អាចមិនលើកទឹកចិត្តឱ្យមានការចូលរួមពីប្រទេសក្រីក្រ ដែលមានកុមារតិចតួចរៀនចេះចំណេះដឹងជាមូលដ្ឋាន។ ប្រទេសមួយចំនួនបានធ្វើការផ្លាស់ប្តូរខ្លឹមសារ គោលដៅនៃមុខវិជ្ជាដែលត្រូវមាន ដើម្បីអាចគ្របដណ្តប់ឱ្យបានកាន់តែប្រសើរលើសមត្ថភាពឆ្លងកម្មវិធីសិក្សា ដែលត្រូវបានធ្វើតេស្តនៅក្នុង PISA។

## ការវិនិយោគលើគ្រូមានសារៈសំខាន់យ៉ាងខ្លាំង

ក្របខ័ណ្ឌដាកា គូសបញ្ជាក់ថា ដើម្បីសម្រេចឱ្យបាននូវការអប់រំសម្រាប់ទាំងអស់គ្នា រដ្ឋាភិបាលចាំបាច់ត្រូវតែបង្កើនចំនួន និងកែលំអការពង្រាយគ្រូដែលមានជំនាញ និងមានទឹកចិត្តបង្រៀន។ ដើម្បីទាក់ទាញ និងរក្សាគ្រូបង្រៀនល្អៗ អ្នកតាក់តែងគោលនយោបាយ ចាំបាច់ត្រូវតែកែលំអការអប់រំគ្រូ ពង្រាយគ្រូឱ្យបានកាន់តែយុត្តិធម៌ជាងមុនផ្តល់ការលើកទឹកចិត្តក្នុងទម្រង់ជាបៀវត្សរ៍សមស្រប និងបង្កើតនូវមាគ៌ាអាជីព ដែលមានភាពទាក់ទាញ។

### *បើទោះបីជាមានវឌ្ឍនភាពក៏ដោយ កង្វះគ្រូបង្រៀននៅតែជាក្តីបារម្ភធ្ងន់ធ្ងរមួយ*

គម្លាតផលធៀបសិស្ស-គ្រូ រវាងតំបន់មួយ និងតំបន់មួយនៅតែមានកម្រិតខ្ពស់។ គិតត្រឹមឆ្នាំ ២០១២ ក្នុងចំណោម ១៦១ ប្រទេស ដែលមានទិន្នន័យ ប្រទេសចំនួន ២៩ មានផលធៀបសិស្ស-គ្រូនៅបឋមសិក្សា លើសពី ៤០ ៖ ១។ ក្នុងចំណោមប្រទេសទាំងនេះ មានប្រទេសចំនួន ២៤ ស្ថិតនៅអាហ្វ្រិចសាប់សាហារ៉ា។ ផលធៀបសិស្ស-គ្រូនៅបឋមសិក្សា មានការថយចុះ នៅក្នុងប្រទេសចំនួន ១២១ ក្នុងចំណោម ១៤៦ ប្រទេស ដែលមានទិន្នន័យ សម្រាប់ឆ្នាំ ១៩៩៩ និង២០១២។ ការកែលំអជាច្រើនកើតឡើងនៅតាមប្រទេស ដែលមានផលធៀបសិស្ស-គ្រូ ក្រោម ៤០ ៖ ១ ទៅហើយ។ នៅកម្រិតអប់រំមធ្យមសិក្សាបឋមភូមិ ក្នុងចំណោម ១០៥ ប្រទេស ដែលមានទិន្នន័យ សម្រាប់ឆ្នាំ ២០១២ ១៨ ប្រទេសមានផលធៀបលើសពី ៣០ ៖ ១។ ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១២ ផលធៀបនេះមានការកើនឡើងសិស្ស ៦ នាក់ ក្នុងគ្រូ ១ នាក់ នៅប្រទេសអេត្យូពី ហ្គាំបៀ ហ្គីនី ម៉ាលី និងមីយ៉ាន់ម៉ា។ ផលធៀបសិស្ស-គ្រូនៅមធ្យមសិក្សាទុតិយភូមិ នៅថេរ ឬមានការថយចុះនៅក្នុងប្រទេសភាគច្រើនដែលមានទិន្នន័យនៅក្នុងទសវត្សរ៍ចុងក្រោយនេះ។

ការបែងចែកគ្រូមិនបានស្មើគ្នានៅក្នុងប្រទេសនាំឱ្យបញ្ហាវិសមធម៌កាន់តែមានការកើនឡើង

### *មានចាំបាច់ត្រូវមានគ្រូបឋមសិក្សាប៉ុន្មាននាក់ ដើម្បីសម្រេចនូវសកលកម្មនៃការអប់រំបឋមសិក្សា ត្រឹមឆ្នាំ ២០១៥*

ចន្លោះពីឆ្នាំ ២០១២ ដល់ ២០១៥ ចាំបាច់ត្រូវមានគ្រូ ៤ លាននាក់ ដើម្បីសម្រេចឱ្យបាននូវសកលកម្មនៃការអប់រំកម្រិតបឋមសិក្សា ៖ ២,៦ លាននាក់ ដើម្បីជំនួសគ្រូដែលចូលនិវត្តន៍ ផ្លាស់ប្តូរការងារ ទទួលមរណភាព ឬឈប់ដោយសារជំងឺ និង ១,៤ លាននាក់ ដើម្បីបំពេញចំនួនគ្រូដែលខ្វះ ដើម្បីបំពេញទៅតាមការកើនឡើងនូវការចុះឈ្មោះចូលរៀន និងរក្សាផលធៀបសិស្សគ្រូឱ្យនៅក្រោម ៤០៖១។ តំបន់ និងប្រទេស មួយចំនួន ត្រូវការគ្រូបឋមសិក្សាបន្ថែមទៀត ក្នុងចំនួនច្រើនជាងគ្រូនៅកម្រិតផ្សេងទៀត។ តំបន់ដែលជួបប្រទះនឹងបញ្ហាប្រឈមធំជាងគេ គឺអាហ្វ្រិចសាប់សាហារ៉ា ដែលមានតម្រូវការគ្រូបន្ថែម ៦៣% នៃចំនួនគ្រូបន្ថែមសរុប។ ក្នុងចំណោម ៩៣ ប្រទេស ដែលត្រូវការគ្រូបន្ថែម មានតែ ២៩ ប្រទេសប៉ុណ្ណោះ ដែលអាចរកបានគ្រូបន្ថែម គិតត្រឹមឆ្នាំ ២០១៥ ហើយប្រទេស ៦៤ ទៀតនៅតែជួបប្រទះនឹងកង្វះគ្រូ។

### *គ្រូដែលបានទទួលការបណ្តុះបណ្តាល ៖ កង្វះគ្រូធ្ងន់ធ្ងរជាងគេ*

ការបង្កើនចំនួនគ្រូ គឺមិនគ្រប់គ្រាន់នោះទេ គុណភាពក៏ចាំបាច់ត្រូវតែកែលំអផងដែរ តាមរយៈគ្រូដែលឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ និងមានទឹកចិត្តបំពេញការងារ។ ប្រទេសជាច្រើនបានបង្កើនចំនួនគ្រូយ៉ាងឆាប់រហ័ស តាមរយៈការជួលអ្នកដែលពុំមានសមត្ថភាពសមស្រប ឱ្យធ្វើជាគ្រូ

បង្រៀន។ ក្នុងចំណោម ៩១ ប្រទេស ដែលមានទិន្នន័យឆ្នាំ ២០១២ ភាគរយនៃគ្រូបឋមសិក្សា ដែលបានទទួលការបណ្តុះបណ្តាល ស្របតាមស្តង់ដាជាតិមានពី ៣៩% នៅក្នុងប្រទេសហ្គីនីប៊ីសាវ ដល់ជាង ៩៥% នៅក្នុង ៣១ ប្រទេស។ ការព្យាករ ដែលធ្វើឡើងសម្រាប់ប្រទេសចំនួន ៤៦ បង្ហាញថា មានប្រទេសចំនួន ១២ មានគ្រូតិចជាង ៧៥% បានទទួលការបណ្តុះបណ្តាលស្របតាមស្តង់ដាជាតិ គិតត្រឹមឆ្នាំ ២០១៥។

បរិយាកាសសិស្សមជ្ឈមណ្ឌលអាចបង្កើតឡើងតាមរយៈការកែសម្រួលយុទ្ធសាស្រ្តរបស់គ្រូឱ្យស្របតាមបរិបទមូលដ្ឋាន

## *គម្លាតសមធម៌នៅក្នុងការពង្រាយគ្រូ ត្រូវការដំណោះស្រាយ*

ចំនួនគ្រូសរុប និងផលធៀបសិស្ស/គ្រូជាមធ្យមអាចលាក់កំបាំងមិនឱ្យគេឃើញពីរបាយមិនស្មើគ្នារបស់គ្រូបង្រៀននៅក្នុងប្រទេសនានា ដែលនាំឱ្យមានការព្រួយបារម្ភខាងសមធម៌។ ជាទូទៅ មានគម្លាតគួរឱ្យកត់សម្គាល់ និងបន្តមានរហូតរវាងអ្នកផ្តល់សេវាអប់រំខាងរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល។ នៅក្នុងប្រទេសនៅអាហ្វ្រិចសាប់សាហារ៉ាជាច្រើន រួមទាំង កុងហ្គោ រវ៉ាន់ដា និងអ៊ូហ្គាន់ដាផងផលធៀបសិស្ស/គ្រូ នៅសាលាបឋមសិក្សា មានច្រើនលើសពីផលធៀបសិស្ស/គ្រូនៅសាលាឯកជន ដល់ទៅសិស្សចាប់ពី ៣០ នាក់ឡើងទៅ។ សិស្សនៅតាមសាលារៀនជួបការលំបាកជារឿយៗ រៀនជាមួយនឹងគ្រូ ដែលត្រៀមរៀបចំខ្លួនតិចតួចជាងគ្រូ នៅតាមសាលារៀនដែលមានធនធានច្រើនជាង។ នៅក្នុងទសវត្សរ៍ចុងក្រោយនេះ រដ្ឋាភិបាលបានព្យាយាមដោះស្រាយបញ្ហាប្រឈមក្នុងការពង្រាយគ្រូតាមបែបផែនច្រើនយ៉ាង ដូចជា ការពង្រាយគ្រូពី ថ្នាក់ជាតិ



Credit: Poulomi Basu

ទៅការផ្ដល់ការលើកទឹកចិត្ត ដូចជា លំនៅដ្ឋាន អត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងការពន្លឿនការឡើងឋានៈ និងការជ្រើសរើសគ្រូនៅនឹងមូលដ្ឋានផ្ទាល់។

### *ការប្រើគ្រូជាប់កិច្ចសន្យាមានការកើនឡើង ប៉ុន្តែក៏បង្កព្រួយបារម្ភផងដែរ*

ដើម្បីឆ្លើយតបចំពោះតម្រូវការគ្រូបង្រៀនបន្ថែមទៀត ដែលកើតឡើងដោយសារតែការកើនឡើងនូវចំនួនសិស្សដែលចុះឈ្មោះចូលរៀន រដ្ឋាភិបាលនៅក្នុងប្រទេសកំពុងអភិវឌ្ឍមួយចំនួន បានជ្រើសរើសគ្រូជាប់កិច្ចសន្យាជាច្រើននាក់។ គិតត្រឹមចុងទសវត្សរ៍ ២០០០ ប្រទេសមួយចំនួននៅអាហ្វ្រិចសាប់សាហារ៉ា មានគ្រូជាប់កិច្ចសន្យាបណ្ដោះអាសន្ន ក្នុងចំនួនច្រើនឆ្ងាយជាងគ្រូពេញសិទ្ធិ។ គ្រូជាប់កិច្ចសន្យា ឋមានលក្ខខណ្ឌ ការងារ សន្តិសុខការងារ និងប្រៀវត្សរ៍ទាបជាងគ្រូពេញសិទ្ធិ។ បើធៀបជាមួយនឹងគ្រូរដ្ឋ មានគ្រូជាប់កិច្ចសន្យាច្រើននាក់ជាង ដែលមិនបានទទួលការបណ្ដុះបណ្ដាល ឬបានទទួលការបណ្ដុះបណ្ដាលតិចជាង ១ ខែ។ តើគ្រូជាប់កិច្ចសន្យាអាចធ្វើការងារប្រកបដោយប្រសិទ្ធភាពដូចជាគ្រូរដ្ឋដែរ ឬទេ? នៅក្នុងប្រទេសនីហ្សេ និងតូហ្គោ គ្រូជាប់កិច្ចសន្យាមានផលប៉ះពាល់ជាអវិជ្ជមាន ឬផលប៉ះពាល់ចម្រុះលើលទ្ធផលនៃការសិក្សានៅក្នុង មុខវិជ្ជាភាសាបារាំង និងគណិតវិទ្យារបស់សិស្សរៀនថ្នាក់ទី៥បើទោះបីជានៅក្នុងប្រទេសម៉ាលី លទ្ធផលដែលទទួលបានពីគ្រូជាប់កិច្ចសន្យាមានភាពវិជ្ជមានក៏ដោយ។ គ្រូជាប់កិច្ចសន្យា ច្រើនតែធ្វើការងារមានប្រសិទ្ធភាពបំផុត នៅពេលដែលមានការចូលរួមខ្ពស់ពីមាតាបិតា ឬសហគមន៍។

### ជោគជ័យនៃការបង្រៀន និងរៀន មានទំនាក់ទំនងជាមួយនឹងធនធានដែលមាន

មានកត្តាចំនួន ៣ ដែលគាំទ្រឱ្យការបង្រៀន និងរៀនមានគុណភាពល្អ ៖ ការផ្គត់ផ្គង់ ការចែកចាយ និងការប្រើប្រាស់ឯកសាររៀន, ការមានបរិស្ថានរូបវន្ត ដែលមានសុវត្ថិភាព និងងាយស្រួលចេញចូល ដោយមានសម្ភារូបវន្តសមស្រប និងពេលវេលា ដែលចំណាយនៅក្នុងថ្នាក់រៀន។

### *ការពង្រីកការប្រើប្រាស់ឯកសារបង្រៀន និងរៀនឱ្យបានសមស្រប*

តួនាទីសំខាន់នៃសៀវភៅសិក្សា នៅក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស មានឥទ្ធិពលលើគោលនយោបាយអប់រំ។ ចំណុចនេះ ត្រូវបានបញ្ជាក់ដោយភស្តុតាងកាន់តែច្រើនឡើងៗ។ ប្រព័ន្ធលទ្ធកម្ម និងបែងចែកសៀវភៅសិក្សាបែបមជ្ឈការ ត្រូវបានជំនួស ដោយភាពជាដៃគូវិស័យសាធារណៈ និងឯកជន។ សហគមន៍អន្តរជាតិបំពេញតួនាទីយ៉ាងសំខាន់ នៅក្នុងការផ្ដល់ការគាំទ្រដល់ការអភិវឌ្ឍ និងការចែកចាយ សៀវភៅសិក្សា នៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើន។ ការធ្វើបច្ចុប្បន្នកម្មសៀវភៅសិក្សា មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យសៀវភៅសិក្សា ស្របតាមការអភិវឌ្ឍចុងក្រោយ នៅក្នុងវិស័យអប់រំ និងតាមមុខវិជ្ជា។

**ស្ទើរតែពុំមានភស្តុតាងដែលបង្ហាញថាសាលារៀនឯកជនបង្កើនគុណភាពនៃការអប់រំឡើយ**

### *ការលើកកម្ពស់បរិយាកាសសាលាកុមារមេត្រី*

កុមារជាច្រើននាក់ ទៅសាលារៀន ដែលពុំមានបរិយាកាសអំណោយផលដល់ការរៀនសូត្រ ដូចជា ការខ្វះទឹកស្អាត កន្លែងលាងសំអាតដៃ និងបង្គន់ដែលស្អាត និងមានសុវត្ថិភាព។ កុមារក៏អាចប្រឈមនឹងការរើសអើង ការបៀតបៀន និងអាចដល់អំពើហិង្សាផងដែរ។ នៅក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះ ប្រទេសជាច្រើនបានប្រើប្រាស់គំរូសាលាកុមារមេត្រី ប៉ុន្តែការវាយតម្លៃលើសាលាកុមារមេត្រី នៅក្នុងប្រទេសហ្គូយ៉ាណា នីការ៉ាហ្គ័រ នីហ្សេរីយ៉ា ហ្វីលីពីន អាហ្វ្រិចខាងត្បូង និងថៃ បានបង្ហាញពីការបញ្ហាប្រឈម ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព។ ហេដ្ឋារចនាសម្ព័ន្ធសាលារៀនមិនល្អ កង្វះការជួសជុលថែទាំ និងកង្វះការបណ្ដុះ

បណ្តាលសមស្រប សម្រាប់នាយកសាលា និងគ្រូ គឺជាបញ្ហាសំខាន់ៗដែលបានកើតឡើង។

### *ធ្វើឱ្យគ្រប់នាទីទាំងក្នុងសាលារៀនមានប្រយោជន៍*

ការបង្កើនចំនួនម៉ោងបង្រៀន ត្រូវបានរកឃើញថាបានបង្កើនលទ្ធភាពទទួលបានចំណេះដឹងរបស់អ្នករៀនសូត្រ និងនាំឱ្យមានការទទួល បានលទ្ធផលរៀនសូត្រយ៉ាងច្រើន។ ទីភ្នាក់ងារអន្តរជាតិនានាបានផ្តល់អនុសាសន៍ឱ្យសាលាបឋមសិក្សាដំណើរការចន្លោះពី ៨៥០ ទៅ ១០០០ ម៉ោងក្នុងមួយឆ្នាំ ប៉ុន្តែចំនួនម៉ោងសរុប ដែលត្រូវបានបែងចែកសម្រាប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅទូទាំងសកលលោក មានការថយចុះតិចតួច នៅក្នុងទសវត្សរ៍ចុងក្រោយនេះ មកនៅក្រោម ១០០០ ម៉ោង។ នៅតាមប្រទេសជាច្រើន ជាពិសេស ក្នុងសហគមន៍ក្រីក្រ ចំនួនថ្ងៃក្នុងសាលារៀនត្រូវបាត់បង់ ដោយសារតែអវត្តមានគ្រូ ការពង្រាយគ្រូយឺតយ៉ាវ វិក្រឹតការ កូដកម្ម និងជម្លោះប្រដាប់អាវុធ។

### ដំណើរការបង្រៀន និងរៀនមានសារៈសំខាន់យ៉ាងខ្លាំង

ទិដ្ឋភាពចំនួន ៤ នៃការបង្រៀន និងរៀន ជាកត្តារួមចំណែកធ្វើឱ្យការអប់រំមួយមានគុណភាពល្អ ៖ កម្មវិធីសិក្សាដែលពាក់ព័ន្ធ និងរួមបញ្ចូល, វិធីសាស្ត្រគរុកោសល្យប្រកបដោយប្រសិទ្ធភាព និងសមស្រប, ការប្រើប្រាស់ភាសាកំណើតរបស់កុមារ និងការប្រើប្រាស់បច្ចេកវិទ្យា សមស្រប។

### *ការអភិវឌ្ឍកម្មវិធីសិក្សាដែលពាក់ព័ន្ធ*

កំណើនសម្ពាធ ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ច នាំឱ្យរដ្ឋាភិបាលធ្វើកំណែទម្រង់កម្មវិធីសិក្សារបស់ខ្លួនស្រដៀងៗគ្នា ដោយជារឿយៗ មិនសូវបានផ្តោតលើចំណេះដឹងខ្លឹមសារឡើយ ប៉ុន្តែផ្តោតខ្លាំងលើសមត្ថភាព។ កន្លងមក មានការជម្រុញ ដើម្បីធ្វើឱ្យខ្លឹមសារកាន់តែឆ្លើយតបទៅតម្រូវការបច្ចុប្បន្នរបស់បុគ្គល សហគមន៍ និងសង្គម។ ប៉ុន្តែ នៅក្នុងករណីមួយចំនួន គ្រូមិនបានចូលរួមពាក់ព័ន្ធនឹងការរៀបចំកម្មវិធីសិក្សា ដែលធ្វើឡើងក្នុងដំណើរការពីលើចុះក្រោមឡើយ។ ដូច្នេះ គ្រូមិនមានការយល់ដឹងឱ្យបានគ្រប់គ្រាន់ពីបំណងរបស់កំណែទម្រង់ ហើយកំណែទម្រង់នេះទៀតសោត ពុំបានឆ្លុះបញ្ចាំងឱ្យបានគ្រប់គ្រាន់អំពីស្ថានភាពជាក់ស្តែង នៅក្នុងថ្នាក់រៀនឡើយ។

### *ការប្រើប្រាស់យុទ្ធសាស្ត្របង្រៀនដែលមានប្រសិទ្ធភាព*

នៅក្នុងទសវត្សរ៍ចុងក្រោយនេះ មានការងាកចេញពីការបង្រៀនបែបគ្រូមជ្ឈមណ្ឌល ទៅជាការប្រើប្រាស់គរុកោសល្យបែបសិស្សមជ្ឈមណ្ឌល។ ប៉ុន្តែ ការអនុវត្តអាចជួបប្រទះនឹងការលំបាក។ ការលំបាកទាំងនេះ រួមមាន កង្វះបរិយាកាសគាំទ្រឱ្យបានគ្រប់គ្រាន់ ការបណ្តុះបណ្តាល និងការត្រៀមរៀបចំគ្រូបង្រៀន សៀវភៅសិក្សា និងឯកសាបង្រៀន និងទំហំថ្នាក់ធំពេក។ ប្រសិនបើពុំមានការគាំទ្រប្រកបដោយនិរន្តរភាព និងមានលក្ខណៈស៊ីសង្វាក់គ្នានោះទេ គ្រូច្រើនតែបង្រៀន តាមរបៀបដែលពួកគេទទួលបានការបង្រៀនដែរ។ ប៉ុន្តែ តាមរយៈការកែសម្រួលយុទ្ធសាស្ត្របង្រៀនថ្មីៗ ឱ្យស្របតាមបរិបទមូលដ្ឋាន គ្រូអាចបង្កើតនូវបរិយាកាសសិស្សមជ្ឈមណ្ឌល សូម្បីតែនៅក្នុងកាលៈទេសៈមិនសមប្រកបក៏ដោយ។

### *ការងាកទៅរកគោលនយោបាយអប់រំពហុភាសា*

ភាសាបង្រៀន និងភាសាដែលត្រូវបានបង្រៀន ក្នុងសាលារៀន មានសារៈសំខាន់យ៉ាងធំធេង ចំពោះគុណភាពនៃការបង្រៀន និងរៀន។ នៅអាហ្វ្រិចសាប់សាហារ៉ា និងប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ មាននិន្នាការជាទូទៅទៅរកការប្រើប្រាស់ភាសាក្នុងមូលដ្ឋាន ឱ្យបានកាន់តែទូលំទូលាយជាងមុន។ នៅអាមេរិចឡាទីន ប្រទេសភាគច្រើនមានគោលនយោបាយអប់រំពីរភាសាអន្តរវប្បធម៌។ តែទោះជាយ៉ាងណាក៏ដោយ មាតាបិតា និងអ្នកអប់រំ ជារឿយៗគិតថា ភាសាមូលដ្ឋាន មិនបានផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់បន្តការសិក្សា និងការរកការងារបានធ្វើនោះទេ។

### *ការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីគាំទ្រដល់ការរៀនសូត្រ*

បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) មានសក្តានុពលលើកកម្ពស់ការបង្រៀន និងរៀន ប៉ុន្តែការសិក្សាបានបង្ហាញយ៉ាងច្បាស់ អំពីឥទ្ធិពលរបស់វា។ ការដាក់បញ្ចូល ICT ទៅក្នុងប្រព័ន្ធអប់រំ គឺមានលក្ខណៈស្មុគស្មាញ។ ប្រទេសជាច្រើន មិនអាចគាំទ្រដល់ការរៀនសូត្រ ដោយប្រើ

ប្រាស់កុំព្យូទ័រដោជំនួយ ឱ្យបានទូលំទូលាយណាស់ ដោយសារតែសាលារៀនពុំមានអ៊ីនធឺណិត ឬអគ្គិសនី សម្រាប់ប្រើប្រាស់។ ប្រសិទ្ធភាពនៃ ICT ក៏អាស្រ័យទៅតាមគ្រូដែលបានទទួលការបណ្តុះបណ្តាលផងដែរ។ គេអាចនិយាយបានថា ទូរស័ព្ទដៃមានសក្តានុពលយ៉ាងធំធេង ក្នុងការសម្រួលឱ្យមានការរៀនសូត្រ ដោយប្រើប្រាស់ ICT ជាគោលដោយសារតែទូរស័ព្ទដៃ មិនត្រូវការហេដ្ឋារចនាសម្ព័ន្ធ ក្នុងកម្រិតដូច គ្នានឹងកុំព្យូទ័រឡើយ ហើយបណ្តាញទូរស័ព្ទក៏មានទូលំទូលាយជាង និងឧបករណ៍ជាច្រើនអាចប្រើប្រាស់អ៊ីនធឺណិត និងវីដេអូបាន។

## វិមជ្ឈការនៃអភិបាលកិច្ចលើការងារអប់រំ

ការធ្វើប្រតិភូកម្មអំណាច ក្នុងការធ្វើសេចក្តីសម្រេចចិត្តដល់សាលារៀន ផ្តល់ការទទួលខុសត្រូវកាន់តែច្រើនជាងមុនដល់នាយកសាលា គ្រូ និងមាតាបិតាសិស្ស។ វិមជ្ឈការនៅក្នុងវិស័យអប់រំ មានគោលបំណងបង្កើនគុណភាព តាមរយៈការពង្រឹងគណនេយ្យភាពរវាងសាលារៀន និងសហគមន៍មូលដ្ឋាន។ នៅក្នុងការអនុវត្តជាក់ស្តែង ការអនុវត្តយុទ្ធសាស្រ្តវិមជ្ឈការមិនបានធ្វើឡើងដូចៗគ្នាឡើយ។ លទ្ធផលនៃការអនុវត្តយុទ្ធសាស្រ្តទាំងនេះ ពឹងអាស្រ័យលើកត្តានៅ មូលដ្ឋានដូចជា ការបែងចែកធនធានហិរញ្ញវត្ថុ ធនធានមនុស្សភាពជាអ្នកដឹកនាំរឹងមាំនៅតាមសាលារៀន ការចូលរួមរបស់មាតាបិតា និងការគាំទ្រពីមន្ត្រីរដ្ឋាភិបាល។

## ភាពពាក់ព័ន្ធនៃការផ្តល់សេវាអប់រំឯកជន ចំពោះគុណភាពនៃការអប់រំ

ការបង្រៀនក្នុងសាលាឯកជន មានការកើនឡើងខ្លាំងចាប់តាំងពីឆ្នាំ ២០០០ មក។ ជារឿយៗ សិស្សដែលរៀននៅតាមសាលាឯកជន ជារឿយៗ ធ្វើបានល្អជាងសិស្សនៅសាលារដ្ឋ នៅក្នុងការវាយតម្លៃលើការរៀនសូត្រ ប្រហែលជាដោយសារតែសិស្ស ដែលមកពីគ្រួសារមានជីវភាពគ្រាន់បើ ច្រើនតែចូលរៀននៅសាលាឯកជន។ សិស្ស ដែលមានជីវភាពធូរធា និងមានសមត្ថភាពខ្ពស់ និងសាលារៀនដែលមានបណ្តាញ ច្រើនទទួលបានប្រយោជន៍ខ្ពស់បំផុត ខណៈពេលដែលសាលារដ្ឋច្រើនជាកន្លែងផ្តល់សេវាដល់ក្រុមសិស្សដែលជួបការលំបាក។ ស្ទើរតែពុំមានភស្តុតាងដែលបង្ហាញថា សាលារៀនឯកជនអនុវត្តវិធីសាស្រ្តបែបច្នៃប្រឌិតថ្មី ដើម្បីបង្កើនគុណភាពនៃការអប់រំឡើយ។ តាមពិតទៅ សាលារដ្ឋមានឱកាសច្រើន ដើម្បីកែច្នៃកម្មវិធីសិក្សារបស់ខ្លួនឱ្យបានកាន់តែប្រសើរជាងមុន ខណៈពេលដែលសាលារៀនឯកជនត្រូវតែឆ្លើយតបចំពោះ តម្រូវការរបស់មាតាបិតា ដែលចង់ឱ្យកូនទទួលបានលទ្ធផលល្អនៅក្នុងការប្រឡង។

# ប័ណ្ណរាយការណ៍ ២០០០-២០១៥

## ហិរញ្ញវត្ថុ

កៀងគរការប្តេជ្ញាចិត្តនយោបាយនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិឱ្យបានរឹងមាំ ដើម្បីការអប់រំសម្រាប់ទាំងអស់គ្នា, រៀបចំផែនការសកម្មភាពជាតិ និងបង្កើនការវិនិយោគឱ្យបានច្រើនលើវិស័យអប់រំថ្នាក់មូលដ្ឋាន

### ពិន្ទុសកល *

*ក្នុងចំណោមប្រទេសដែលមានទិន្នន័យ

នៅក្នុងឆ្នាំ ១៩៩៩ ក្នុងចំណោម ១១៦ ប្រទេស ដែលមានទិន្នន័យ ១៨ ប្រទេស ចំណាយចាប់ពី ៦% ឡើងទៅនៃ GNP របស់ខ្លួនលើវិស័យអប់រំ

នៅក្នុងឆ្នាំ ២០១២ ក្នុងចំណោម ១៤២ ប្រទេស ដែលមាន ទិន្នន័យ ៣៩ ប្រទេស ចំណាយចាប់ពី ៦% ឡើងទៅនៃ GNP របស់ ខ្លួនលើវិស័យអប់រំ

### ជោគជ័យ

**ការបង្កើនចំណាយលើវិស័យអប់រំ**

ពីសំណាក់រដ្ឋាភិបាលជាច្រើន ជាពិសេស នៅក្នុងប្រទេសក្រីក្រ (ដូចជា ប្រេស៊ីល អេត្យូពី នេប៉ាល់)

**ការចូលរួមយ៉ាងរឹងមាំរបស់ សង្គមស៊ីវិល នាំឱ្យសម្រេចបាន នូវជោគជ័យ**

ឧ. ការបង្កើនប្រសិទ្ធភាពនៃការ ចែកចាយសៀវភៅសិក្សា នៅ ក្នុងប្រទេសហ្វីលីពីននាំឱ្យមានការសន្សំប្រាក់ចំនួន ១,៨៤ លានដុល្លារ

**ការផ្តល់អាទិភាពលើចំណាយសម្រាប់ការអប់រំ**

ប្រទេសចំនួន ៦៤% បានសម្រេចគោលដៅនេះ រួមជាមួយ នឹងកំណើនសេដ្ឋកិច្ចក្នុងកម្រិត រឹងមាំ

$

### កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើង

**តម្លាភាព និងគណនេយ្យភាព**

អង្គការសង្គមស៊ីវិលបានជួយគូសបញ្ជាក់ពីសារៈសំខាន់នៃតម្លាភាព និងគណនេយ្យភាព

**ការបង្កើនចំណាយ**

នៅក្នុងប្រទេសចំនួន ៣៨ ចាប់ពី ១% ឡើង ទៅនៃចំណូលជាតិ របស់ខ្លួន (១៩៩៩-២០១២)

by 1%

**ការកាត់បន្ថយគម្លាតនៃចំណាយ**

ក្នុងសិស្សម្នាក់ រវាងការអប់រំ កម្រិតបឋមសិក្សា និងឧត្តមសិក្សា ត្រូវបានធ្វើឡើង នៅក្នុង ប្រទេសចំនួន ៣០

បឋមសិក្សា | ឧត្តមសិក្សា — 1999

បឋមសិក្សា | ឧត្តមសិក្សា — 2012

### បញ្ហាប្រឈមដែលនៅបន្តមាន

**ចំណាយលើឯកសាររៀន**

នៅក្នុងប្រទេសចំនួន ១២ នៅអាហ្វ្រិច ឯកសាររៀន និងបង្រៀនស្រូបយក ៥៦% នៃចំណាយរបស់គ្រួសារ

**ការផ្តល់មូលនិធិរបស់រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ**

EFA goals 1 2 3 4 5 6

ក្រៅតែពីការចំណាយលើការអប់រំកម្រិតបឋមសិក្សា ចំណាយមួយភាគធំធ្វើឡើងលើ សកម្មភាពអប់រំ ដែលមិនពាក់ព័ន្ធជាមួយនឹងការអប់រំសម្រាប់ទាំងអស់គ្នា

**សកម្មភាពមនុស្សធម៌ នៅក្នុងឆ្នាំ**

ក្នុងចំណោមមូលនិធិ សរុបសម្រាប់សកម្មភាព មនុស្សធម៌ មានតែ ២% ប៉ុណ្ណោះ ដែលចំណាយសម្រាប់ការអប់រំ

### វិឌ្ឍនភាពមិនស្មើគ្នា

**ការបែងចែកធនធាន**

ចាំបាច់ត្រូវតែមានសមធម៌ និងប្រសិទ្ធភាពជាងមុន

**ការផ្តល់ជំនួយឱ្យបានកាន់តែមានប្រសិទ្ធភាពជាងមុន**

**ការផ្តល់ហិរញ្ញប្បទានដែលមិនធ្លាប់មានកន្លងមក**

សម្រាប់ការងារអប់រំ ដែលមិន ទទួលបានធនធានគ្រប់គ្រាន់ (ឧ. ការវិនិយោគឯកជន ការគាំទ្រពីក្រុមហ៊ុនឯកជន ។ល។)

### អនុសាសន៍ សម្រាប់ក្រោយឆ្នាំ ២០១៥

១. ការអប់រំ ដែលមិនសូវទទួលបានការយកចិត្តទុកដាក់ ដូចជា ការអប់រំកម្រិតមត្តេយ្យសិក្សា ការអប់រំឱកាសទី ២ អក្ខរកម្មមនុស្សពេញវ័យ ត្រូវតែជាអាទិភាពរបស់រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ

២. ចាំបាច់ត្រូវមានឧបករណ៍វិភាគល្អជាងមុន ដើម្បីស្វែងយល់ពីរបៀបដែលចំណាយត្រូវបានធ្វើឡើង

ចាំបាច់ត្រូវមានការប្តេជ្ញាចិត្តបន្ថែមទៀត

# ជំពូក ៨ ហិរញ្ញវត្ថុ

*កៀងគរការប្តេជ្ញាចិត្តនយោបាយនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិឱ្យបានរឹងមាំ ដើម្បីការអប់រំសម្រាប់ទាំងអស់គ្នា, រៀបចំផែនការសកម្មភាពជាតិ និងបង្កើនការវិនិយោគឱ្យបានច្រើនលើវិស័យអប់រំថ្នាក់មូលដ្ឋាន*

ក្របខ័ណ្ឌសកម្មភាពដាកា អំពាវនាវឱ្យមានការបង្កើនឱ្យបានច្រើននូវការប្តេជ្ញាចិត្តខាងហិរញ្ញវត្ថុ ពីរដ្ឋាភិបាលថ្នាក់ជាតិ និងពីអ្នកផ្តល់ជំនួយ ដើម្បីពន្លឿនវឌ្ឍនភាព ក្នុងការឈានទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា។ ក្របខ័ណ្ឌសកម្មភាពនេះលើកទឹកចិត្តអ្នកផ្តល់ជំនួយឱ្យផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការបង្កើនជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋាន និងផ្តល់ការគាំទ្រនេះឱ្យមានប្រសិទ្ធភាព តាមដែលអាចធ្វើបាន។ ក្របខ័ណ្ឌសកម្មភាពនេះក៏អំពាវនាវឱ្យប្រទេសនានាបង្កើនគណនេយ្យភាពរបស់ខ្លួន ចំពោះប្រជាពលរដ្ឋផងដែរ។

ការសន្យា ដែលធ្វើឡើងនៅទីក្រុងដាកា ដែលថា ពុំមានប្រទេសណាមួយគួរជួបប្រទះការរាំងស្ទះ នៅក្នុងការសម្រេចគោលដៅអប់រំ សម្រាប់ទាំងអស់គ្នា ដោយសារតែកង្វះធនធាន គឺជាបរាជ័យមួយ ក្នុងចំណោមបរាជ័យធំៗជាងគេនៅក្នុងរយៈពេលនៃការអប់រំសម្រាប់ទាំងអស់គ្នានេះ។ អ្នកផ្តល់ជំនួយខកខានមិនបានធ្វើទៅតាមអ្វី ដែលពួកគេសន្យានោះឡើយ។ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនៃប្រទេសចំណូលទាបជាច្រើន ក្នុងការបែងចែកអាទិភាពឡើងវិញនៃថវិកាអប់រំ ដល់ការអប់រំកម្រិតបឋមសិក្សា គួរជាអ្វីដែលសមនឹងទទួលបានការកោតសរសើរ ប៉ុន្តែចាំបាច់ត្រូវមានថវិកាឱ្យបានច្រើនផ្សេងទៀត ដើម្បីផ្តល់អាទិភាពដល់ចំណាយសម្រាប់វិស័យអប់រំទាំងមូល។ ការគាំទ្រពីរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ សម្រាប់គោលដៅអប់រំសម្រាប់ទាំងអស់គ្នាផ្សេងទៀត មានតិចតួច ហើយវឌ្ឍនភាពក្នុងការឈានទៅសម្រេចគោលដៅទាំងនោះ នៅមានកម្រិតខ្សោយនៅឡើយ។

## ការផ្លាស់ប្តូរការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុរបស់ជាតិ ចំពោះការអប់រំសម្រាប់ទាំងអស់គ្នា ចាប់តាំងពីមានក្របខ័ណ្ឌដាកាមក

ក្របខ័ណ្ឌដាកា មានបំណងចង់ឱ្យរដ្ឋាភិបាលថ្នាក់ជាតិផ្តល់ហិរញ្ញប្បទានឱ្យបានច្រើនលើការអប់រំសម្រាប់ទាំងអស់គ្នា។ ការរំពឹងទុកនេះ ត្រូវបានបំពេញ សូម្បីតែនៅក្នុងតំបន់ដែលពឹងអាស្រ័យលើជំនួយពីខាងក្រៅ ៖ ចំណាយសាធារណៈក្នុងស្រុក មានច្រើនជាងជំនួយពីខាងក្រៅ។

នៅក្នុងឆ្នាំ ២០០៦ ក្រុមការងារកម្រិតខ្ពស់ខាងការអប់រំសម្រាប់ទាំងអស់គ្នា បានលើកស្នើថា រដ្ឋាភិបាលគួរចំណាយចន្លោះពី ៤% ទៅ ៦% នៃផលិតផលជាតិសរុប (GNP) លើការអប់រំ និងដោយឡែក ក្នុងក្របខ័ណ្ឌថវិការដ្ឋាភិបាលវិញ ថវិកាចន្លោះពី ១៥% ទៅ ២០% គួរវិភាជន៍សម្រាប់វិស័យអប់រំ។

**នៅក្នុងឆ្នាំ២០១២ ថវិកាដែលវិភាជន៍សម្រាប់វិស័យអប់រំគិតជាភាគរយនៃ GNP មានកម្រិត ៥%**

វឌ្ឍនភាព នៅក្នុងការដាក់អាទិភាពលើវិស័យអប់រំមានភាពចម្រុះ។ នៅក្នុងសកលលោកទាំងមូលថវិកាដែលវិភាជន៍សម្រាប់វិស័យអប់រំ គិតជាភាគរយនៃ GNP មាន ៥% នៅក្នុងឆ្នាំ ២០១២។ សម្រាប់ប្រទេសដែលមានចំណូលទាប កម្រិតថវិកាជាមធ្យមមាន ៤%។ ក្នុងចំណោម ១៤២ ប្រទេស ដែលមានទិន្នន័យ មានប្រទេសចំនួន ៩៦ ចំណាយចាប់ពី ៤% ឡើងទៅនៃ GNP លើវិស័យអប់រំ (ក្នុងនោះមាន ប្រទេសចំណូលទាបចំនួន ១៤

និងប្រទេសចំណូលមធ្យមកម្រិតទាបចំនួន ១៨) ហើយក្នុងចំណោមប្រទេសទាំង ៩៦ នេះ មានប្រទេសចំនួន ៣៩ ចំណាយថវិកាចាប់ពី ៦% ឡើងទៅលើវិស័យអប់រំ។

### ចំណាយលើវិស័យអប់រំ មិនបានតាមទាន់កំណើនសេដ្ឋកិច្ច និងកំណើននៃការចុះឈ្មោះចូលរៀនជានិច្ចនោះទេ

កំណើនសេដ្ឋកិច្ច នៅក្នុងរយៈពេលពីឆ្នាំ ១៩៩៩ ដល់ ២០១២ កើតឡើងអមជាមួយនឹងកំណើនពិតប្រាកដនៃចំណាយសាធារណៈលើការអប់រំ។ កំណើនសេដ្ឋកិច្ចនៅអាហ្វ្រិចសាប់សាហារ៉ា ដែលជាមធ្យមមានកម្រិត ៤,០% មានល្បឿនយឺតជាងកំណើនចំណាយសាធារណៈលើការអប់រំ ដែលជាមធ្យមមានកម្រិត ៦,១% នៅក្នុងមួយឆ្នាំ។ ផ្ទុយទៅវិញ អាស៊ីខាងត្បូង និងខាងលិច មានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ចន្លោះ ពីឆ្នាំ ១៩៩៩ ដល់ ២០១២ ជាមធ្យម ៤,៥% ខណៈពេលដែលចំណាយសាធារណៈលើវិស័យអប់រំមានកម្រិតខ្ពស់ជាងនេះតិចតួច ពោលគឺ ៤,៩% ក្នុងមួយឆ្នាំ។

នៅក្នុងឆ្នាំ ២០១២ ប្រទេសដែលមានចំណូលទាបចំណាយលើសិស្សកម្រិតឧត្តមសិក្សា១១ ដងច្រើនជាងសិស្សបឋមសិក្សា

### នៅក្នុងថវិកាជាតិរបស់ប្រទេសជាច្រើន វិស័យអប់រំមិនមែនជាអាទិភាពនោះទេ

បើគិតជាភាគរយនៃចំណាយរបស់រដ្ឋាភិបាល ចំណាយសម្រាប់វិស័យអប់រំ មានការប្រែប្រួលតិចតួច ចាប់តាំងពីឆ្នាំ ១៩៩៩ មក។ នៅក្នុងឆ្នាំ ២០១២ អត្រាជាមធ្យមសម្រាប់ពិភពលោកទាំងមូលគឺ ១៣,៧% ពោលគឺទាបជាងចំណុចដៅ ដែលកំណត់ពី ១៥% ដល់ ២០%។ អាហ្វ្រិចសាប់សាហារ៉ា គឺជាតំបន់ ដែលមានប្រទេសវិភាជន៍ចំណាយរបស់រដ្ឋាភិបាល ក្នុងកម្រិតច្រើនបំផុត លើវិស័យអប់រំ (១៨,៤%) បន្ទាប់មក អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច (១៧,៥%)។ អាស៊ីខាងត្បូង និងខាងលិច វិភាជន៍ ១២,៦%។

### ថវិកាអប់រំដែលវិភាជន៍សម្រាប់ការអប់រំកម្រិតមត្តេយ្យសិក្សា មានកម្រិតទាប

បើគិតជាភាគរយនៃចំណាយសាធារណៈសរុបរបស់រដ្ឋាភិបាលលើវិស័យអប់រំ ចំណាយសរុបលើការអប់រំកម្រិតមត្តេយ្យសិក្សា មានប្រមាណជា ៤,៩% នៅក្នុងឆ្នាំ ២០១២។ អាមេរិចខាងជើង និងអឺរ៉ុបខាងលិច វិភាជន៍ថវិកាប្រមាណជា ៨,៨% នៃថវិកាអប់រំ លើការអប់រំកម្រិតមត្តេយ្យសិក្សា ខណៈពេលដែលអាហ្វ្រិចសាប់សាហារ៉ា ចំណាយ ០,៣%។

### និន្នាការនៃការផ្តល់ហិរញ្ញប្បទានដល់ការអប់រំបឋមសិក្សាមានការប្រែប្រួលខុសគ្នាឆ្ងាយ

ចំណុចដៅអប់រំ នៃការអប់រំសម្រាប់ទាំងអស់គ្នា និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ គូសបញ្ជាក់ពីភាពចាំបាច់ដើម្បីពង្រីកការអប់រំកម្រិតបឋមសិក្សា ដែលមានគុណភាពដោយមិនគិតថ្លៃ ដោយធ្វើការពង្រីកការវិនិយោគលើការអប់រំកម្រិតបឋមសិក្សា និងផ្តល់អាទិភាពដល់ ថវិកាសម្រាប់ការអប់រំបឋមសិក្សា។ បើទោះបីជាមានការគូសបញ្ជាក់បែបនេះក៏ដោយ ក្នុងចំណោម ៥៦ ប្រទេសដែលមានទិន្នន័យអំពីភាគរយ នៃចំណាយក្នុងស្រុករបស់រដ្ឋាភិបាលលើការអប់រំកម្រិតបឋមសិក្សា នៅក្នុងឆ្នាំ ១៩៩៩ និង ២០១២ មានប្រទេសត្រឹមតែ ១៦ ប៉ុណ្ណោះ ដែលបានបង្កើនភាគរយនេះ។

### នៅក្នុងប្រទេសក្រីក្រជាច្រើន បៀវត្សរ៍គ្រូស្រូវយកចំណែកធំជាងគេនៃថវិការបស់សាលាបឋមសិក្សា

បៀវត្សរ៍គ្រូ ជាមធ្យមមានចំណែក ៨២% នៃចំណាយចរន្តសរុប សម្រាប់ការអប់រំបឋមសិក្សា នៅក្នុងប្រទេសដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ នៅតាមប្រទេសដែលមានចំណូលខ្ពស់ ជាមធ្យម អត្រានេះមានកម្រិត ៦៤%។ សម្រាប់ប្រទេសជាច្រើន ភាគរយដ៏ខ្ពស់បែបនេះ ធ្វើឱ្យនៅសល់ធនធានតិចតួច សម្រាប់ការងារផ្សេងទៀត ដូចជា ការបំពេញទៅតាមគោលដៅខាងគុណភាព និងប្រសិទ្ធភាពជាដើម។ ការសិក្សា ដែលធ្វើឡើងនៅឆ្នាំ ២០០៨ សម្រាប់ធនាគារពិភពលោក និងក្របខ័ណ្ឌបណ្តោះអាសន្នឆ្នាំ ២០០៤ សម្រាប់គំនិតផ្តួចផ្តើមពន្លឿន ការសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា ផ្តល់ជាអនុសាសន៍ឱ្យមានការវិភាជន៍ចំណាយចរន្តសម្រាប់ការអប់រំកម្រិតបឋមសិក្សា ១ ភាគ ៣ សម្រាប់ចំណាយមិនមែនបៀវត្សរ៍។ នៅក្នុងឆ្នាំ ២០១២ នៅក្នុងប្រទេស ដែលមានចំណូលទាប និងចំណូលមធ្យមដែលមានទិន្នន័យចំនួន ៣៦ ប្រទេស ភាគរយនៃចំណាយ ចរន្តរបស់ការអប់រំកម្រិតបឋមសិក្សាដែលត្រូវបាន ចំណាយលើ

សៀវភៅសិក្សា និងសម្ភារបង្រៀន និងរៀន មានចំនួន ២%។ ប្រទេសចំនួន ១៦ ចំណាយតិចជាង ១%។ មានតែប្រទេសគុយវ៉ែត និងម៉ាឡាវីប៉ុណ្ណោះ ដែលចំណាយកៀកទៅនឹង ៥% ឬច្រើនជាងនេះ។

## *ប្រទេសភាគច្រើនបានបង្កើនចំណាយលើការអប់រំកម្រិតមធ្យមសិក្សា*

សិស្សក្នុងចំនួនដ៏ច្រើន ដែលឆ្លងភូមិសិក្សានៅកម្រិតមធ្យមសិក្សា ទាមទារឱ្យមានការចំណាយធនធានបន្ថែមទៀត។ ក្នុងចំណោម ៦១ ប្រទេស ដែលមានទិន្នន័យអំពីការចំណាយសាធារណៈលើការអប់រំកម្រិតមធ្យមសិក្សា គិតជាភាគរយនៃចំណូលជាតិ នៅក្នុងឆ្នាំ ១៩៩៩ និង ២០១២ មានប្រទេសចំនួន ៣៨ បានបង្កើនចំណាយលើការអប់រំកម្រិតមធ្យមសិក្សា។ ក្នុងចំណោមប្រទេសទាំងនេះ មានប្រទេសចំនួន ១៥ គឺជា ប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមកម្រិតទាប។

## *អំពើពុករលួយបន្តជាឧបសគ្គ*

អំពើពុករលួយរបស់រដ្ឋាភិបាល ត្រូវបានរកឃើញថាមានផលប៉ះពាល់ជាអវិជ្ជមានមកលើសមភាពនៃសេវាសាធារណៈ រួមទាំងសេវា អប់រំផងដែរ។ ក្របខ័ណ្ឌដាកា ធ្វើការកត់សម្គាល់ថា "អំពើពុករលួយគឺជាឧបសគ្គធំមួយ ចំពោះការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព សម្រាប់សេវាអប់រំ ហើយគួរធ្វើការទប់ស្កាត់ជាបន្ទាន់"។ អង្គការសង្គមស៊ីវិលបានបំពេញតួនាទីយ៉ាងសំខាន់ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ បើទោះបីជាមានការចាត់វិធានការបែបនេះ នៅក្នុងទសវត្សរ៍កន្លងទៅក៏ដោយ អំពើពុករលួយក្នុងវិស័យអប់រំ នៅតែបន្តកើតមាន ហើយការខាតបង់ភាគច្រើន ត្រូវរ៉ាប់រងដោយប្រជាពលរដ្ឋក្រីក្រ ដែលជា

ជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋាននៅទ្រឹងនៅក្នុងឆ្នាំ ២០១០

**រូបភាពទី ១០ ៖ ជំនួយដើម្បីសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ក្រៅពីការអប់រំកម្រិតបឋមសិក្សា ពុំមានការកើនឡើងឡើយ**
ជំនួយសរុប ដែលត្រូវបានសន្យាថានឹងផ្តល់សម្រាប់ការអប់រំ ចំនួនមធ្យមសម្រាប់ ៣ ឆ្នាំរំកិល ១៩៩៥-២០១២




សម្គាល់ ៖ ទិន្នន័យមុនឆ្នាំ ២០០២ គឺជាទិន្នន័យបង្ហាញពីជំនួយដែលបានសន្យា ដោយសារតែមិនមានទិន្នន័យអំពីការផ្តល់ជំនួយ។ ដោយសារតែ ការឡើងចុះនូវបរិមាណជំនួយដែលបានសន្យា ក្រាហ្វនេះបង្ហាញតួលេខទាំងនេះគិតជាមធ្យមសម្រាប់ ៣ ឆ្នាំរំកិល។
*ប្រភព* ៖ OECD-DAC (២០១៤)

រឿយៗ មានជម្រើសតិចតួច នៅក្នុងការប្រើប្រាស់សេវាខាងក្រៅវិស័យសាធារណៈ។

### *សមធម៌ និងការយកចិត្តទុកដាក់ចំពោះមនុស្សគ្រប់រូបនៅក្នុងចំណាយអប់រំ*

ការគ្រាន់តែវិភាជន៍ធនធានក្នុងស្រុក បន្ថែមដល់វិស័យអប់រំ គឺមិនគ្រប់គ្រាន់នោះទេ។ ធនធានទាំងនេះត្រូវតែចំណាយឱ្យមានសមធម៌។ នេះតម្រូវឱ្យមានការផ្ដោតចំណាយសាធារណៈឱ្យចំក្រុម ដែលនៅឆ្ងាយបំផុតពីការបំពេញគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ដូចជា កុមារក្រីក្រជាងគេ កុមារពិការ និងកុមាររស់នៅតាមតំបន់ដាច់ស្រយាល និងកុមារមកពីជនជាតិភាគតិច។ ប៉ុន្តែ ប្រទេសជាច្រើនបន្តផ្ដល់ថវិកាក្នុងចំនួនស្មើគ្នា សម្រាប់កុមារម្នាក់ ដោយមិនបាន



Credit: Ami Vitale\Panos Pictures

ពិចារណាអំពីភាពខុសប្លែកគ្នារវាងសាលារៀន និងតំបន់ និងតម្រូវការរបស់ក្រុមដែលជួបការលំបាក។

សម្រាប់ប្រទេសចំណូលទាបភាគច្រើន ហេតុផលដែលគាំទ្រឱ្យមានចំណាយបន្ថែមលើការអប់រំកម្រិតបឋមសិក្សាមានកម្រិតខ្ពស់ ដោយហេតុថា នេះគឺជាកម្រិត ដែលកុមារមកពីគ្រួសារក្រីក្រ ទំនងជាអាចចូលរៀនបានច្រើនបំផុត។ ប៉ុន្តែជាមធ្យម នៅក្នុងឆ្នាំ ២០១២ ប្រទេសចំណូលទាបចំណាយលើសិស្សថ្នាក់ឧត្តមសិក្សាម្នាក់ ខ្ពស់ជាងលើសិស្សបឋមសិក្សាម្នាក់ ១១ ដង ខណៈពេលដែលប្រទេសចំណូលខ្ពស់ចំណាយតែ ១,៣ ដងច្រើនជាង។ នៅក្នុងប្រទេសដែលមានការរំពឹងទុកខ្ពស់ ថានឹងផ្តល់ការគាំទ្រដល់ប្រជាជនក្រីក្រ តាមរយៈចំណាយសាធារណៈ អត្ថប្រយោជន៍នៃការអប់រំ ជាពិសេស នៅកម្រិតដែលទទួលបានភាគច្រើនដោយអ្នកមាននៅតែបន្តទទួលបានដោយអ្នកមាន។

### *គ្រួសារជួយលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងអប់រំរបស់ជាតិ ជាពិសេស នៅពេលដែលចំណាយរបស់រដ្ឋាភិបាលមានកម្រិតតិចតួច*

បញ្ហា នៅក្នុងប្រទេសជាច្រើន មិនមែនរឿងចំណាយរបស់ជាតិលើការអប់រំពុំមានកម្រិតគ្រប់គ្រាន់នោះទេ ប៉ុន្តែជាបញ្ហាដែលថា ចំណាយធំៗត្រូវរ៉ាប់រងដោយប្រជាពលរដ្ឋដោយខ្លួនឯង។ ជាទូទៅ នៅពេលដែលប្រទេសមួយកាន់តែក្រ បន្ទុកចំណាយមកលើគ្រួសារមានកម្រិតកាន់តែខ្ពស់។ ក្នុងចំណោមប្រទេសដែលមានចំណូលទាប មធ្យម និងខ្ពស់ចំនួន៥០នៅក្នុងតំបន់ទាំងអស់ដែលមានទិន្នន័យនៅក្នុងឆ្នាំណាមួយ ក្នុងអំឡុងពីឆ្នាំ ២០០៥ ដល់ ២០១២ ចំណាយរបស់គ្រួសារលើការអប់រំ មានប្រមាណជា ៣១% នៃចំណាយសរុប។ ក្នុងចំណោម ២៥ ប្រទេស ដែលផ្តល់ហិរញ្ញប្បទានដល់វិស័យអប់រំក្នុងកម្រិតទាបបំផុត គ្រួសាររួមចំណែក ៤២% នៃចំណាយសរុប ខណៈពេលដែលនៅក្នុង ២៥ ប្រទេស ដែលផ្តល់ហិរញ្ញប្បទានក្នុងកម្រិតខ្ពស់បំផុត គ្រួសាររួមចំណែក ២៧%។

## ជំនួយអភិវឌ្ឍន៍អន្តរជាតិ

ក្រោយឆ្នាំ ២០០០ មានការរំពឹងទុកខ្ពស់ថា សហគមន៍អ្នកផ្តល់ជំនួយនឹងបង្កើនការគាំទ្រ ផ្នែកហិរញ្ញវត្ថុរបស់ខ្លួនដល់វិស័យអប់រំ ស្របតាមគោលបំណង ដែលត្រូវបានដាក់ចេញនៅក្នុងគោលដៅទាំង ៦ នៃការអប់រំសម្រាប់ទាំងអស់គ្នា។ ខណៈពេលដែលជំនួយសម្រាប់ការអប់រំ ថ្នាក់មូលដ្ឋានមានការកើនឡើងជាមធ្យម ៦% ក្នុងមួយឆ្នាំ ភាគរយនៃជំនួយសម្រាប់វិស័យអប់រំ ពុំមានការប្រែប្រួលឡើយ ពោលគឺមិនដែល លើសពី ១០% ឡើយ។ ផ្ទុយទៅវិញ ភាគរយនៃជំនួយសរុប សម្រាប់វិស័យសុខាភិបាល បានកើនឡើងពី ៩% ដល់ ១៤%។

ជំនួយសរុបសម្រាប់វិស័យអប់រំ មានការកើនឡើងបន្តិចម្តងៗ រហូតដល់ឆ្នាំ ២០១០ ប៉ុន្តែថយចុះចំនួន ១០% (ត្រឹមសរុប ១,៣ ពាន់ លានដុល្លារ) ចន្លោះពីឆ្នាំ ២០១០ ដល់ ២០១២។

នៅក្នុងឆ្នាំ ២០១៣ វិស័យអប់រំ បានទទួល ត្រឹមតែ ២% នៃជំនួយ មនុស្សធម៌ តែប៉ុណ្ណោះ

## ការបែងចែកជំនួយ ទៅតាមកម្រិតនៃការអប់រំ

ជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋាន ដែលពាក់ព័ន្ធជាមួយនឹងគោលដៅចំនួន ៥ ក្នុងចំណោមគោលដៅទាំង ៦ នៃការអប់រំសម្រាប់ទាំងអស់គ្នា មានការកើនឡើងដល់កម្រិតកំពូល នៅក្នុងឆ្នាំ ២០០៩ និង ២០១០។ បន្ទាប់មកចន្លោះពីឆ្នាំ ២០១០ និង ២០១២ ការផ្តល់ជំនួយមកដល់កម្រិតនេះ មានការថយចុះចំនួន ១៥% ឬ ៩២១ លានដុល្លារ។ ផ្ទុយទៅវិញ ជំនួយសម្រាប់ការអប់រំក្រោយមធ្យមសិក្សា មានការថយចុះ ៦%។ ជាក់ស្តែង នៅក្នុងឆ្នាំ ២០១២ ជំនួយសម្រាប់ការអប់រំក្រោយមធ្យមសិក្សា មានកម្រិតខ្ពស់ជាងជំនួយសម្រាប់ការអប់រំកម្រិតមូលដ្ឋាន។

ហិរញ្ញប្បទានពីខាងក្រៅសម្រាប់វិស័យអប់រំ ផ្តោតខ្លាំងលើការអប់រំនៅកម្រិតបឋមសិក្សា និងតិចតួចលើគោលដៅផ្សេងទៀតនៃការអប់រំសម្រាប់ទាំងអស់គ្នា។ បើគិតជាចំណែកនៃការផ្តល់ហិរញ្ញប្បទានសរុប ដល់ការអប់រំថ្នាក់មូលដ្ឋាន ជំនួយដែលផ្តល់សម្រាប់បំណិនជីវិតមូលដ្ឋានសម្រាប់យុវជន និងមនុស្សពេញវ័យ និងការអប់រំកុមារតូចមានការថយចុះ។ យុទ្ធសាស្ត្ររបស់អ្នកផ្តល់ជំនួយផ្តោតតិចតួចលើការ អប់រំមនុស្សពេញវ័យ ការរៀនសូត្រពីចំងាយ ការអប់រំក្រៅប្រព័ន្ធ ឬការអប់រំកុមារដែលមានតម្រូវការពិសេស។

## ការផ្តល់ជំនួយបែងចែកតាមតំបន់

ជំនួយដែលផ្តល់ដល់ការអប់រំថ្នាក់មូលដ្ឋាន នៅអាហ្វ្រិចសាប់សាហារ៉ា ដែលមានកុមារក្រៅសាលាជាងពាក់កណ្តាល

នៃចំនួនកុមារក្រៅ សាលាសរុបក្នុងពិភពលោក មានការថយចុះ ចាប់តាំងពីឆ្នាំ ២០០៩ មក។ នៅក្នុងឆ្នាំ ២០០២-២០០៤ ជាមធ្យម ជំនួយ ៤៧% នៃជំនួយសរុប ដែលផ្តល់ដល់ការអប់រំថ្នាក់មូលដ្ឋាន ត្រូវបានវិភាជន៍ទៅឱ្យប្រទេសនៅអាហ្វ្រិចសាប់សាហារ៉ា ប៉ុន្តែត្រឹមឆ្នាំ ២០១០-២០១២ កម្រិតនៃការវិភាជន៍មានការថយចុះមកនៅ ៣១%។ ភាគរយសម្រាប់ការអប់រំនៅថ្នាក់មូលដ្ឋាន នៅអាស៊ីខាងត្បូង និងអាស៊ីខាងលិច បន្តនៅថេរ ដោយមានការកើនឡើងពី ២១% ដល់ ២២% ប៉ុណ្ណោះ។

## ការផ្តល់ជំនួយ ដើម្បីបានទៅដល់អ្នកក្រ

ក្នុងពេលដែលកាលពីដើមទសវត្សរ៍ ១៩៩០ ប្រជាជនក្រីក្រ ៩៣% នៃប្រជាជនក្រីក្រសរុបក្នុងពិភពលោក រស់នៅក្នុងប្រទេសដែលមានចំណូលទាប ពួកគេ ៧២% រស់នៅក្នុងប្រទេសចំណូលមធ្យម នៅក្នុងឆ្នាំ ២០១២។ បច្ចុប្បន្ននេះ កុមារក្រៅសាលា ៥៩% ប្រមូលផ្តុំនៅក្នុងប្រទេសដែលមានចំណូលមធ្យម។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសដែលមានចំណូលទាប និងរដ្ឋបែកបាក់ ដែលត្រូវការជំនួយសម្រាប់សេវាមូលដ្ឋានច្រើនជាងគេ គួរតែនៅតែអាទិភាពដដែល។ ទោះជាយ៉ាងណាក៏ដោយ ភាគរយនៃជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋាន ដែលផ្តល់ដល់ប្រទេសចំណូលទាប មានការថយចុះពី ៤០% ដល់ ៣៤% នៅក្នុងទសវត្សរ៍នេះ។

## ការផ្លាស់ប្តូរស្ថានភាពជំនួយចាប់តាំងពីឆ្នាំ ២០០០ មក

ពីមុនមក អ្នកផ្តល់ជំនួយភាគច្រើន គឺបណ្តាប្រទេស OECD ប៉ុន្តែ ចាប់តាំងពីឆ្នាំ ២០០០ មក ប្រទេសដែលមានសេដ្ឋកិច្ចទើបរីកចម្រើន កំពុងបង្កើតជាផ្លូវការនូវយន្តការជាសកល សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដូចជា កម្មវិធី IBSA សម្រាប់កាត់បន្ថយភាពក្រីក្រ និងគ្រោះអត់ឃ្លាន ជាដើម ដែលបង្កើតឡើងនៅក្នុងឆ្នាំ ២០០៤ ដោយប្រទេសឥណ្ឌា ប្រេស៊ីល និងអាហ្វ្រិចខាងត្បូង និងធនាគារអភិវឌ្ឍន៍ថ្មី ដែលត្រូវបាន បង្កើតឡើងដោយប្រទេសប្រេស៊ីល ចិន ឥណ្ឌា រុស្ស៊ី និងអាហ្វ្រិចខាងត្បូង។

## *អ្នកផ្តល់ជំនួយមិនបានបំពេញទៅតាមការសន្យារបស់ខ្លួនក្នុងការផ្តល់ជំនួយអប់រំឱ្យបានកាន់តែមានប្រសិទ្ធភាពនោះឡើយ*

ចាប់តាំងពីមានក្របខ័ណ្ឌដាកាមក មានការប្តេជ្ញាចិត្តខាងនយោបាយខ្ពស់ជាងមុន ដើម្បីធ្វើការកែលំអ មិនត្រឹមតែបរិមាណប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអភិបាលកិច្ចលើជំនួយអន្តរជាតិទៀតផង។ សេចក្តីប្រកាសទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ នៅក្នុងឆ្នាំ ២០០៥ គឺជាការប្តេជ្ញាចិត្តមិនធ្លាប់មានកន្លងមក ដើម្បីធ្វើការផ្តល់ជំនួយកាន់តែលក្ខណៈល្អប្រសើរជាងមុន។ ក្នុងចំណោមចំណុចដៅទាំង ១៣ នៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ មានការសម្រេចបានតែចំណុចដៅអំពីការតម្រឹម និងការសម្របសម្រួលជំនួយបច្ចេកទេសតែប៉ុណ្ណោះ បើគិតត្រឹមឆ្នាំ ២០១០។

## កង្វះរចនាសម្ព័ន្ធជំនួយសកល បង្កជាឧបសគ្គដល់ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងចំណោមអ្នកផ្តល់ជំនួយ

ការសម្របសម្រួលនៅកម្រិតសកល នឹងផ្តល់លទ្ធភាពឱ្យអ្នកផ្តល់ជំនួយដល់វិស័យអប់រំ ធ្វើការវិភាជន៍ជំនួយទៅកន្លែងដែលមាន តម្រូវការខ្ពស់ជាងគេ។ ប៉ុន្តែ យន្តការសម្របសម្រួលនៅកម្រិតសកល និងកម្រិតប្រទេសបច្ចុប្បន្ន ហាក់បីដូចជាមិនបានជួយអ្វីច្រើនឡើយ។ វេទិកាកម្រិតខ្ពស់លើកទី ៤ ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅក្នុងទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ នៅក្នុងឆ្នាំ ២០១១ បានគូសបញ្ជាក់ពីការប្រើប្រាស់ស្ថាប័នពហុភាគី និងមូលនិធិសកល ដើម្បីកែលំអការសម្របសម្រួល ប៉ុន្តែជំនួយទ្វេភាគីភាគច្រើន សម្រាប់ការអប់រំថ្នាក់ មូលដ្ឋាន នៅតែបន្តត្រូវបានបែងចែកតាមទីតាំង និងវិស័យដដែល។

## ភាពជាដៃគូសកលកាន់តែមានលទ្ធភាពជាងមុនក្នុងការផ្តោតគោលដៅចំប្រទេសដែលមានតម្រូវការ

ភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) ដែលកាលពីមុនហៅថា គំនិតផ្តួចផ្តើមពន្លឿនការអប់រំសម្រាប់ទាំងអស់គ្នា ដែលត្រូវបាន បង្កើតឡើង នៅក្នុងឆ្នាំ ២០០២ អាច

បំពេញតួនាទីសំខាន់ នៅក្នុងការសម្របសម្រួលជំនួយអប់រំ ក្នុងពិភពលោកទាំងមូល ប៉ុន្តែកម្មវិធីនេះពុំមានការគាំទ្រ ហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីធ្វើការងារនេះឱ្យមានប្រសិទ្ធភាព។ ផ្ទុយទៅវិញ ចំណុចខ្លាំង និងសក្តានុពលរបស់កម្មវិធីនេះ ពឹងអាស្រ័យលើ លទ្ធភាពរបស់កម្មវិធីនេះ ក្នុងការផ្តោត គោលដៅចំប្រទេស ដែលមានតម្រូវការ។ ជាមធ្យម ចាប់ពី ឆ្នាំ ២០១០ ដល់ ២០១២ ជំនួយ ៨១% នៃជំនួយសរុបរបស់ GPE ត្រូវបានផ្តល់ដល់ប្រទេសដែលមានចំណូលទាប បើធៀបជាមួយនឹង ៤២% នៃជំនួយពីគណៈកម្មាធិការផ្តល់ជំនួយអភិវឌ្ឍន៍របស់ OECD។

## *យុទ្ធសាស្ត្រផ្តល់ជំនួយ ចាំបាច់ត្រូវតែពង្រីកលើសពីការសម្រេចឱ្យបាននូវការចូលរៀន*

លទ្ធផលនៃជំនួយដល់វិស័យអប់រំ ដែលគេអាចមើលឃើញជាក់ច្បាស់បំផុត គឺការបង្កើនការចូលរៀន ជាពិសេសក្នុងការអប់រំថ្នាក់មូលដ្ឋាន។ ឥទ្ធិពលដែលជំនួយបរទេសមានមកលើយុគភាពយេនឌ័រ មានតិចតួច។ ប៉ុន្តែ កត្តាប្រឈម ដែលរារាំងក្មេងស្រីមិនឱ្យទៅរៀនតាមសាលារៀននានាពីដំបូងទី ដូចជា បញ្ហាពាក់ព័ន្ធនឹងភាពក្រីក្រ ចំងាយទៅកាន់សាលារៀន ចំណាយឱកាសសម្រាប់ការទៅរៀនរបស់ក្មេងស្រី និងជំនឿនខាងវប្បធម៌-អាចដោះស្រាយបានតាមរយៈការបង្កើនប្រសិទ្ធភាពនៃការជំនួយរបស់អ្នកផ្តល់ជំនួយ។

## *តួនាទីរបស់ជំនួយមនុស្សធម៌ សម្រាប់វិស័យអប់រំ*

ស្របពេលដែលស្ថានភាពអាសន្នអូសបន្លាយពេលយូរកើតឡើងកាន់តែញឹកញាប់ជាងមុន នៅក្នុងទសវត្សរ៍ចុងក្រោយនេះ វិស័យអប់រំ បានព្យាយាមពន្យល់ដល់ អ្នកដែលធ្វើការងារក្នុងវិស័យជំនួយមនុស្សធម៌ថា ការវិនិយោគលើវិស័យអប់រំ គឺជាការសង្គ្រោះជីវិត។ ប៉ុន្តែ ជំនួយដល់វិស័យអប់រំបន្តទទួលការយកចិត្តទុកដាក់តិចតួច នៅក្នុងប្រព័ន្ធជំនួយមនុស្សធម៌ដែលកំពុងតែខ្វះធនធានស្រាប់ផងនោះ។ នៅក្នុងឆ្នាំ ២០១២ រដ្ឋាភិបាល ទីភ្នាក់ងារសហប្រជាជាតិ វិស័យឯកជន និងអង្គការសង្គមស៊ីវិល បានអំពាវនាវឱ្យមានការបង្កើនទ្វេដងនូវភាគរយនៃជំនួយមនុស្សធម៌ សរុបដែលវិភាជន៍សម្រាប់វិស័យអប់រំ ឱ្យបានយ៉ាងហោចណាស់ ៤% នៃមូលនិធិទាំងអស់ ដែលបានពីការអំពាវនាវសុំជំនួយមនុស្សធម៌។ បើទោះ បីជាមានការអំពាវនាវបែបនេះយ៉ាងណាក៏ដោយ នៅក្នុងឆ្នាំ ២០១៣ វិស័យនេះទទួលបានត្រឹមតែ ២% ប៉ុណ្ណោះ។

## *អង្គការមិនមែនរដ្ឋាភិបាល ហាក់បីដូចជាផ្តល់ធនធានបានច្រើន សម្រាប់គោលដៅអប់រំសម្រាប់ទាំងអស់គ្នា ដែលគេមិនសូវយកចិត្តទុកដាក់*

ហិរញ្ញប្បទានរបស់អង្គការមិនមែនរដ្ឋាភិបាល សម្រាប់ការអប់រំក្នុងប្រព័ន្ធ មានការកើនឡើងដល់ចន្លោះពី ២,៦ ពាន់លានដុល្លារ និង ៥,២ ពាន់លានដុល្លារ។ អង្គការមិនមែនរដ្ឋាភិបាលបានក្លាយជាអ្នកដែលមានតួនាទីសំខាន់ នៅក្នុងការផ្តល់សេវាជាមូលដ្ឋាន នៅតាមប្រទេសមួយចំនួន ហើយចំណាយ របស់អង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំបង្ហាញថា គោលដៅរបស់អង្គការទាំងនេះត្រូវបានតម្រឹមស្របជាមួយនឹងគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា ដែលកន្លងមក មិនសូវទទួលបានការយកចិត្តទុកដាក់ពីរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ដូចជា ការអប់រំក្រៅប្រព័ន្ធ និងការគាំពារ និងអប់រំកុមារតូចជាដើម។

## *ហិរញ្ញប្បទានបែបថ្មី អាចមានតួនាទីរឹតតែសំខាន់*

ហិរញ្ញប្បទានបែបថ្មី មានការកើនឡើងយ៉ាងគំហុករហូតដល់ជាង ៥០ ពាន់លានដុល្លារ។ នៅក្នុងឆ្នាំ ២០១០ ក្រុមការងារដឹកនាំខាង ការផ្តល់ហិរញ្ញប្បទានបែបថ្មីដល់ការអភិវឌ្ឍបានផ្តល់អនុសាសន៍ឱ្យមានការបង្កើនយន្តការចំនួន ៩ ដើម្បីបង្កើនថវិកាសម្រាប់វិស័យអប់រំ ដូចជា ពន្ធលើប្រតិបត្តិការហិរញ្ញវត្ថុ មូលបត្រអប់រំជារូបិយប័ណ្ណក្នុងស្រុក មូលនិធិវិនិយោគ មូលបត្រ diaspora ការផ្តល់ភាគទានដោយស្ម័គ្រចិត្តពី ទេសន្តរប្រវេសន៍ជន ការផ្លោះប្តូរបំណុល ការយកពន្ធលើកីឡា ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន និងការផ្តល់ជំនួយខ្នាតតូច។ យន្តការស្រដៀងគ្នានេះ បានប្រមែប្រមូលថវិកាជាង ៧ ពាន់លានដុល្លារ សម្រាប់ផ្តល់ជំនួយដល់វិស័យសុខាភិបាល ចាប់តាំងពីឆ្នាំ ២០០២ មក ប៉ុន្តែយន្តការបែបនេះតិចតួចប៉ុណ្ណោះ ដែលត្រូវបានគេប្រើប្រាស់ ដើម្បីផ្តល់មូលនិធិដល់វិស័យអប់រំ។

# អនុសាសន៍

## 1 បង្កើនការផ្តោតការយកចិត្តទុកដាក់លើការគាំពារ និងអប់រំកុមារតូច

ប្រទេសទាំងអស់គួរធ្វើឱ្យការអប់រំកម្រិតមត្តេយ្យសិក្សាយ៉ាងហោចណាស់ឱ្យបាន ១ ឆ្នាំ ក្លាយជាការអប់រំតាមបែបចាប់បង្ខំតាមច្បាប់ នៅក្នុងវដ្តនៃការអប់រំថ្នាក់មូលដ្ឋាន ហើយរដ្ឋាភិបាលគួរផ្តល់នូវធនធានដែលចាំបាច់ សម្រាប់ការងារនេះ។

នៅក្នុងករណីដែលថវិការបស់រដ្ឋាភិបាល មិនអាចពង្រីកសេវាសម្រាប់ទាំងអស់គ្នាបាននោះទេ រដ្ឋាភិបាលគួរផ្តោតគោលដៅលើក្រុមប្រជាជនដែលជួបការលំបាកជាងគេ។

គួរមានការផ្តល់ការគាំទ្រដល់កម្មវិធីអប់រំកុមារតូចក្រៅប្រព័ន្ធ និងតាមសហគមន៍ នៅក្នុងករណីដែលពិបាកនឹងអនុវត្តកម្មវិធីអប់រំក្នុងប្រព័ន្ធ។

ការគាំពារ និងការបង្រៀន គួរតែមានគុណភាពល្អ ហើយបុគ្គលិកគួរទទួលបានការបណ្តុះបណ្តាល ដើម្បីភ្ញោចការទទួលបានចំណេះដឹងរបស់កុមារតូច និងផ្តល់ឱ្យពួកគេនូវការគាំទ្រផ្នែកចិត្តសង្គម។

ប្រទេសនានាគួរខិតខំទាក់ទាញអ្នកផ្តល់ការថែទាំ និងគ្រូបង្រៀនដែលមានសមត្ថភាពឱ្យបានកាន់តែច្រើននាក់ថែមទៀត តាមរយៈការបង្កើនឋានៈ និងបៀវត្សរ៍របស់ពួកគេឱ្យស្មើនឹងគ្រូបឋមសិក្សា។

## 2 ធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីផ្តល់លទ្ធភាពឱ្យកុមារគ្រប់រូបអាចរៀនចប់បឋមសិក្សា

រដ្ឋាភិបាលចាំបាច់ត្រូវតែបង្កើតនូវកម្មវិធីផ្ទេរប្រាក់ ដែលមានលក្ខណៈប្រាកដនិយម ជាមួយនឹងការដាក់លក្ខខណ្ឌងាយៗ និងផ្តោតចំគោលដៅ ដើម្បីជួយដល់គ្រួសារក្រីក្រក្នុងការរ៉ាប់រងចំណាយសម្រាប់ការរៀនសូត្រ ដូចជា ការបង់ថ្លៃក្រៅផ្លូវការ ឯកសណ្ឋាន និងការធ្វើដំណើរជាដើម។

ដើម្បីបង្កើនការចូលរួមរបស់សាលារៀន និងកាត់បន្ថយការបោះបង់ចោលការសិក្សា រដ្ឋាភិបាលគួរអនុវត្តកម្មវិធីអន្តរវិស័យ នៅក្នុងវិស័យនានា ដូចជា សុខភាព និងអាហារូបត្ថម្ភជាដើម ក៏ដូចជាធ្វើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទឹក និងអគ្គិសនីជាដើម។

រដ្ឋាភិបាលគួររៀបចំនូវផែនការបម្រុង ដើម្បីឆ្លើយតបទៅនឹងតម្រូវការអប់រំរបស់កុមារ ដែលកំពុងស្ថិតនៅក្នុងស្ថានភាពអាសន្ន និងក្នុងតំបន់ដែលមានជម្លោះប្រដាប់អាវុធ។

## 3 បង្កើនការទទួលបានជំនាញការងារ និងបំណិនជីវិតដល់យុវជន និងមនុស្សពេញវ័យ

រដ្ឋាភិបាលចាំបាច់ត្រូវតែធានាយ៉ាងណាឱ្យយុវជនគ្រប់រូបជាពិសេស យុវជនដែលមានឱកាសតិចតួចជាងគេ ទទួលបានជំនាញមូលដ្ឋាន តាមរយៈការទទួលបានជាសកលនូវការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ដែលផ្តល់ដោយមិនគិតថ្លៃ និងត្រូវបានកំណត់ដោយច្បាប់។

ដោយមានការទទួលស្គាល់ថា ការរៀនបណ្តើរ ធ្វើការបណ្តើរ នឹងធ្វើឱ្យប៉ះពាល់ដល់ឱកាសរបស់កុមារ ដើម្បីទទួលបានជំនាញជាមូលដ្ឋាន ប្រទេសទាំងអស់គួរផ្តល់សច្ចាប័ន ប្រកាសឱ្យអនុវត្ត និងអនុវត្តអនុសញ្ញាលេខ ១៣៨

របស់អង្គការអន្តរជាតិខាងការងារ ដែលកំណត់អាយុអប្បបរមា សម្រាប់ការទទួលយកឱ្យចូលធ្វើការ។

អ្នកតាក់តែងគោលនយោបាយគួរធ្វើការកំណត់ និងផ្តល់អាទិភាពដល់ជំនាញ ដែលត្រូវទទួលបាននៅចុងដំណាក់កាលនីមួយៗនៃការអប់រំក្នុងប្រព័ន្ធ។

រដ្ឋាភិបាលគួរវាស់វែង ដើម្បីឱ្យដឹងថាតើការអប់រំ ឬការបណ្តុះបណ្តាលប្រភេទណាមួយ ដូចជា កម្មវិធីបណ្តុះបណ្តាលពេលកំពុងធ្វើការជាក់ស្តែង និងកម្មវិធីហត្ថការជាដើម ដែលមានប្រសិទ្ធភាព និងមានសមធម៌បំផុតសម្រាប់ការទទួលបានជំនាញ។

ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្សពេញវ័យដែលមានកម្រិតវប្បធម៌ទាប រដ្ឋាភិបាលគួរពង្រីកឱកាសឱ្យមនុស្សពេញវ័យ អាចបន្តការអប់រំរបស់ខ្លួនទៀតបាន។

## 4 បង្កលក្ខណៈឱ្យមនុស្សពេញវ័យទាំងអស់អាចសម្រេចបានសិទ្ធិរបស់ខ្លួន ក្នុងការទទួលបានចំណេះដឹងអក្ខរកម្ម និងលេខនពន្ធ

គោលនយោបាយ និងយុទ្ធសាស្ត្រអក្ខរកម្ម គួរភ្ជាប់ទំនាក់ទំនងគោលនយោបាយអភិវឌ្ឍន៍ ដែលមានស្រាប់ ជាមួយនឹងតម្រូវការរបស់សហគមន៍ ដូចជា តម្រូវការខាងសុខភាព ការអភិវឌ្ឍសហគមន៍ នវានុវត្តន៍ខាងកសិកម្ម និងការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋ។

ការប្រើប្រាស់ទូរស័ព្ទដៃ និងបច្ចេកវិទ្យា ICT ផ្សេងទៀត ដើម្បីទទួលបាន និងរក្សាចំណេះដឹងអក្ខរកម្ម គួរទទួលបានការគាំទ្រ តាមរយៈភាពជាដៃគូរវាងរដ្ឋាភិបាល និងវិស័យឯកជន។

ប្រទេសនានាគួរពង្រឹងកម្មវិធីអក្ខរកម្មរបស់ខ្លួន តាមរយៈការកំណត់ពីកម្រិតជំនាញ ដែលមនុស្សពេញវ័យត្រូវទទួលបាន និងតាមរយៈការវាស់វែង និងពិនិត្យតាមដានលើការចូលរួម និងលទ្ធផលដែលសម្រេចបាន។

## 5 ផ្លាស់ប្តូរការផ្តោតការយកចិត្តទុកដាក់ពីយុគភាពយេនឌ័រ ទៅសមភាពយេនឌ័រ

ដើម្បីធ្វើឱ្យបរិយាកាសរៀនសូត្រកាន់តែមានសមធម៌ គេចាំបាច់ត្រូវតែប្រើប្រាស់ធនធានឱ្យចំគោលដៅ ដើម្បីធានាយ៉ាងណាឱ្យមានសម្ភារបង្រៀន និងសម្ភារប្រេវន្តទឹក និងអនាម័យគ្រប់គ្រាន់។

រដ្ឋាភិបាលចាំបាច់ត្រូវតែធានាយ៉ាងណាឱ្យកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការ មានដាក់បញ្ចូលយុទ្ធសាស្ត្រយេនឌ័រ សម្រាប់ឱ្យគ្រូប្រើប្រាស់ នៅក្នុងគរុកោសល្យ និងការគ្រប់គ្រងថ្នាក់រៀនរបស់ខ្លួន។ ការរៀបចំកម្មវិធីទាំងនេះចាំបាច់ត្រូវតែធ្វើឡើងឱ្យបានប្រុងប្រយ័ត្ន ដោយត្រូវគិតពិចារណាពីវិសមភាពយេនឌ័រ ដែលកំពុងកើតមានឡើងនៅក្នុងបរិបទមូលដ្ឋាន។

កម្មវិធីសិក្សាត្រូវតែឆ្លើយតបចំពោះយេនឌ័រ និងមានដាក់បញ្ចូលការបង្រៀនអំពីសុខភាពបន្តពូជ និងផ្លូវភេទ។

## 6 វិនិយោគលើគុណភាពនៃការអប់រំ

រដ្ឋាភិបាលចាំបាច់ត្រូវធ្វើការវិនិយោគឱ្យបានច្រើនលើការផ្តល់ការអប់រំដែលមានគុណភាពល្អ។ គោលនយោបាយដែលលើកកម្ពស់វិជ្ជាជីវៈ និងបង្កើនការលើកទឹកចិត្តដល់គ្រូគួរចាត់ទុកជាគោលនយោបាយអាទិភាព។ គួរមានការពិចារណាឱ្យបានល្អិតល្អន់លើហានិភ័យ ដែលពាក់ព័ន្ធជាមួយនឹងការជ្រើសរើសគ្រូកិច្ចសន្យា។

គ្រូគួរទទួលបានការគាំទ្រ ជាមួយនឹងកម្មវិធីសិក្សាដែលពាក់ព័ន្ធ និងមានលក្ខណៈរួមបញ្ចូលគ្នា ដើម្បីធ្វើឱ្យការរៀនសូត្ររបស់សិស្ស កាន់តែមានភាពល្អប្រសើរមួយកម្រិតទាប ជាពិសេស ផ្តល់លទ្ធភាពឱ្យសិស្សរៀនខ្សោយអាចរៀន

ទាន់គេ។ ធនធានរៀនសូត្រសមស្របគ្រប់ គ្រាន់ ជាពិសេស សៀវភៅសិក្សា ចាំបាច់ត្រូវតែផ្តល់ដល់សិស្សឱ្យបានគ្រប់រូប។

បែបផែននៃការបង្រៀន និងវិធីសាស្ត្របង្រៀន ចាំបាច់ត្រូវតែឆ្លើយតបឱ្យបានកាន់តែប្រសើរទៅនឹងបរិបទវប្បធម៌ និងបរិបទក្នុងថ្នាក់រៀន។ នៅក្នុងសង្គមពហុភាសា គោលនយោបាយភាសាក្នុងការអប់រំ មានសារៈសំខាន់ជាពិសេស សម្រាប់ឱ្យការរៀនសូត្រកាន់តែមានប្រសិទ្ធភាព។

ប្រព័ន្ធអភិបាលកិច្ច គួរដាក់បញ្ចូលការរៀបចំស្ថាប័នដែលមានភាពរឹងមាំ ជាមួយនឹងការប្តេជ្ញាចិត្ត ដើម្បីសម្រេចឱ្យបាននូវសមធម៌។

រដ្ឋាភិបាលគួរអនុវត្តគោលនយោបាយ ដើម្បីពង្រាយគ្រូឱ្យបានសមស្រប នៅតំបន់ដែលខ្វះគ្រូ។



ពេលវេលាគ្រប់គ្រាន់ និងមានគុណភាព ក្នុងសាលារៀន ដើម្បីឱ្យគ្រូ និងសិស្សចូលរួមឱ្យបានសកម្ម នៅក្នុងសកម្មភាពរៀនសូត្រ មានសារៈសំខាន់យ៉ាងខ្លាំង។

ប្រទេសទាំងឡាយគួរពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការវាយតម្លៃលើការរៀនសូត្រ ដើម្បីឆ្លុះបញ្ចាំងពីអាទិភាពនៅថ្នាក់ជាតិ និងផ្ដល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីធានាឱ្យការផ្ដល់ការអប់រំ ប្រកបដោយគុណភាព ប្រសិទ្ធភាពបង្រៀន និងការរៀនសូត្រ ប្រកបសមធម៌ តាមមុខវិជ្ជានានា។

## 7 បង្កើនហិរញ្ញប្បទានសម្រាប់ការអប់រំ និងផ្ដោតការផ្ដល់ធនធានឱ្យចំក្រុមដែលជួបការលំបាកបំផុត

រដ្ឋាភិបាលគួរធ្វើការកៀងគរធនធានក្នុងស្រុកបន្ថែមទៀត ដើម្បីធានាយ៉ាងណាឱ្យក្របខ័ណ្ឌអប់រំក្រោយឆ្នាំ ២០១៥ ទទួលបានហិរញ្ញប្បទានពីប្រភពដែលមាននិរន្តរភាព។ ប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមកម្រិតទាប ត្រូវចំណាយថវិកាស្មើនឹង ៣,៤% នៃ GDP របស់ខ្លួន លើការអប់រំកម្រិតមត្តេយ្យសិក្សាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ឬ ៥,៤% នៃ GDP សម្រាប់ការអប់រំនៅគ្រប់កម្រិតទាំងអស់។

ចាំបាច់ត្រូវតែមានការវិភាជន៍ធនធានសម្រាប់ការអប់រំសាធារណសារជាថ្មី ដើម្បីឱ្យមានការផ្ដល់ធនធានទាំងនេះ ដល់ការអប់រំកម្រិតមត្តេយ្យសិក្សា ការអប់រំក្រៅប្រព័ន្ធ និងអក្ខរកម្មមនុស្សពេញវ័យ ដើម្បីជាប្រយោជន៍ដល់ក្រុមដែលគ្មានឱកាស។ អ្នកផ្ដល់ជំនួយគួរបង្កើនជំនួយរបស់ខ្លួនឱ្យបានច្រើន សម្រាប់វិស័យអប់រំ និងធានាយ៉ាងណាឱ្យមានការប្រើប្រាស់ធនធានទាំងនេះឱ្យចំគោលដៅជាងមុន។ ការសម្របសម្រួល ការងារអភិវឌ្ឍន៍សកល និងជំនួយមនុស្សធម៌ មិនត្រូវទុកចោលប្រទេស ដែលត្រូវការការគាំទ្រជាងគេនោះទេ។

ដោយសារតែថវិកានៅខ្វះប្រមាណជា ២២ ពាន់លានដុល្លារទៀត អ្នកផ្ដល់ជំនួយចាំបាច់ត្រូវបង្កើនបរិមាណនៃជំនួយរបស់ខ្លួនដល់ការអប់រំកម្រិតមត្តេយ្យសិក្សាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ក្នុងប្រទេសចំណូលទាប និងប្រទេសចំណូលមធ្យមកម្រិតទាប ឱ្យបានយ៉ាងហោចណាស់ ៤ ដង។

ការវិនិយោគលើឧបករណ៍វិភាគ ដែលធ្វើការតាមដានរាល់ធនធាន ប្រើប្រាស់នៅក្នុងវិស័យអប់រំ នឹងជួយដល់រដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយ ធ្វើការវាយតម្លៃកាន់តែប្រសើរលើរបៀបដែលក្រុមដែលមានចំណូលផ្សេងៗគ្នា ទទួលបានប្រយោជន៍ពីចំណាយផ្លូវការ និងធានាយ៉ាងណាមិនឱ្យកុមារក្រីក្រជាងគេ នៅក្រោយគេនោះឡើយ។

## 8 សម្រួចការយកចិត្តទុកដាក់លើសមធម៌

ដើម្បីដោះស្រាយបញ្ហាសមធម៌ ដំបូងបំផុត រដ្ឋាភិបាលចាំបាច់ត្រូវធ្វើការផ្លាស់ប្ដូររបៀប ដែលរដ្ឋាភិបាលប្រើប្រាស់ព័ត៌មាន ដើម្បីគ្រោងរៀបចំអន្តរាគមន៍អប់រំរបស់ខ្លួន។

រដ្ឋាភិបាលគួរផ្ដល់អាទិភាពដល់ការប្រើប្រាស់ទិន្នន័យ ដែលត្រូវបានបែងចែកលំអិត ទទួលបានពីការអង្កេតតាមសាលារៀន គ្រួសារ និងទីផ្សារការងារ ដើម្បីកែលំអផែនការអប់រំរបស់ខ្លួន និងផ្ដោតធនធានឱ្យចំអ្នកដែលមានតម្រូវការច្រើនជាងគេ។

## 9 ដោះស្រាយបញ្ហាកង្វះទិន្នន័យធ្ងន់ធ្ងរ ដើម្បីឱ្យការពិនិត្យតាមដានកាន់តែមានលក្ខណៈល្អប្រសើរមួយកម្រិតទៀត

ការកែលំអមូលដ្ឋានចំណេះដឹងនៃប្រព័ន្ធអប់រំជាតិ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីបំបិទគម្លាតធ្ងន់ធ្ងរខាងទិន្នន័យ ពាក់ព័ន្ធនឹងបញ្ហានានា ចាប់ពីគុណភាព រហូតដល់ជំនាញអក្ខរកម្ម និងទិន្នន័យពាក់ព័ន្ធនឹងហិរញ្ញប្បទាន។ ដើម្បីដោះស្រាយបញ្ហានេះ ទាមទារឱ្យមានការបង្កើតស្តង់ដាររួមការកសាងសមត្ថភាព និងការសម្របសម្រួលទិន្នន័យ។

ចាំបាច់ត្រូវមានការសហការឱ្យបានជិតស្និទ្ធបន្ថែមទៀត ដើម្បីធ្វើការពិនិត្យតាមដានវឌ្ឍនភាពនៃការរៀនសូត្រ នៅក្នុងរយៈពេលមួយ និងវឌ្ឍនភាព ដែលសម្រេចបានតាមប្រទេសនានា ផ្អែកទៅតាមរង្វាស់ ដែលគេអាចភ្ជាប់ទំនាក់

ទំនងជាមួយនឹងការវាយតម្លៃថ្នាក់ជាតិលើការរៀនសូត្រមុខវិជ្ជានានា។

រដ្ឋាភិបាលគួរបង្កើតក្របខ័ណ្ឌពិនិត្យតាមដាន ដើម្បីប្រមូលទិន្នន័យលំអិតអំពីស្ថានភាពនៃការអប់រំរបស់ក្រុមប្រជាជនផ្សេងៗ។

ភាពអាចរកបាន ភាពអាចជឿទុកចិត្តបាន និងលទ្ធភាពប្រៀបធៀបគ្នាបាននៃទិន្នន័យអក្ខរកម្ម គួរពង្រីកបន្ថែមទៀត ដើម្បីកែលំអការរៀបចំផែនការ និងការតាក់តែងគោលនយោបាយ។

ជាមួយនឹងការបញ្ចប់អណត្តិនៃរបាយការណ៍ពិនិត្យតាមដានជាសកលនេះ របាយការណ៍ពិនិត្យតាមដានជាសកលដោយឯករាជ្យលើវិស័យអប់រំ ចាំបាច់ត្រូវតែបន្តមានទៀត។

### 10 ដោះស្រាយបញ្ហាប្រឈមនៅក្នុងការសម្របសម្រួលដើម្បីបន្តរក្សាការគាំទ្រនយោបាយកម្រិតខ្ពស់សម្រាប់វិស័យអប់រំ

យុទ្ធសាស្ត្រ សម្រាប់អនុវត្តគោលនយោបាយអប់រំ ចាំបាច់ត្រូវតែមានលក្ខណៈរឹងមាំខាងបច្ចេកទេស និងមានភាពទាក់ទាញខាងនយោបាយ។ យុទ្ធសាស្ត្រទាំងនេះចាំបាច់ត្រូវតែមានគោលដៅច្បាស់លាស់ និងតម្រូវឱ្យមានសមត្ថភាពខាងយុទ្ធសាស្ត្រ និងបច្ចេកទេសជាក់លាក់។ យុទ្ធសាស្ត្រទាំងនេះគួរទទួលបានហិរញ្ញប្បទានពីប្រភពរួម និងមានការវាយតម្លៃជាទៀងទាត់ ជាមួយនឹងការគាំទ្រនយោបាយច្បាស់លាស់ និងមានការគាំទ្រពីស្ថាប័នដែលមានឥទ្ធិពល។

ចាំបាច់ត្រូវតែមានយន្តការគណនេយ្យភាពច្បាស់លាស់ ដើម្បីទាមទារឱ្យរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយមានគណនេយ្យភាព ប្រសិនបើរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយមិនបានសម្រេចតាមចំណុចដៅ ឬខកខានមិនបានបំពេញទៅតាមការសន្យារបស់ខ្លួន។

ការអប់រំគឺជាកូនសោរដើម្បីសម្រេចគោលដៅភាគច្រើននៅក្នុងរបៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ ២០១៥ ចេញពីផ្តោតលើការប្រើប្រាស់ប្រកបដោយនិរន្តរភាព ទៅជាការផ្តោតលើសុខភាព និងសង្គមដែលមានសុខសន្តិភាព។ គួរមានការរៀបចំកម្មវិធី និងអភិក្រមប្រើប្រាស់ក្នុងវិស័យអប់រំសារជាថ្មី ដើម្បីសម្រេចគោលដៅទាំងនេះ។

# ការអប់រំសម្រាប់ទាំងអស់គ្នា ២០០០-២០១៥ ៖ សមិទ្ធផល និងបញ្ហាប្រឈម

កំណែទី ១២ នៃរបាយការណ៍ពិនិត្យតាមដានសកលលើការអប់រំសម្រាប់ទាំងអស់គ្នា - ដែលរៀបចំឡើងស្របពេលនឹងកាលបរិច្ឆេទកំណត់ឆ្នាំ ២០១៥ សម្រាប់គោលដៅទាំង ៦ ដែលត្រូវបានដាក់ចេញនៅក្នុងវេទិកាអប់រំពិភពលោក នៅទីក្រុងដាកា ប្រទេសសេណេហ្គាល់ កាលពីឆ្នាំ ២០០០ ធ្វើការពិពណ៌នាគ្រប់ជ្រុងជ្រោយ ដោយមានការពិចារណាល្អិតល្អន់អំពីវឌ្ឍនភាព ដែលសម្រេចបានក្នុងសកលលោកទាំងមូល។ ស្របពេលដែលសហគមន៍អន្តរជាតិត្រៀមខ្លួន សម្រាប់របៀបវារៈថ្មីខាងការអភិវឌ្ឍ និងការអប់រំ របាយការណ៍នេះធ្វើការបូកសរុបសមិទ្ធផល ដែលសម្រេចបានកន្លងមក និងធ្វើការឆ្លុះបញ្ចាំងពីបញ្ហាប្រឈម ដែលអាចកើតមានឡើងនាពេលអនាគត។

មានសញ្ញាជាច្រើន ដែលបង្ហាញពីភាពជឿនលឿនគួរឱ្យកត់សម្គាល់។ ការឈានទៅសម្រេចសកលកម្មនៃការអប់រំបឋមសិក្សា ធ្វើឡើងក្នុងល្បឿនយ៉ាងលឿន គម្លាតយេនឌ័រត្រូវបានកាត់បន្ថយ នៅក្នុងប្រទេសជាច្រើន ហើយរដ្ឋាភិបាលកំពុងតែបង្កើនការផ្តោតការយកចិត្តទុកដាក់របស់ខ្លួនលើការធានាយ៉ាងណាឱ្យកុមារទទួលបានការអប់រំ ដែលមានគុណភាពល្អ។ ប៉ុន្តែ បើទោះបីជាមានកិច្ចខិតខំប្រឹងប្រែងទាំងនេះក៏ដោយ ពិភពលោកទាំងមូលខកខានមិនបានសម្រេចទៅតាមការប្តេជ្ញាចិត្តជារួមរបស់ខ្លួន ចំពោះការអប់រំសម្រាប់ទាំងអស់គ្នា។ កុមារ និងក្មេងជំទង់រាប់លាននាក់ បន្តនៅក្រៅសាលារៀន ហើយប្រជាពលរដ្ឋក្រីក្រជាងគេ និងជួបការលំបាកជាងគេ គឺជាអ្នកដែលត្រូវទទួលរងផលប៉ះពាល់ ដោយសារតែបរាជ័យ ក្នុងការសម្រេចចំណុចដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា។

របាយការណ៍ក្រោមចំណងជើង ការអប់រំសម្រាប់ទាំងអស់គ្នា ២០០០-២០១៥ ៖ សមិទ្ធផល និងបញ្ហាប្រឈមនេះ ធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយលើវឌ្ឍនភាពនៅកម្រិតប្រទេស ក្នុងការឈានទៅសម្រេចគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា និងរំលេចឱ្យឃើញពីការងារដែលនៅសេសសល់។ របាយការណ៍នេះរំលេចពីគោលនយោបាយដែលមានប្រសិទ្ធភាព និងលើកឡើងនូវអនុសាសន៍ សម្រាប់ធ្វើការពិនិត្យតាមដាន និងវាយតម្លៃចំណុចដៅអប់រំ ក្រោយឆ្នាំ ២០១៥។ របាយការណ៍នេះក៏ផ្តល់ឱ្យអ្នកតាក់តែងគោលនយោបាយនូវប្រភពអាចជឿជាក់បាន សម្រាប់យកទៅធ្វើការតស៊ូមតិ ដើម្បីឱ្យការអប់រំក្លាយជាសសរគ្រឹះនៃរបៀបវារៈអភិវឌ្ឍន៍សកល ក្រោយឆ្នាំ ២០១៥។

របាយការណ៍ពិនិត្យតាមដានសកលលើការអប់រំសម្រាប់ទាំងអស់គ្នា គឺជាឯកសារបោះពុម្ពផ្សាយ ដែលអ្នកនិពន្ធផ្តល់មតិយោបល់ដោយឯករាជ្យ ឈរលើភស្តុតាងផ្សេងៗ ដែលរដ្ឋាភិបាល អ្នកសិក្សាស្រាវជ្រាវ អ្នកឯកទេសខាងការអប់រំ និងការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយ និងសិស្ស និស្សិតអាចយកទៅប្រើប្រាស់ជាឧបករណ៍ចាំបាច់មួយ។ របាយការណ៍នេះបានធ្វើការវាយតម្លៃលើវឌ្ឍនភាពក្នុងវិស័យអប់រំនៅក្នុង២០០ប្រទេស និងដែនដីស្ទើរតែរៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០០២មក។ ការងារនេះនឹងបន្តមានទៀតនៅក្នុងរយៈពេលនៃការអនុវត្តរបៀបវារៈ អភិវឌ្ឍន៍ប្រកបដោយចីរភាព ក្រោយឆ្នាំ ២០១៥ ដែលពេលនោះហៅថា របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំ។

*កំណែទម្រង់មួយ ក្នុងចំណោមកំណែទម្រង់ធំៗ ចាប់តាំងពីឆ្នាំ ២០០០ មក គឺគោលនយោបាយ ដែលតម្រូវឱ្យកុមារគ្រប់រូបត្រូវតែទៅសាលារៀន។ កំណែទម្រង់នេះបានជួយឱ្យមនុស្សគ្រប់រូបភ្លក់រសជាតិផលដែលទទួលពីការអប់រំ។ កំណែទម្រង់នេះបានប្លន់កម្លាំងពលកម្មពីកសិករ ប៉ុន្តែបានផ្តល់ឱ្យពួកគេវិញនូវគ្រាប់ពូជ សម្រាប់លើកកម្ពស់ជីវភាពរស់នៅនាពេលអនាគត។*

- Sonam គ្រូ នៅប្រទេសប៊ូតាន

*មាតាបិតា ដែលជួបនឹងការលំបាក ដោយមិនចេះសរសេរអក្សរ មិនចេះប្រើទូរស័ព្ទដៃ ឬម៉ាស៊ីន ATMs ធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីផ្តល់ឱ្យកូនៗរបស់ពួកគេនូវការអប់រំ ដើម្បីកុំឱ្យពួកគេត្រូវបាត់បង់ឱកាស ដោយសារតែមិនចេះអក្សរ។*

- Omovigho Rani Ebireri
សកលវិទ្យាល័យ Maiduguri ប្រទេសនីហ្សេរីយ៉ា

*ឈប់រៀន ដោយសារតែអ្វីដែលបង្កឡើងដោយក្រុមឧទ្ទាម។ ពួកគេបានបំផ្លាញសាលារៀនរបស់យើង យើងលែងអាចទៅរៀនទៀត។ ពួកគេមិនចូលចិត្តរបៀបស្លៀកពាក់របស់ក្មេងស្រីមួយចំនួន។ ពួកគេស្រែកឱ្យយើង ដោយនិយាយថា អ្វីដែលយើងកំពុងតែពាក់មិនល្អឡើយ។ ពួកគេបំផ្លាញតុក្នុងសាលារៀនរបស់យើង បំផ្លាញសៀវភៅក្នុងសាលារៀនរបស់យើង និងរបស់របររបស់យើង។ សាលារៀនត្រូវតែជាកន្លែង ដែលយើងទទួលការរៀនសូត្រ។*

- Sita សិស្ស នៅប្រទេសនេហ្សេរីយ៉ា

*កុមារគ្រប់រូបដែលមានអាយុក្រោម ៥ ឆ្នាំ ត្រូវតែចូលរៀននៅសាលាមត្តេយ្យ។ ការអប់រំកុមារតូច គឺជាអាទិភាពចម្បងមួយ។*

- Martha Isabel Castano
គ្រូបឋមសិក្សា ប្រទេសកូឡុំបៀ

UNESCO Publishing

United Nations
Educational, Scientific and
Cultural Organization

EDUCATION FOR ALL GLOBAL MONITORING REPORT

www.unesco.org/publishing
www.efareport.unesco.org